# ការពារអ្នកការពារសិទ្ធិមនុស្ស៖
# សន្តិសុខដល់អ្នកការពារសិទ្ធិមនុស្សកម្ពុជា
# ២០១៣

ISBN: 978-1-906586-56-0

ផ្ទះលេខ៧៩៨ផ្លូវ៩៩បឹងត្របែកចំការមនប្រអប់សំបុត្រលេខ ២៥១៥ភ្នំពេញព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖៨៥៥(០)២៣៧២ ៦៩០១, ទូរសារ៖៨៥៥(០)២៣៧២៦៩០២

អ៊ីម៉ែល៖ info@cchrcambodia.org

មជ្ឈមណ្ឌលហ្វ្រីវ៉ដ, ផ្លូវហ្វារីនដុនលេខ៦០, ទីក្រុងឡុងដុងEC1R 3GA

ទូរស័ព្ទ៖៤៤២០ ៧៣២៤២៥០០, ទូរសារ៖៤៤២០៧៤៩០ ០៥៦៦អ៊ីម៉ែល info@article19.org

# សេចក្តីថ្លែងអំណរគុណ

ការវិភាគអំពីភាពប្រថុយប្រថានរបស់អ្នកការពារសិទ្ធិមនុស្ស(តទៅហៅថា «របាយការណ៍») ជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) និងអង្គការមាត្រា១៩។ របាយការណ៍នេះជាផ្នែកមួយនៃគម្រោងអ្នកការពារសិទ្ធិមនុស្សរបស់ ម.ស.ម.ក (គ.អ.ស) ដែលមានគោលបំណងបំពេញបន្ថែម និងគាំទ្រដល់បណ្តាញសង្គមស៊ីវិលទាំងឡាយដែលគាំទ្រអ្នកការពារសិទ្ធិមនុស្សកំពុងប្រឈមនឹងគ្រោះថ្នាក់ក្នុងខណៈដែលសេវាគាំទ្រទាំងនោះមិនមានឬមិនគ្រប់គ្រាន់ ហេតុដូចនេះហើយ គម្រោងនេះជានារកឲ្យបានគ្រប់គ្រាន់នូវសេវាគាំទ្រផ្សេងៗទៀតពីភាគីដទៃទៀត ឧទាហរណ៍អង្គការអន្តរជាតិជាដើម។

ក្រោមការឧបត្ថម្ភគាំទ្រជាថវិកាដំបូង ពីសំណាក់កម្មវិធីជំនួយបរទេសរបស់រដ្ឋាភិបាលប្រទេសអូស្ត្រាលីតាមរយៈគម្រោងជំនួយសម្រាប់កិច្ចការសិទ្ធិមនុស្ស គម្រោងអ្នកការពារសិទ្ធិមនុស្សនេះ ត្រូវបានចាប់ផ្តើមអនុវត្តឡើង កាលពីខែមិនា ឆ្នាំ២០១១។ ម.ស.ម.ក ជាអ្នកអនុវត្តគម្រោងនេះផ្ទាល់ ហើយបានទទួលការគាំទ្រពីសំណាក់អង្គការមាត្រា១៩ផងដែរ។ ខ្លឹមសារនៃរបាយការណ៍នេះជាការទទួលខុសត្រូវរបស់ ម.ស.ម.ក និងអង្គការមាត្រា១៩ ហើយមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលីឡើយ។

ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ ឯករាជ្យឈានមុខដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្សពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅកម្ពុជា។ ចក្ខុវិស័យរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាគឺចង់ឲ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាពត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ចង់បានស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយមដោយក្នុងនោះភាពចម្រុះបែបនៃសង្គមត្រូវបានទទួលយកនិងសាទរជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា រំលេចឲ្យឃើញរូបសត្វព្រាបសហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវដែលនេះជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា។

អង្គការមាត្រា១៩ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨៧ ដើម្បីការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ អង្គការមាត្រា១៩មានទស្សនវិស័យចង់បានពិភពលោកមួយ ដែលពលរដ្ឋគ្រប់រូបអាចបញ្ចេញមតិយោបល់របស់ខ្លួនដោយសេរី អាចចូលរួមក្នុងការសម្រេចចិត្តនានានិងធ្វើការជ្រើសរើសដោយត្រឹមត្រូវជុំវិញជំរើសសម្រាប់ជីវិតរបស់ខ្លួន។ ស្ថាប័ននេះយកឈ្មោះតាមមាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សដែលធានាដល់សិទ្ធិសកលក្នុងការបញ្ចេញមតិនិងមានទស្សនយោបល់។ បេសកកម្មរបស់អង្គការមាត្រា១៩គឺធ្វើយុទ្ធនាការ និងការតស៊ូមតិទាមទារសេរីភាពក្នុងការបញ្ចេញមតិនិងព័ត៌មាន ដោយស្ថាប័ននេះមាន

ការិយាល័យតាមប្រទេសមួយចំនួន ដូចជា បង់ក្លាដេស ប្រេស៊ីល គីនយ៉ា ម៉ិចស៊ីកូ ទុនេស៊ីស៊ី ណេហ្គាល និង ចក្រភពអង់គ្លេស ហើយមានការចូលរួមសហការជាមួយដៃគូរចំនួន៩០ នៅលើពិភពលោកផងដែរ។

ប្រសិនលោកអ្នកមានសំណួរឬត្រូវការព័ត៌មានបន្ថែម ពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬមានបំណងចង់ផ្តល់ជាមតិយោបល់សូមសរសេរជាអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈ info@cchrcambodia.org ឬអង្គការមាត្រា១៩តាមរយៈ info@article19.org ។

របាយការណ៍នេះ និងអត្ថបទបោះពុម្ពផ្សាយផ្សេងទៀតរបស់ ម.ស.ម.ក អាចរកបាននៅក្នុងគេហទំព័ររបស់ ម.ស.ម.ក តាមរយៈ www.cchrcambodia.org និងគេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជាដែលបានទទួលជ័យលាភី គឺ www.sithi.org ដែលសម្របសម្រួលដោយ ម.ស.ម.ក។

# មាតិកា


**សេចក្តីសង្ខេប** ..... ៥

**សេចក្តីផ្តើម** ..... ៧

**សាវតារ** ..... ៩

**បទដ្ឋានថ្នាក់អន្តរជាតិ និងតំបន់** ..... ១៣

- បទដ្ឋានអន្តរជាតិ ..... ១៣
- បទដ្ឋានថ្នាក់តំបន់ ..... ១៧

**បទបញ្ញត្តជាតិ និងការរឹតបន្តឹង** ..... ១៩

- ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ..... ២០
- ច្បាប់ស្តីការធ្វើបាតុកម្មដោយសន្តិវិធី ..... ២១
- ច្បាប់ប្រឆាំងអំពើពុករលួយ ឆ្នាំ២០១០ ..... ២២
- ច្បាប់របបសារព័ត៌មាន ឆ្នាំ១៩៩៥ ..... ២៣
- សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ..... ២៣
- សេចក្តីព្រាងច្បាប់ស្តីពីសហជីព ..... ២៤

**ការវាយតម្លៃលើភាពប្រថុយប្រថានរបស់អ្នកការពារសិទ្ធិមនុស្សកម្ពុជា** ..... ២៥

- វិសាលភាព និងវិធីសាស្ត្រ ..... ២៥
- ប្រភេទអ្នកការពារសិទ្ធិមនុស្ស ..... ២៧
  - តំណាងរាស្ត្រគណបក្សប្រឆាំង ..... ២៧
  - មេធាវីសិទ្ធិមនុស្ស ..... ២៩
  - អ្នកសារព័ត៌មាន និងអ្នកជំនាញការខាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ..... ៣១
  - សកម្មជនសិទ្ធិនៅមូលដ្ឋាន ..... ៣៤
  - សកម្មជនសហជីព ..... ៣៨
  - សកម្មជនសិទ្ធិដីធ្លីជាស្ត្រី ..... ៤១
  - បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ..... ៤៦
- ការវាយតម្លៃភាពប្រថុយប្រថាន ..... ៥២
  - ការប្រឈមសំខាន់ៗ ..... ៥៤
  - ភាពងាយរងគ្រោះ ..... ៥៧

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ..... ៦៣

**ឧបសម្ព័ន្ធ ៖ អក្សរកាត់** ..... ៧០

# សេចក្ដីសង្ខេប

ការងាររបស់អ្នកការពារសិទ្ធិមនុស្ស គឺមានតម្លៃខ្លាំងណាស់ក្នុងការធ្វើយ៉ាងណាឲ្យសម្រេចបាននូវការការពារនិងការលើកកម្ពស់សិទ្ធិ ហើយការងារទាំងនោះតែងតែផ្សារភ្ជាប់នឹងការប្រមូលផ្ដុំនិងការចែកចាយព័ត៌មាន ការតស៊ូមតិ ការកៀងប្រមូលនូវទស្សនៈយោបល់ ការពង្រឹងអំណាច និងការគាំទ្រដល់ជនរងគ្រោះពីការរំលោភបំពានសិទ្ធិមនុស្ស។[1] អ្នកការពារសិទ្ធិមនុស្សដើរតួយ៉ាងសំខាន់ក្នុងលទ្ធិប្រជាធិបតេយ្យដោយលើកទឹកចិត្តឲ្យមានការចូលរួមខាងនយោបាយនិងជម្រុញឲ្យមានអភិបាលកិច្ចល្អនិងតម្លាភាព។ ស្ថានភាពសន្តិសុខនិងកម្រិតនៃភាពប្រថុយប្រថានរបស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាត្រូវបានប្រឈមយ៉ាងខ្លាំងនៅឆ្នាំ២០១២ ហើយបន្តប្រឈមថែមទៀតក្នុងឆ្នាំ២០១៣នេះ។ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋាភិបាល) បានបង្ក្រាបជាបន្តបន្ទាប់ប្រឆាំងដល់ការងាររបស់អ្នកការពារសិទ្ធិមនុស្ស ក្នុងខណៈដែលការបោះឆ្នោតថ្នាក់ជាតិឆ្នាំ ២០១៣ កំពុងខិតចូលមកដល់។ ដូចនេះហើយ របាយការណ៍នេះ ចង់ចង្អុលបង្ហាញពីការគំរាមកំហែងសន្តិសុខសំខាន់ៗ ដែលអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាកំពុងប្រឈមមុខ និងធ្វើការវិភាគពីកម្រិតទូទៅនៃភាពប្រថុយប្រថានដែលបណ្ដាលពីការគំរាមកំហែងទាំងនោះ ហើយនិងផ្ដល់ជាអនុសាសន៍ដើម្បីបញ្ចៀសភាពប្រថុយប្រថានព្រមទាំងលើកកម្ពស់សន្តិសុខរបស់អ្នកការពារសិទ្ធិមនុស្ស។ រចនាសម្ព័ន្ធនៃរបាយការណ៍នេះត្រូវបានរៀបរៀងដូចខាងក្រោម៖

**សេចក្ដីផ្ដើមនិងសាវតារ៖** ផ្នែកនេះបង្ហាញនូវគោលបំណងនៃរបាយការណ៍ និងការវិវឌ្ឍសំខាន់ៗ ព្រមទាំងបង្ហាញឲ្យឃើញនូវទិដ្ឋភាពនៃស្ថានភាពសិទ្ធិមនុស្សទូទៅនៅកម្ពុជា ហើយក៏ឆ្លុះបញ្ចាំងពីសាវតារនយោបាយនិងសេដ្ឋកិច្ចផងដែរ។

**បទដ្ឋានបញ្ញត្តថ្នាក់អន្តរជាតិ តំបន់ និងជាតិ៖** ផ្នែកនេះ រៀបរាប់ពីច្បាប់ថ្នាក់ជាតិ តំបន់ និងអន្តរជាតិព្រមទាំងសេចក្ដីប្រកាសនានា ដែលពាក់ព័ន្ធដល់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា។ ច្បាប់និងសេចក្ដីប្រកាសមួយចំនួន ជួយការពារនិងលើកកម្ពស់សិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សតែផ្នែកខ្លះទៀត បានរឹតបន្តឹងដល់ការងាររបស់អ្នកការពារសិទ្ធិមនុស្ស ហើយរាំងស្ទះដល់កិច្ចការពារដល់អ្នកការពារសិទ្ធិមនុស្សផងដែរ។

**ការវាយតម្លៃភាពប្រថុយប្រថានរបស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា៖** ផ្នែកនេះត្រូវបានបែងចែងជាពីរអនុផ្នែក។ ទស្សនទាននៃសន្តិសុខពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្ស ត្រូវបានលើកមកពិភាក្សាជាសង្ខេប ហើយបន្ទាប់មក ក្នុងអនុផ្នែកទីមួយ («ប្រភេទអ្នកការពារសិទ្ធិមនុស្ស») នឹងធ្វើការគូសបញ្ជាក់ពីការគំរាមកំហែងដែលក្រុមអ្នកការពារសិទ្ធិមនុស្សនានាបានប្រឈម តួយ៉ាងដូចជាតំណាងរាស្ត្រនៃគណបក្សប្រឆាំងមេធាវី អ្នកសារព័ត៌មាន/អ្នកជំនាញការខាងសារព័ត៌មាន សកម្មជនមូលដ្ឋាន សកម្មជនសហជីព សកម្មជនសិទ្ធិ

[1] ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (ក.ឧ.ស), "អ្នកការពារសិទ្ធិមនុស្ស៖ការពារសិទ្ធិក្នុងការការពារសិទ្ធិមនុស្ស" (សលាកប័ត្រលេខ២៩) http://www.ohchr.org/EN/PUBLICATIONSRESOURCES/Pages/FactSheets.aspx

ជីផ្លីជាស្ត្រី បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។ អនុផ្នែកទីពីរ («ការវាយតម្លៃភាពប្រថុយប្រថាន») កំណត់នូវភាពប្រថុយប្រថានដែលក្រុមអ្នកការពារសិទ្ធិមនុស្សបានប្រឈមនៅកម្ពុជា តាមរយៈការសម្លឹងមើលលើការគំរាមកំហែងដែលមាន ដូចបានរៀបរាប់ក្នុងអនុផ្នែកទីមួយហើយនិងភាពរងគ្រោះអាចកើតមានចំពោះការគំរាមកំហែងនោះ។

**សេចក្តីសន្និដ្ឋាននិងអនុសាសន៍៖** ផ្នែកចុងក្រោយនៃរបាយការណ៍នេះផ្តល់ជាការសង្ខេបនៃរបកគំហើញទាំងមូលនិងផ្តល់ជាអនុសាសន៍ជាក់លាក់ដល់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា អង្គការសិទ្ធិមនុស្ស សហគមន៍សិទ្ធិមនុស្សនៅកម្ពុជា និងរដ្ឋាភិបាលដើម្បីធ្វើយ៉ាងណាឲ្យស្ថានភាពសន្តិសុខបច្ចុប្បន្នដែលអ្នកការពារសិទ្ធិមនុស្សបានប្រឈម ឲ្យមានភាពប្រសើរឡើងនៅប្រទេសនេះ។

# សេចក្តីផ្តើម

បើយោងតាមការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស អ្នកការពារសិទ្ធិមនុស្សត្រូវបានផ្តល់និយមន័យថាជាបុគ្គល ក្រុមនិងសរីរាង្គរបស់សង្គមដែលធ្វើការលើកកម្ពស់និងការពារសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋានដែលត្រូវបានគេទទួលស្គាល់ជាសកល។ អ្នកការពារសិទ្ធិមនុស្សធ្វើការដើម្បីលើកកម្ពស់និងការពារសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយព្រមទាំងលើកកម្ពស់ការពារនិងធ្វើឲ្យទទួលបាននូវសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ អ្នកការពារសិទ្ធិមនុស្សក៏ធ្វើការលើកកម្ពស់ និងការពារសិទ្ធិរបស់សមាជិកសហគមន៍ផងដែរដូចជាសហគមន៍ជនជាតិដើមភាគតិចជាដើម។ និយមន័យនេះ មិនគ្របដណ្តប់ចំពោះបុគ្គលឬក្រុមទាំងឡាយណាដែលប្រព្រឹត្ត ឬជម្រុញឲ្យមានអំពើហឹង្សានោះទេ។[2]

ស្ថានភាពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននៅកម្ពុជាដោយរាប់បញ្ចូលទាំងសេរីភាពក្នុងការមានទស្សនៈយោបល់ បញ្ចេញមតិ និងសមាគមផងនោះគឺកំពុងធ្លាក់ចុះយ៉ាងខ្លាំង។ ស្ថានភាពអ្នកការពារសិទ្ធិមនុស្សក៏គួរឲ្យព្រួយបារម្ភផងដែរ។ នៅឆ្នាំ២០១២ អាជ្ញាធរបានបន្តប្រតិកម្មខ្លាំងៗតបតនឹងសកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្ស ដែលរាប់បញ្ចូលទាំងសកម្មជនសិទ្ធិដីធ្លី និងលំនៅដ្ឋាន សហជីព អ្នកសារព័ត៌មាន និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការឃាយឃី គំរាមកំហែង ប្រើប្រាស់អំពើហឹង្សា និងវិធានការច្បាប់ដើម្បីបំបិទសម្លេងអ្នកប្រឆាំងតវ៉ា។ ថ្វីបើតម្រូវដោយច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្សក៏ដោយ កម្ពុជាមិនទាន់មានយន្តការថ្នាក់ជាតិដែលឯករាជ្យត្រូវបានបង្កើតឡើងដើម្បីការពារ និងលើកកម្ពស់សិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សនៅឡើយ។[3] អង្គការមិនមែនរដ្ឋាភិបាលផ្តល់ការគាំទ្រមួយចំនួនដល់អ្នកការពារសិទ្ធិមនុស្សរួមមានជំនួយផ្នែកច្បាប់និងជំនួយមនុស្សធម៌ ប៉ុន្តែដោយសារថាអង្គការមិនមែនរដ្ឋាភិបាលនៅមានកម្រិតផ្នែកសមត្ថភាពនិងធនធាន អាស្រ័យហេតុនេះហើយ ក្នុងករណីបំពានជាច្រើន ជាពិសេសករណីដែលកើតឡើងនៅទីដាច់ស្រយាលពីទីក្រុងភ្នំពេញជំនួយគាំទ្រទាំងនោះស្ទើរតែគ្មានតែម្តង។

ស្ថានភាពសន្តិសុខ និងកម្រិតនៃភាពប្រថុយប្រថានរបស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាត្រូវបានសម្គាល់ថាបានប្រឈមខ្លាំងនៅឆ្នាំ២០១២។ រដ្ឋាភិបាលបានធ្វើការបង្ក្រាបយ៉ាងខ្លាំងដល់ការងារអ្នកការពារសិទ្ធិមនុស្សខណៈដែលការបោះឆ្នោតថ្នាក់ជាតិខិតជិតចូលមកដល់នៅខែកក្កដាឆ្នាំ២០១៣ខាងមុខនេះ។

របាយការណ៍នេះផ្អែកលើការចុះស្រាវជ្រាវផ្ទាល់របស់អង្គការមាត្រា១៩មកកាន់ប្រទេសកម្ពុជា និងផ្អែកលើរបកគំហើញបឋមតាមរយៈកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយអង្គការមាត្រា១៩ និង ម.ស.ម.ក ជាមួយអ្នក

---

[2]ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (ក.ឧ.ស), សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស, (សេចក្តីអធិប្បាយ) http://www.ohchr.org/EN/Issues/SRHRDefenders/Pages/Declaration.aspx

[3]ម.ស.ម.ក, កម្រងវិភាគស្ថាប័ន៖ «ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិនៅកម្ពុជា» (សលាកប័ត្រ) (ខែមិនាឆ្នាំ២០១២) http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=38&id=5

ការពារសិទ្ធិមនុស្ស ព្រមទាំងការស្រាវជ្រាវស៊ីជម្រៅដោយផ្ទាល់របស់ ម.ស.ម.ក។ របាយការណ៍នេះមិនត្រូវបានធ្វើឡើងក្នុងទ្រង់ទ្រាយបែបបរិមាណ ជុំវិញស្ថានភាពសន្តិសុខរបស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជានោះឡើយ ហេតុនេះហើយករណីសិក្សាដែលរៀបរាប់ក្នុងរបាយការណ៍នេះ មិនមានន័យសន្និដ្ឋានរួមចំពោះទម្រង់នៃការគំរាមកំហែងនិងភាពប្រថុយប្រថានដែលអ្នកការពារសិទ្ធិមនុស្សប្រឈមនោះទេ។ ផ្ទុយទៅវិញ ករណីសិក្សាដែលប្រើប្រាស់ក្នុងរបាយការណ៍នេះគ្រាន់តែជាឧទាហរណ៍នៃបរិបទទូទៅមួយនៃភាពប្រថុយប្រថាន និងការគំរាមកំហែង ដោយហេតុថារបាយការណ៍នេះផ្តល់នូវការវិភាគបែបគុណភាពពីស្ថានភាពសន្តិសុខទូទៅ។

គោលបំណងនៃរបាយការណ៍នេះចង់បង្ហាញពីការគំរាមកំហែងផ្នែកសន្តិសុខសំខាន់ៗ ដែលអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាកំពុងប្រឈម និងធ្វើការវិភាគពីកម្រិតទូទៅនៃភាពប្រថុយប្រថានដែលបណ្តាលពីការគំរាមកំហែងទាំងនោះហើយនិងផ្តល់ជាអនុសាសន៍ដើម្បីបញ្ចៀសភាពប្រថុយប្រថាន ព្រមទាំងលើកកម្ពស់សន្តិសុខរបស់អ្នកការពារសិទ្ធិមនុស្សក្នុងប្រទេសនេះ។

# សាវតារ

ថ្វីបើប្រទេសកម្ពុជាធ្លាប់មានប្រវត្តិហឹង្សាពីអតីតកាលក្តី សេដ្ឋកិច្ចនៃប្រទេសនេះបានរីកចំរើនគួរឲ្យកត់សម្គាល់ក្នុងរយៈពេល១០ឆ្នាំមកនេះ ហើយអាត្រានៃភាពក្រីក្រក៏បានធ្លាក់ចុះផងដែរ។[4] ទោះជាយ៉ាងនេះក្តី ដំណើរការនៃវឌ្ឍនភាពនេះគឺមិនត្រូវបានស្វាគមន៍ទាំងស្រុងនោះទេ ដោយសារតែគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាលបានផ្តល់ផលប្រយោជន៍តែចំពោះអភិជនមួយចំនួនតូច ហើយជាញឹកញយតែងប៉ះពាល់ដល់ពលរដ្ឋសាមញ្ញ។ គម្លាតរវាងអ្នកមាននិងអ្នកក្រកើនឡើងជាបន្តបន្ទាប់។[5] អ្នកដែលមានអំណាចបន្តលក់ដីនិងធនធានធម្មជាតិដែលជាញឹកញយខុសច្បាប់ទៅឲ្យក្រុមហ៊ុនឯកជនដែលមានទំនាក់ទំនងជិតស្និត ដើម្បីផលចំណេញខាងសេដ្ឋកិច្ចក្នុងរយៈពេលមួយដ៏ខ្លី តែបន្សល់នូវផលប៉ះពាល់ធ្ងន់ធ្ងរក្នុងរយៈពេលវែងដល់ពលរដ្ឋកម្ពុជា។

ចំណោទសំខាន់មួយនៃបញ្ហាសិទ្ធិមនុស្សនៅកម្ពុជាដែលប៉ះពាល់ខ្លាំងដល់ការងាររបស់អ្នកការពារសិទ្ធិមនុស្សនោះគឺការរឹតបន្តឹងទៅលើគ្រប់ទម្រង់នៃការបញ្ចេញមតិ។ គណបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជា មិនអត់អោនចំពោះការរិះគន់នោះឡើយ ដែលនេះបង្ហាញឲ្យឃើញច្បាស់នូវផលវិបាកពីការបញ្ចេញមតិនិងសេរីភាពក្នុងការទទួលបានព័ត៌មានក្នុងប្រទេសនេះ។ អង្គភាពរបស់រដ្ឋរាប់បញ្ចូលទាំងនគរបាល យោធាតុលាការ និងសូម្បីតែសភាត្រូវបានមន្ត្រីរដ្ឋាភិបាល និងដៃគូអាជីវកម្មប្រើប្រាស់ដើម្បីបំបិទសម្លេងអ្នករិះគន់។

មេដឹកនាំគណបក្សប្រឆាំង គឺលោកសមរង្ស៊ីកំពុងតែនិរទេសខ្លួននៅក្រៅប្រទេស ដោយសារតែការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល១១ឆ្នាំ ហើយក្នុងករណីដែលលោកនឹងត្រឡប់មកកម្ពុជាវិញលោកនឹងអាចត្រូវបានជាប់ពន្ធនាគារ។[6] ក្នុងឆ្នាំ២០១០លោកត្រូវបានគេរកឃើញថាមានពិរុទ្ធភាពក្នុងបទចោទដែលមានចេតនាខាងនយោបាយ ពីបទផ្តល់ព័ត៌មានមិនពិត ក្លែងឯកសារ បំផ្លាញទ្រព្យសម្បត្តិ និងញុះញង់ឲ្យមានការរើសអើង។[7] ក្នុងឆ្នាំ២០១២ឈ្មោះរបស់លោកសមរង្ស៊ីត្រូវបានគេលុបចេញពីបញ្ជីបោះឆ្នោតដោយសារតែបទចោទ

---

[4]ធនាគារពិភពលោក, «ទិដ្ឋភាពប្រទេសៈកម្ពុជា» (ឆ្នាំ២០១១) http://www.worldbank.org/en/country/cambodia/overview

[5]វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍សង្គម, «ការត្រួតពិនិត្យមើលលើការអភិវឌ្ឍន៍ប្រចាំឆ្នាំ ២០១១-២០១២» (២០១២) http://www.cdri.org.kh/webdata/download/adr/adr07e1112.pdf

[6]លោក សមរង្ស៊ីកំពុងប្រឈមការជាប់ពន្ធនាគាររយៈពេល១១ឆ្នាំដោយសារការផ្តន្ទាទោសពីបទល្មើសចំនួនបីផ្សេងៗគ្នា។ ការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារវែងបំផុត គឺ១០ឆ្នាំត្រូវបានគេសម្រេចកាលពីឆ្នាំមុនបន្ទាប់ពីលោកត្រូវបានគេកាត់ទោសក្នុងករណីពីរផ្សេងទៀត ពាក់ព័ន្ធនឹងការតវ៉ាដែលលោកបានដឹកនាំកាលពីឆ្នាំ២០០៩ប្រឆាំងនឹងការរំលោភយកដីរបស់វៀតណាម។ ការផ្តន្ទាទោសនោះត្រូវបានគេសម្រាលមកត្រឹម៧ឆ្នាំ កាលពីខែកញ្ញា ឆ្នាំ២០១១។ អង្គការលីកាដូ, «ការបំភ័ន្តភ្នែកនៃការអភិវឌ្ឍន៍៖ការវាយបកផ្នែកច្បាប់នៅកម្ពុជាចំពោះសេរីភាពក្នុងការបញ្ចេញមតិ» (របាយការណ៍) (ខែតុលាឆ្នាំ២០១១http://www.licadho-cambodia.org/reports/files/162LICADHOReport-LegislativeAssaultFreedomExpression2011-English.pdf

[7]សូមមើលឯកសាររបស់ ម.ស.ម.ក, «ការវិភាគពីមូលហេតុផ្នែកច្បាប់ក្នុងការផ្តន្ទាទោស និងភាពយុត្តិធម៌នៃនិតិវិធីតុលាការ ក្នុងករណីព្រហ្មទណ្ឌប្រឆាំងមកលើលោកសមរង្ស៊ី» (ខែកុម្ភៈ ឆ្នាំ២០១១) http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=24&id=5

ព្រហ្មទណ្ឌប្រឆាំងមកលើរូបលោក នេះមានន័យថាលោកមិនត្រូវបានអនុញ្ញាតឲ្យចូលរួមជាផ្លូវការសម្រាប់ការបោះឆ្នោតថ្នាក់ជាតិនាខែកក្កដា ឆ្នាំ២០១៣ខាងមុខនេះឡើយ។[8]

សារព័ត៌មាននៅកម្ពុជាត្រូវបានគេត្រួតពិនិត្យយ៉ាងខ្លាំង ដើម្បីបំពេញចិត្តដល់គណបក្សប្រជាជនកម្ពុជា។ គ្រប់បណ្តាស្ថានីយទូរទស្សន៍ និងស្ទើរតែគ្រប់ស្ថានីយវិទ្យុ និងកាសែតភាគច្រើនឋិតក្រោមការកាន់កាប់ ឬគ្រប់គ្រងដោយបក្សកាន់អំណាច ឬបុគ្គលដែលមានទំនាក់ទំនងនឹងបក្សកាន់អំណាច[9]ដែលនេះធានាដល់ការកាន់កាប់របស់រដ្ឋាភិបាលក្នុងការផ្សព្វផ្សាយព័ត៌មានលើសលុបជាងខាងប្រឆាំង។[10]

ចាប់តាំងពីឆ្នាំ២០០០មក ពលរដ្ឋប្រមាណ៧០០.០០០នាក់ ត្រូវបានគេប៉ាន់ស្មានថា ត្រូវបានគេដកហូតដីធ្លី ឬត្រូវបានរងផលប៉ះពាល់ ដោយសារតែរដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ច[11]ដែលជាការផ្តល់កម្មសិទ្ធិក្នុងរយៈពេលវែង ដែលនេះអនុញ្ញាតឲ្យសម្បទានិក ធ្វើការឈូសឆាយដីធ្លីដើម្បីអភិវឌ្ឍឧស្សាហកម្មកសិកម្ម។ សមាគមការពារសិទ្ធិមនុស្សនិងការអភិវឌ្ឍន៍នៅកម្ពុជា (អង្គការអាដហុក) ដែលមានការិយាល័យតាមបណ្តាខេត្តចំនួន២៣ក្នុងចំណោមខេត្តក្រុងទាំង២៤ នៃប្រទេសកម្ពុជាបានរាយការណ៍ឲ្យដឹងថាដីសម្បទានចំនួន១០០ត្រូវបានគេផ្តល់សម្បទានក្នុងឆ្នាំ២០១២ដែលប្រៀបនឹងឆ្នាំ២០១១មានត្រឹម៦៨ប៉ុណ្ណោះ។អង្គការអាដហុកក៏បានរាយការណ៍ផងដែរថាក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ដីសម្បទានចំនួន៣២ ត្រូវបានគេផ្តល់សម្បទាន បើទោះជានាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្អាកជាបណ្តោះអាសន្នចំពោះការផ្តល់ដីសម្បទាន កាលពីខែឧសភាឆ្នាំ២០១២នេះហើយក៏ដោយ។[12] ទំហំដីសម្បទានសេដ្ឋកិច្ច មានទំហំប្រមាណជា២សែនហិកតាប្រហាក់ប្រហែលជា១០%នៃផ្ទៃដីសរុប។[13]

គោលនយោបាយសេដ្ឋកិច្ចនេះ បានបង្កជាបញ្ហាជាច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយហើយនេះជាប្រភពនាំឲ្យមានបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា។ ការងាររបស់អ្នកការពារសិទ្ធិមនុស្សភាគច្រើន គឺផ្សារភ្ជាប់នឹងការការពារសិទ្ធិដីធ្លីតួយ៉ាង ដូចជាអ្នកសារព័ត៌មានសកម្មជន និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ដែលតែងត្រូវបានគេដៅមុខសញ្ញានៅពេលដែលពួកគាត់បានចេញមុខនិយាយតវ៉ាប្រឆាំងការរំលោភដីធ្លី និងការបណ្តេញ

---

[8] «លោកសមរង្ស៊ី ត្រូវបានគេលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត», កាសែតឌឹខេមបូឌៀដេលី (ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២) http://www.cambodiadaily.com/news/sam-rainsy-deleted-from-voter-list-for-election-5229/

[9] ខុមហ្វ្រែល «របាយការណ៍ឆ្នាំ២០០៩៖ លទ្ធិប្រជាធិបតេយ្យការបោះឆ្នោតនិងការកែទម្រង់នៅកម្ពុជា» (ខែកុម្ភៈ ឆ្នាំ២០១០) http://www.comfrel.org/eng/components/com_mypublications/files/8978541265785063Comfrel_Cambodia_Democratic_Reform_2009_En_Final.pdf

[10] ម.ស.ម.ក, «សារព័ត៌មានបែបទំនើបនិងការលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា» (របាយការណ៍) (ខែកក្កដា ឆ្នាំ២០១២) ទំព័រ៦ http://www.cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=79&id=5

[11] «កាត់ដីធ្លីនៅកម្ពុជា», កាសែតឌឹខេមបូឌៀដេលី (ថ្ងៃទី១០-១១ខែមិនា ឆ្នាំ២០១២) (អត្ថបទចុងសប្តាហ៍លេខ៤)

[12] «ការចាប់ខ្លួនសកម្មជនដីធ្លីបានកើនឡើងទ្វេដងសម្រាប់ឆ្នាំ២០១២», កាសែតឌឹខេមបូឌៀដេលី (ថ្ងៃទី២៤ខែមករាឆ្នាំ២០១៣) ទំព័រទី១

[13] ដូចខាងលើ។

ចេញទាំងបង្ខំ។ សម្រាប់តែឆ្នាំ២០១២ប៉ុណ្ណោះ យ៉ាងហោចណាស់ សកម្មជនចំនួន២០១នាក់ត្រូវបានគេចាប់ខ្លួន ដែលតួលេខនេះបានកើនទ្វេដងបើធៀបនឹងតួលេខចាប់ខ្លួនក្នុងឆ្នាំ២០១១។[14]

ស្របពេលដែលការបំពានសិទ្ធិដីធ្លីបានបណ្តាលឲ្យមានបាតុកម្មទ្រង់ទ្រាយធំជាច្រើន ការមិនគោរពលក្ខខណ្ឌការងារដល់កម្មករ ក៏ជាប្រភពសំខាន់មួយទៀតនៃភាពចលាចលក្នុងសង្គមផងដែរ។ ឧស្សាហកម្មកាត់ដេរ ជាវិស័យមួយដែលរីកដុះដាលយ៉ាងខ្លាំងនៅកម្ពុជា។ វិស័យនេះគ្របដណ្តប់ស្ទើរតែ៩០%នៃការនាំចេញទៅក្រៅប្រទេស និងផ្តល់ការងារដល់ពលរដ្ឋប្រមាណជា ៣០០.០០០នាក់។[15] វិស័យកាត់ដេរ ជាផ្នែកសំខាន់មួយនៃវិនិយោគទុនបរទេសព្រមទាំងជាប្រភពផ្តល់ការងារជាពិសេសសម្រាប់ស្ត្រីផងដែរ។ ទោះជាយ៉ាងនេះក្តីក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះកម្មកររោងចក្រកាត់ដេរបានចេញមុខតវ៉ាជាច្រើន ប្រឆាំងនឹងការផ្តល់ប្រាក់ឈ្នួលទាប លក្ខខណ្ឌការងារ និងការខកខានរបស់ថ្នាក់គ្រប់គ្រងរោងចក្រក្នុងការបង់ផលកម្រៃដែលកម្មករត្រូវទទួលបាន។ បញ្ហានេះបានបណ្តាលឲ្យមានការបង្ក្រាបដល់សេរីភាពក្នុងការប្រជុំនិងសមាគមរបស់កម្មករ។ កម្មករ ជាញឹកញយត្រូវបានគេដាក់ពិន័យដោយសារការចូលជាសមាជិកជាមួយសហជីពឬការចូលរួមធ្វើបាតុកម្ម ហើយប្រធានសហជីពវិញ ជាទូទៅតែងរងនូវការគំរាមកំហែង និងការឃាយី។[16]

ស្រដៀងនឹងការបំបិទសិទ្ធសេរីភាពបញ្ចេញមតិនោះសេរីភាពខាងការប្រជុំ ក៏ត្រូវបានគេបង្ក្រាបផងដែរ។ ការកើនឡើងនូវការប្រមូលផ្តុំក្នុងចំណោមសកម្មជនសហគមន៍ និងកម្មករ ក្នុងការរៀបចំបាតុកម្មជាសាធារណៈបានធ្វើឲ្យមានការឆ្លើយតបពីសំណាក់អាជ្ញាធរទាំងកម្លាំងបាយ។ បាតុកម្មដោយសន្តិវិធី បានប្រែក្លាយជាការប៉ះទង្គិចគ្នាទាំងហឹង្សាជាមួយនឹងនគរបាល និងនគរបាលយោធា ហើយចាប់តាំងពីឆ្នាំ២០១២មកមានឧបទ្ទវហេតុជាច្រើនបានកើតឡើងដែលអាជ្ញាធរបានបាញ់រះមកលើសកម្មជន។ ក្នុងករណីមួយនៅឆ្នាំ២០១២ យុទ្ធសាស្ត្រនោះបានបណ្តាលឲ្យកុមារម្នាក់អាយុ១៤ឆ្នាំ ឈ្មោះ ហេង ចន្ថា នៅខេត្តក្រចេះត្រូវបានបាញ់សម្លាប់ ក្នុងខណៈដែលក្មេងនោះមានវត្តមាននៅទីកើតហេតុ នៅពេលដែលយោធាបានបាញ់រះលើពលរដ្ឋដែលគេបណ្តេញចេញហើយបដិសេធមិនព្រមចេញពីដីនោះ។[17]

ថ្វីត្បិតតែសង្គមស៊ីវិលនៅកម្ពុជាហាក់ដូចជាមានសភាពសកម្ម និងចូលរួមយ៉ាងណាក៏ដោយ ស្ថានភាពសិទ្ធិមនុស្សជាទូទៅ ដែលបង្កជាផលលំបាកដល់មជ្ឈដ្ឋានសន្តិសុខរបស់អ្នកការពារសិទ្ធិមនុស្សផងនោះត្រូវ

---

[14]ដូចខាងលើ។

[15]រោងចក្រល្អប្រសើរនៅកម្ពុជា, «កម្រងទិន្នន័យឧស្សាហកម្មឆ្នាំ២០១១» (ខែមិនា ឆ្នាំ២០១១) http://www.betterfactories.org/content/documents/Industry%20Data%20Sheet%202011_March2011%20(EN).pdf

[16]យុទ្ធនាការសំលៀកបំពាក់ស្អាតស្អំនិងមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍, «រយៈពេល១០ឆ្នាំនៃគម្រោងរោងចក្រល្អប្រសើរនៅកម្ពុជា» (របាយការណ៍រួម) (ខែសីហាឆ្នាំ២០១២) ទំព័រទី១៦។

[17]«ក្មេងស្រីជំទង់ម្នាក់ត្រូវបានកងកម្លាំងសន្តិសុខបាញ់សម្លាក់ក្នុងពេលបណ្តេញចេញពីដីធ្លី», កាសែតឌឹភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២)http://www.phnompenhpost.com/2012051756224/National/girl-killed-in-eviction.html

បានក្រុមសិទ្ធិមនុស្សទទួលស្គាល់ថាមានសភាពដុនដាបខ្លាំងក្នុងឆ្នាំ២០១២។[18] ដោយរាប់ទាំងករណីក្មេងស្រីអាយុ១៤ឆ្នាំនៅខេត្តក្រចេះនោះ ករណីឃាតកម្មចំនួន៣បានកើតឡើងសម្រាប់តែក្នុងឆ្នាំ២០១២ ដែលជាលទ្ធផលនៃការតបតពីសំណាក់រដ្ឋាភិបាលចំពោះភាពសកម្ម និងសេរីភាពក្នុងការបញ្ចេញមតិ។ កាលពីថ្ងៃទី២៦ខែមេសា ឆ្នាំ២០១២ លោក ឈុត វុទ្ធី ដែលជាសកម្មជនបរិស្ថានដ៏ល្បីឈ្មោះ និងជាប្រធានអង្គការការពារធនធានធម្មជាតិ ត្រូវបាននគរបាលយោធាបាញ់សម្លាប់ ខណៈពេលដែលរូបលោកកំពុងធ្វើការចុះអង្កេតការកាប់ព្រៃឈើខុសច្បាប់ នៅខេត្តកោះកុង។ កាលពីថ្ងៃទី១១ខែកញ្ញា ឆ្នាំ២០១២ លោក ហង្ស សេរីឧត្តម ដែលជាអ្នកកាសែតឲ្យសារព័ត៌មានក្នុងស្រុកមួយនៅខេត្តរតនគីរីឈ្មោះថា វីរជនខ្មែរដែលជាញឹកញយបានធ្វើព័ត៌មានរាយការណ៍ជុំវិញការកាប់ព្រៃឈើខុសច្បាប់ និងអ្នកជាប់ពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាលនោះ[19]ត្រូវបានគេរកឃើញសាកសពរូបលោកក្នុងឡានរបស់ខ្លួន។ គ្មាននរណាម្នាក់ត្រូវបានចាប់ខ្លួន និងកាត់ទោសចំពោះឃាតកម្មលើរូបលោក ឈុត វុទ្ធី ឬក្មេងស្រី ហេង ចន្ថានោះឡើយ។ មនុស្សពីរនាក់ត្រូវបានគេចាប់ខ្លួន និងចោទប្រកាន់ពីបទឃាតកម្មលើរូបលោក ហង្ស សេរីឧត្តម ប៉ុន្តែករណីឃាតកម្មនេះ ត្រូវបានគេជឿជាក់ថាមានមនុស្សពាក់ព័ន្ធច្រើនជាងនេះទៅទៀត។[20] ការស៊ើបអង្កេតត្រូវបានតុលាការខេត្តរតនគីរីស៊ើបរើឡើងវិញក្នុងខែមេសាឆ្នាំ២០១៣ ដោយតុលាការអះអាងថាព័ត៌មានសំខាន់ត្រូវបានគេមើលរំលង។[21] នៅប្រទេសកម្ពុជា ការបំពានសិទ្ធិអ្នកការពារសិទ្ធិមនុស្ស ជាទូទៅត្រូវបានបំបាំងដោយពពកនៃនិទ្ទណ្ឌភាព។

ប្រទេសកម្ពុជាមានអង្គភាពសិទ្ធិមនុស្សថ្នាក់ជាតិចំនួនបីគឺគណៈកម្មការសិទ្ធិមនុស្សរដ្ឋសភា គណៈកម្មការសិទ្ធិមនុស្សព្រឹទ្ធសភា និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ ទោះជាយ៉ាងនេះក្តី អង្គភាពទាំងបីនេះមិនបានបំពេញតាមលក្ខខណ្ឌដែលបានចែងក្នុងគោលការណ៍ទីក្រុងប៉ារីស (នឹងត្រូវបានពន្យល់បន្ថែមនៅផ្នែកខាងក្រោម) ហើយត្រូវបានគេយល់ថាមិនមានភាពស្វយ័តគ្រប់គ្រាន់ក្នុងការដាក់ឲ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះការបំពានសិទ្ធិមនុស្សនោះឡើយ។[22]

---

[18] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, «របាយការណ៍ពិភពលោកឆ្នាំ២០១៣» (ខែមករាឆ្នាំ២០១៣) (ជំពូកប្រទេសៈកម្ពុជា )http://www.hrw.org/world-report/2013/country-chapters/cambodia

[19]«អ្នកកាសែតដែលរាយការណ៍រឿងកាប់ព្រៃឈើត្រូវបានគេរកឃើញសាកសព», កាសែតឌឹភ្នំពេញប៉ុស្ដិ៍ (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១២) shttp://www.phnompenhpost.com/2012091258652/National/stringer-who-reported-on-logging-found-dead.html

[20]«ការស៊ើបអង្កេតលើករណីឃាតកម្មចំពោះអ្នកកាសែតហង្ស សេរីឧត្តម ត្រូវបានបញ្ចប់ហើយ» កាសែតឌឹភ្នំពេញប៉ុស្ដិ៍ (ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២) http://www.phnompenhpost.com/index.php/2012112259882/National-news/probe-into-murder-of-journalist-hang-serei-oudom-closes.html

[21]វិទ្យុអាស៊ីសេរី, «តុលាការកម្ពុជាបញ្ជាឲ្យស្វែងរកភស្តុតាងថ្មីជុំវិញករណីឃាតកម្មលើអ្នកកាសែត» (ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៣) http://www.rfa.org/english/news/cambodia/probe-04302013192504.html

[22]ម.ស.ម.ក, «កម្រងឯកសារស្ថាប័នៈ អង្គភាពសិទ្ធិមនុស្សថ្នាក់ជាតិនៅកម្ពុជា» (សលាកប័ត្រ) (ខែមីនា ឆ្នាំ២០១២) http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=38&id=5

# បទដ្ឋានថ្នាក់អន្តរជាតិ និងតំបន់

អ្នកការពារសិទ្ធិមនុស្សកម្ពុជា ត្រូវបានការពារដោយច្បាប់ជាតិនិងអន្តរជាតិ ជាពិសេសពាក់ព័ន្ធសិទ្ធិសេរីភាពក្នុងការប្រកាន់មតិ និងបញ្ចេញមតិនិងសិទ្ធិក្នុងការប្រជុំ និងចូលរួមជាសមាគមផងដែរ ដែលទាំងនេះជាខែលការពារសំខាន់សម្រាប់បំពេញការងាររបស់ពួកគាត់។ សេចក្ដីប្រកាសថ្នាក់តំបន់ បានផ្ដល់ការគាំពារតិចតួចដល់សិទ្ធិទាំងអស់នេះ ខណៈដែលបទបញ្ញត្តជាតិដែលមានលក្ខណៈទូទៅមិនច្បាស់លាស់ ត្រូវបានគេយកមកប្រើប្រាស់ដើម្បីរឹតបន្តឹងដល់ការងារអ្នកការពារសិទ្ធិមនុស្ស ហើយបានឈានដល់ការឃាយឺចំពោះពួកគាត់ផងដែរ។

## បទដ្ឋានអន្តរជាតិ

មកទល់នឹងបច្ចុប្បន្ននេះ កម្ពុជាបានផ្ដល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិសិទ្ធិមនុស្សចំនួន៧ក្នុងចំណោមកតិកាសញ្ញា៩សំខាន់ៗ៖

- កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ
- កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- អនុសញ្ញាអន្តរជាតិស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍
- អនុសញ្ញាស្ដីពីការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងពិធីសារបន្ថែម
- អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបនិងពិធីសារបន្ថែម
- អនុសញ្ញាស្ដីពីសិទ្ធិកុមារនិងពិធីសារបន្ថែម
- អនុសញ្ញាស្ដីពីសិទ្ធិជនពិការ

ប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាស្ដីពី សិទ្ធិការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងអនុសញ្ញាស្ដីពីការបាត់ខ្លួនដោយបង្ខំ ផងដែរ ប៉ុន្តែមិនទាន់បានធ្វើសច្ចាប័ននៅឡើយទេ។

សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ថ្វីត្បិតតែមិនមានលក្ខណៈចាប់ចងដូចច្បាប់ក៏បានផ្ដល់ជាមូលដ្ឋានសម្រាប់សន្ធិសញ្ញាសិទ្ធិមនុស្សដទៃទៀត ដូចជាកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ក.អ.ស.ព.ន)ជាដើម។ មាត្រា ១៩ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សបានចែងថា៖

*ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិ ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួលនិងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែនទឹកដី ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។*[23]

ក្នុងឆ្នាំ១៩៩២ កម្ពុជាបានទទួលស្គាល់ ក.អ.ស.ព.ន ដែលក្នុងនោះផ្ទុកនូវកាតព្វកិច្ចរបស់រដ្ឋភាគីក្នុងការលើកកម្ពស់ការគោរពជាសកល និងធ្វើការតាមដានស្ថានភាពសិទ្ធិមនុស្ស និងសេរីភាព។ មាត្រា ១៩នៃ ក.អ.ស.ព.ន ធានាដល់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ៖[24]

១.ជនគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ ដោយគ្មានការជ្រៀតជ្រែក។

២.ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួលនិងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្ប :ក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន។

សេរីភាពប្រជុំដោយសន្តិវិធី និងសិទ្ធិចូលរួមជាសមាគម ត្រូវបានធានាក្រោមមាត្រា២១និងមាត្រា២២នៃ ក.អ.ស.ព.ន ផងដែរ។[25]

កម្ពុជាបានចុះហត្ថលេខា ប៉ុន្តែមិនទាន់បានផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃ ក.អ.ស.ព.ន នៅឡើយ។ ការផ្តល់សច្ចាប័នដល់ពិធីសារបន្ថែមនេះ នឹងអនុញ្ញាតឲ្យគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិមានសមត្ថកិច្ចក្នុងការទទួលយកបណ្តឹងពីបុគ្គលគ្រប់រូប ពាក់ព័ន្ធការបំពេញតាមកាតព្វកិច្ចចែងក្នុង ក.អ.ស.ព.ន របស់ប្រទេសកម្ពុជា។

ផ្សារភ្ជាប់នឹងសារៈសំខាន់នៃការងាររបស់អ្នកការពារសិទ្ធិមនុស្សកាលពីឆ្នាំ១៩៩៨ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តទៅលើសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងសរីរាង្គរបស់សង្គមក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានគេទទួលស្គាល់ជាសកល។ សេចក្តីប្រកាសនោះត្រូវបានគេស្គាល់ថាជា សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស។ ក្នុងឆ្នាំ២០០០ គណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកការងារសិទ្ធិមនុស្សបានស្នើដល់អគ្គលេខាធិការឲ្យតែងតាំងអ្នកតំណាងពិសេសស្តីពីអ្នកការពារសិទ្ធិមនុស្ស ដើម្បីធ្វើការតាមដាន និងគាំទ្រដល់ការអនុវត្តន៍សេច

[23]សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់មហាសន្និបាត ២១៧អេ (III) ឯកសាររបស់អង្គការសហប្រជាជាតិលេខ អេ/៨១០ ៧១ (ឆ្នាំ១៩៤៨)

[24]ក.អ.ស.ព.ន របស់អង្គការសហប្រជាជាតិ, សេចក្តីសម្រេចរបស់មហាសន្និបាត២២០០អេ (XXI), ឯកសាររបស់អង្គការសហប្រជាជាតិ លេខ អេ/៦៣១៦ (ឆ្នាំ១៩៦៦) ចូលជាធរមាន (ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦)

[25]ដូចខាងលើ។

ក្តីប្រកាសនេះ។[26] សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្សគូសបញ្ជាក់ពីសារៈសំខាន់ដែលត្រូវបានគេទទួលស្គាល់ទូទៅនៃការងាររបស់អ្នកការពារសិទ្ធិមនុស្ស និងធានាដល់កិច្ចគាំពារនានា។ ថ្វីបើសេចក្តីប្រកាសមិនមានលក្ខណៈចាប់ចងដូចច្បាប់ក្តី សេចក្តីប្រកាសនេះផ្ទុកនូវគោលការណ៍ជាច្រើនដែលដកស្រង់ចេញពីឯកសារច្បាប់ដូចជា ក.អ.ស.ព.ន ហើយបានតាក់តែងក្នុងបរិបទការងារអ្នកការពារសិទ្ធិមនុស្ស។ លើសនេះទៀត សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្សនេះ ត្រូវបានមហាសន្និបាតអនុម័តជាឯកច្ឆ័ន ហេតុដូចនេះហើយសេចក្តីប្រកាសនេះបានទទួលការប្តេជ្ញាចិត្តយ៉ាងខ្លាំងពីសំណាក់រដ្ឋភាគីដើម្បីអនុវត្តតាម។[27] សេចក្តីប្រកាសនេះបានគូសបញ្ជាក់នូវទំនួលខុសត្រូវរបស់រដ្ឋភាគីក្នុងការការពារសិទ្ធិមនុស្សនិងអ្នកការពារសិទ្ធិមនុស្ស ប៉ុន្តែក៏អំពាវនាវដល់បុគ្គលគ្រប់រូបឲ្យបំពេញតួនាទីរបស់ខ្លួនជាអ្នកការពារសិទ្ធិមនុស្សផងដែរ។

មាត្រា ១ មាត្រា ៥-៩ និងមាត្រា ១១-១៣ នៃសេចក្តីប្រកាសស្តីអំពីអ្នកការពារសិទ្ធិមនុស្ស បានចែងពីកិច្ចគាំពារជាក់លាក់ដល់អ្នកការពារសិទ្ធិមនុស្ស ក្នុងនោះរាប់បញ្ចូលទាំងសិទ្ធិ៖ ក្នុងការស្វែងរកការការពារ និងការទទួលបាននូវសិទ្ធិមនុស្សនៅកម្រិតជាតិ និងអន្តរជាតិ ធ្វើការងារសិទ្ធិមនុស្សដោយផ្ទាល់ និងចូលរួមជាសមាគមជាមួយអ្នកដទៃ បង្កើតសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ជួបប្រជុំ ឬធ្វើការប្រមូលផ្តុំដោយសន្តិវិធី ស្វែងរក ទទួលនិងផ្ទុកព័ត៌មានពាក់ព័ន្ធសិទ្ធិមនុស្ស ដាក់ពាក្យបណ្តឹងអំពីគោលនយោបាយជាតិ និងដាក់សំណើរទៅកាន់អង្គភាពរបស់រដ្ឋាភិបាលដើម្បីឲ្យការបំពេញភារកិច្ចមានភាពប្រសើរឡើង ផ្តល់ជំនួយផ្នែកច្បាប់ក្នុងការការពារសិទ្ធិមនុស្ស អាចធ្វើការទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអន្តររដ្ឋាភិបាល និងទទួលបានការគាំពារប្រកបដោយប្រសិទ្ធិភាពតាមច្បាប់ជាតិ ក្នុងការតវ៉ាប្រឆាំងតាមរយៈមធ្យោបាយដោយសន្តិវិធីចំពោះទង្វើ ឬការខកខានរបស់រដ្ឋដែលបង្កឲ្យមានការបំពានសិទ្ធិមនុស្ស។[28]

សេចក្តីប្រកាសស្តីអំពីអ្នកការពារសិទ្ធិមនុស្ស បានរំឭកអំពីកាតព្វកិច្ចរបស់រដ្ឋក្នុងការធានាដល់ការបង្កើត និងធ្វើឲ្យប្រសើរឡើងនៃស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិដែលឯករាជ្យ ដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្ស និងសេរីភាព។ ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិត្រូវគេយល់ថាជា «ខែលការពារជាសាធារណៈដល់អ្នកការពារសិទ្ធិមនុស្ស»។[29] ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ ជាអង្គភាពរបស់រដ្ឋដែលមានអាណត្តិធម្មនុញ្ញ និង/ឬចែងដោយច្បាប់ដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។ ស្ថាប័ននេះជាខ្នែងរបស់រដ្ឋ ហើយត្រូវបានទទួលការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសំណាក់រដ្ឋផងដែរ ហើយលក្ខណៈសំខាន់បំផុតរបស់ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិនេះ គឺ

---

[26]ក.ឧ.ស, «អ្នកការពារសិទ្ធិមនុស្ស៖ ការពារសិទ្ធិក្នុងការការពារសិទ្ធិមនុស្ស» (សលាកប័ត្រលេខ២៩) http://www.ohchr.org/EN/PUBLICATIONSRESOURCES/Pages/FactSheets.aspx

[27]សេចក្តីសម្រេចរបស់មហាសន្និបាត លេខ A/RES/53/144 បានអនុម័តសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស http://www.ohchr.org/EN/Issues/SRHRDefenders/Pages/Declaration.aspx

[28]ក.ឧ.ស, «អ្នកការពារសិទ្ធិមនុស្ស៖ ការពារសិទ្ធិក្នុងការការពារសិទ្ធិមនុស្ស» (សេចក្តីអធិប្បាយ) http://www.ohchr.org/EN/Issues/SRHRDefenders/Pages/Declaration.aspx

[29]បណ្តាញអង្គការអាស៊ីស្តីពីស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ (អាននី), «របាយការណ៍របស់អាននីស្តីពីការបំពេញភារកិច្ច និងការបង្កើតឡើងនូវស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិនៅអាស៊ីឆ្នាំ២០១២» (ប្រទេសថៃឡង់ដ៍ ឆ្នាំ២០១២) ទំព័រទី១៥ http://www.forum-asia.org/?p=15570

ស្វ័យយ័តភាពពីរដ្ឋ។[30] នៅខែធ្នូ ឆ្នាំ១៩៩៣ មហាសន្និបាតរបស់អង្គការសហប្រជាជាតិ បានអនុម័តគោលការណ៍ទីក្រុងប៉ារីស តាមរយៈសេចក្តីសម្រេចមួយដែលកំណត់ពីបទដ្ឋានដែលស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិនេះត្រូវអនុលោមតាម។[31] *ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិទូទាំងពិភពលោកត្រូវបានគេផ្តល់ការវាយតម្លៃគុណភាពទៅតាមកម្រិតផ្សេងៗនៃស្ថានភាពដែលស្ថាប័នទាំងនោះបានអនុលោមតាមគោលការណ៍ទីក្រុងប៉ារីស។*[32] តួនាទីរបស់ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ រឹតតែសំខាន់បំផុតនៅតំបន់អាស៊ីដែលប្រទេសជាច្រើនបានប្រឈមនឹងស្ថានភាពសិទ្ធិមនុស្សធ្ងន់ធ្ងរ។[33]

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានអនុម័តជាឯកច្ឆ័នលើ «ការការពារអ្នកការពារសិទ្ធិមនុស្ស» (អេ/ក.ស.អ.ស.ប/២២/អិល.១៣)។ សេចក្តីសម្រេចជាប្រវត្តិសាស្រ្តនេះបានអំពាវនាវដល់បណ្តារដ្ឋភាគីឲ្យបង្កនូវមជ្ឈដ្ឋានល្អសម្រាប់ការងារសិទ្ធិមនុស្ស។ សេចក្តីសម្រេចនេះតម្រូវឲ្យរដ្ឋភាគីធានាថា «ការបញ្ចេញទស្សនយោបល់គួរត្រូវអាចធ្វើបានដោយសន្តិវិធី» ហើយច្បាប់មិន «រារាំងដល់ការដែលមន្រ្តីសាធារណៈត្រូវមានទំនួលខុសត្រូវនោះឡើយ»។

ការលើកកម្ពស់ការយល់ដឹងជាអន្តរជាតិ ជុំវិញការដើរតួយ៉ាងសំខាន់របស់អ្នកការពារសិទ្ធិមនុស្សបានរីកដុះដាលច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ គណៈកម្មការអន្តរអាមេរិកកាំងស្តីអំពីសិទ្ធិមនុស្សបានថ្លែងថា «អ្នកការពារសិទ្ធិមនុស្សបានបំពេញភារកិច្ចស្នូលក្នុងការការពារសិទ្ធិរបស់ពលរដ្ឋគ្រប់រូប។ ក្នុងន័យនេះការគាំពារដល់អ្នកការពារសិទ្ធិមនុស្សរឹតតែសំខាន់បំផុត»។[34] សហភាពអឺរ៉ុប បានអនុម័តនូវសេចក្តីណែនាំស្តីអំពីអ្នកការពារសិទ្ធិមនុស្សកាលពីខែមិថុនា ឆ្នាំ២០០៤ ដើម្បីផ្តល់ជាគន្លឹះដល់វិធានការរបស់សហភាពអឺរ៉ុបពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្សនៅប្រទេសដែលមិនមែនក្នុងសហភាពអឺរ៉ុប។[35] សេចក្តីសម្រេចរបស់សភាសហ

---

[30]ក.ឧ.ស របស់អង្គការសហប្រជាជាតិ, «ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ៖ ប្រវត្តិ គោលការណ៍ តួនាទី និងការទទួលខុសត្រូវ» (ទីក្រុងញូយ៉ក និងហ្សឺណែវឆ្នាំ២០១០) ទំព័រទី១៣ http://www.ohchr.org/Documents/Publications/PTS-4Rev1-NHRI_en.pdf

[31]មហាសន្និបាតរបស់អង្គការសហប្រជាជាតិ, សេចក្តីសម្រេចលេខ៤៨/១៣៤ (ថ្ងៃទី២០ខែធ្នូ ឆ្នាំ១៩៩៣) ឯកសាររបស់អង្គការសហប្រជាជាតិលេខ A/RES/48/134
http://www.un.org/documents/ga/res/48/a48r134.htm

[32]អនុគណៈកម្មការ ស្តីពីការវាយតម្លៃគុណភាព (អេស.ស៊ី.អេ) នៃគណៈកម្មាធិការសម្របសម្រួលអន្តរជាតិរបស់ស្ថាប័នជាតិ ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស មានអណត្តិត្រួតពិនិត្យឡើងវិញនិងវិភាគការវាយតម្លៃគុណភាពនៃការអនុវត្តន៍របស់ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ និងផ្តល់ជាអនុសាសន៍ដល់សមាជិកការិយាល័យក្នុងការបំពេញតាមលក្ខខណ្ឌនៃគោលការណ៍ទីក្រុងប៉ារីស។ អេស.ស៊ី.អេ មានសមាសភាគ «ថ្នាក់អេ» ដែលផ្តល់ការវាយតម្លៃគុណភាពនៃស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិសម្រាប់តំបន់ទាំងបួន ពោលគឺអាហ្វ្រិចអាមេរិកកាំង អាស៊ីប៉ាស៊ីហ្វិច និងអឺរ៉ុប។

[33]បណ្តាញអង្គការអាស៊ីស្តីពីស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ (អាននី), «របាយការណ៍របស់អាននីស្តីពីការបំពេញភារកិច្ច និងការបង្កើតឡើងនូវស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិនៅអាស៊ីឆ្នាំ២០១២» (ប្រទេសថៃឡង់ដ៍ ឆ្នាំ២០១២) ទំព័រទី៨ http://www.forum-asia.org/?p=15570

[34]គណៈកម្មការអន្តរអាមេរិកាំងស្តីពីសិទ្ធិមនុស្ស (គ.អ.អ.ស), «គ.អ.អ.ស ថ្កោលទោសលើករណីធ្វើឃាត ម៉ារីយ៉ា ដេល កាមែនផ្ល័រហ្សនៅប្រទេសកូឡុំប៊ី» (សេចក្តីថ្លែងការណ៍ ៦/០២) (ទីក្រុងវ៉ាស៊ីនតោន ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០២)
http://www.cidh.org/Comunicados/English/2002/Press6.02.htm

[35]សូមមើលសេចក្តីណែនាំរបស់សហភាពអឺរ៉ុបស្តីពីអ្នកការពារសិទ្ធិមនុស្ស
http://europa.eu/legislation_summaries/human_rights/human_rights_in_third_countries/l33601_en.htm

ភាពអឺរ៉ុបស្តីពីគោលការណ៍របស់សហភាពអឺរ៉ុបក្នុងការគាំទ្រដល់អ្នកការពារសិទ្ធិមនុស្ស បានទទួលស្គាល់ «នូវការបរិច្ចាគដែលមិនអាចកាត់ថ្លៃបានរបស់អ្នកការពារសិទ្ធិមនុស្ស ក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងការទប់ស្កាត់ជម្លោះដែលនាំឲ្យប៉ះពាល់ដល់សុវត្ថិភាពរបស់ខ្លួន [...]។[36]

ក្នុងឆ្នាំ២០១២អ្នករាយការណ៍ពិសេស ឬអ្នកតំណាងទទួលបន្ទុកសេរីភាពក្នុងការបញ្ចេញមតិរបស់អង្គការសហប្រជាជាតិ អង្គការដើម្បីសន្តិសុខនិងសហប្រតិបត្តិការក្នុងតំបន់អឺរ៉ុប អង្គការរដ្ឋអាមេរិកកាំង និងគណៈកម្មការអាហ្វ្រិចស្តីពីមនុស្សនិងសិទ្ធិមនុស្ស បានអនុម័តសេចក្តីថ្លែងការណ៍រួមមួយស្តីពីឧក្រិដ្ឋកម្មប្រឆាំងសេរីភាពក្នុងការបញ្ចេញមតិ[37] ដោយបានគូសបញ្ជាក់ពីអង្គហេតុដែលថា «ឧក្រិដ្ឋកម្មប្រឆាំងសេរីភាពក្នុងការបញ្ចេញមតិ [...] ជាការបំពានដ៏ធ្ងន់ធ្ងរលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិទទួលបានព័ត៌មាន»។ សេចក្តីប្រកាសរួមនេះក៏បានធ្វើការកត់សម្គាល់ថា «អំពើហឹង្សា និងឧក្រិដ្ឋកម្មដទៃទៀតប្រឆាំងនឹងការប្រើប្រាស់សិទ្ធិក្នុងការបញ្ចេញមតិ រាប់បញ្ចូលទាំងចំពោះអ្នកសារព័ត៌មាន តួអង្គសារព័ត៌មានដទៃទៀត និងអ្នកការពារសិទ្ធិមនុស្ស មានផលប៉ះពាល់ដល់លំហូរព័ត៌មាន និងមតិយោបល់ក្នុងសង្គម («ការគាបសង្កត់តាមរយៈឃាតកម្ម» ហើយនេះជាការវាយប្រហារមិនត្រឹមតែចំពោះជនរងគ្រោះប៉ុណ្ណោះទេថែមទាំងចំពោះសេរីភាពក្នុងការបញ្ចេញមតិផងដែរ...»)។

## បទដ្ឋានថ្នាក់តំបន់

នៅតំបន់អាស៊ីអាគ្នេយ៍វិញ ថ្មីៗនេះ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថាអាស៊ានបានអនុម័តសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន កាលពីខែវិច្ឆិកា ឆ្នាំ២០១២។[38] សេចក្តីប្រកាសនេះ ផ្ទុកនូវបញ្ញត្តមានប្រយោជន៍មួយចំនួនដល់ការងារអ្នកការពារសិទ្ធិមនុស្ស ដូចជាការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងប្រកាន់យកមតិយោបល់ ដូចមានចែងក្នុងមាត្រា២៣ សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី ចែងក្នុងមាត្រា២៤ សិទ្ធិចូលរួមក្នុងជីវភាពនយោបាយនៃប្រទេស ចែងក្នុងមាត្រា២៥ ជាដើម។[39] ទោះជាយ៉ាងនេះក្តី សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាននេះ នៅមានចំណុចខ្វះខាតមួយចំនួន។ ចំណុចព្រួយបារម្ភខ្លាំងនោះគឺការប្រើប្រាស់ពាក្យពេចន៍ទូលាយ និងមិនច្បាស់លាស់ពាក់ព័ន្ធនឹងការដែលអនុញ្ញាតឲ្យមានការរឹតបន្តឹងដល់ការប្រើប្រាស់សិទ្ធិ ដោយនេះអាចធ្វើឲ្យសិទ្ធិរបស់បុគ្គលអាចត្រូវបានដកហូត ក្រោមការសំអាងដើម្បីផលប្រយោជន៍រួម ឬជាតិ។ ចំណុចទីពីរនោះគឺថាសេចក្តីប្រកាសនេះគឺអាចរាំងខ្ទប់បានក្រោមការយោងដល់«ច្បាប់ជាតិ» ឬ

---

[36]សេចក្តីសម្រេចរបស់សភាសហភាពអឺរ៉ុប ២០០៩/២១៩៩(អាយអិនអាយ) ស្តីពីគោលការណ៍របស់សហភាពអឺរ៉ុប គាំទ្រអ្នកការពារសិទ្ធិមនុស្ស (ឆ្នាំ២០០៩) http://www.europarl.europa.eu/sides/getDoc.do?pubRef=-//EP//TEXT+TA+P7-TA-2010-0226+0+DOC+XML+V0//EN&language=EN

[37]សេចក្តីប្រកាសរួមស្តីពីឧក្រិដ្ឋកម្មប្រឆាំងសេរីភាពក្នុងការបញ្ចេញមតិ (ឆ្នាំ២០១២) http://www.oas.org/en/iachr/expression/showarticle.asp?artID=905&lID=1

[38]អាស៊ាន, សេចក្តីថ្លែងការណ៍នៅទីក្រុងភ្នំពេញស្តីពីការអនុម័តសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន» (សេចក្តីថ្លែងការណ៍) (ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២) http://www.asean.org/news/asean-statement-communiques/item/phnom-penh-statement-on-the-adoption-of-the-asean-human-rights-declaration-ahrd

[39]អាស៊ាន, «សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន» (វិច្ឆិកា ឆ្នាំ២០១២) http://www.asean.org/news/asean-statement-communiques/item/asean-human-rights-declaration

«បរិបទសាសនា និងប្រទេស» ដែលនេះធ្វើឲ្យបាត់បង់នូវសកលភាព និងភាពមិនអាចកាត់ផ្តាច់បានចំពោះសិទ្ធិមនុស្ស ហើយនេះធ្វើឲ្យសេចក្តីប្រកាសនេះឋិតឆ្ងាយពីបទដ្ឋានអប្បបរិមារបស់ ក.អ.ស.ព.ន និងកតិកាសញ្ញាអន្តរជាតិដទៃទៀតដែលរដ្ឋជាសមាជិកអាស៊ានទាំងអស់តម្រូវត្រូវបំពេញ។[40]

អ្វីដែលទាក់ទងផ្ទាល់ដល់ការជ្រៀតជ្រែករបស់រដ្ឋនោះ គឺគោលការណ៍អធិបតេយ្យភាពដាច់ខាតរបស់រដ្ឋជាសមាជិកអាស៊ាន។ កង្វះនូវយន្តការពង្រឹងច្បាប់ថ្នាក់តំបន់ ដូចជាតុលាការសិទ្ធិមនុស្សថ្នាក់តំបន់ជាដើម បានធ្វើឲ្យសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និងគណៈកម្មាការសិទ្ធិមនុស្សអាស៊ាន មិនមានអំណាចអ្វីនោះទេ។[41] សេចក្តីប្រកាសនេះនឹងធ្វើឲ្យមានគ្រោះថ្នាក់ដល់សន្តិសុខរបស់អ្នកការពារសិទ្ធិមនុស្ស នៅពេលដែលរដ្ឋជាសមាជិកដូចជាកម្ពុជានឹងចាប់ផ្តើមសម្លឹងមើលសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាននេះជាគោល ឬជាសំអាងជាជាងការបំពេញតាមកាតព្វកិច្ចដូចដែលបានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

សម្រាប់អវត្តមាននូវស្ថាប័នសិទ្ធិមនុស្សថ្នាក់តំបន់ដែលមានប្រសិទ្ធិភាពពេញលេញមួយ ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិនិងតុលាការជាតិក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺត្រូវការចាំបាច់បំផុតក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងអ្នកការពារសិទ្ធិមនុស្សក្នុងប្រទេសជាសមាជិក។

[40]ម.ស.ម.ក, «ម.ស.ម.ក គូសបញ្ជាក់ពីភាពប្រញាប់ប្រញាលក្នុងការអនុម័តនៃសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ានដែលមិនបំពេញតាមបទដ្ឋានអន្តរជាតិ» (សេចក្តីថ្លែងការណ៍) (ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២)
http://www.sithi.org/temp.php?url=media_view2.php&mid=6093
[41]ដូចខាងលើ។

# បទបញ្ញត្តជាតិ និងការរឹតបន្តឹង

អ្នកការពារសិទ្ធិមនុស្សត្រូវបានការពារក្រោមច្បាប់ជាតិ។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានធានាដល់«ការគោរព និងទទួលស្គាល់» សិទ្ធិនានាដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាសិទ្ធិមនុស្សដទៃទៀតហើយថាពលរដ្ឋគ្រប់រូបត្រូវមានសិទ្ធិស្មើគ្នា។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញបានចែងថា៖

*«ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ»* ។

កតិកាសញ្ញា និងអនុសញ្ញាទាំងនេះត្រូវបានដាក់បញ្ចូលក្នុងច្បាប់ជាតិតាមរយៈការផ្តល់សច្ចាប័ន ហើយការផ្តល់សច្ចាប័ននេះត្រូវបានបញ្ជាក់តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដែលចែងថា *«កតិកាសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានទទួលស្គាល់ បានបញ្ចូលជាច្បាប់ជាតិ»*។[42]

រដ្ឋធម្មនុញ្ញក៏ការពារដល់សិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សផងដែរ តាមរយៈមាត្រា៤១ដែលចែងថា *«ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ»*។ បន្ថែមលើសនេះ មាត្រា៣៥ នៃរដ្ឋធម្មនុញ្ញចែងថា ពលរដ្ឋខ្មែរមានសិទ្ធិ *«ចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ចនិងវប្បធម៌របស់ប្រទេសជាតិ»* ហើយមាត្រា៣៩ ចែងអំពីសិទ្ធិពលរដ្ឋ *«ប្តឹងបរិហារ ប្តឹងតវ៉ាឬប្តឹងទាសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ»*។ គួរកត់សម្គាល់ថាការទទួលបានសិទ្ធិមូលដ្ឋានដោយឈរលើមូលដ្ឋានសញ្ជាតិនោះ គឺមិនអនុលោមតាមបទដ្ឋានអន្តរជាតិឡើយ ដោយសារថាសិទ្ធិទាំងនេះត្រូវបានយល់ថា ត្រូវអនុវត្តតែលើបុគ្គលដែលឋិតក្នុងបូរណភាពទឹកដីកម្ពុជាឬក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប៉ុណ្ណោះ។

លើសពីនេះ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញចែងថា *«ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ»*។ ការរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិ និងការប្រជុំដោយសន្តិវិធី ដោយសំអាងលើ *«ទំនៀមទំលាប់ល្អរបស់សង្គម»* នោះគឺមិនស្របច្បាប់ទេ ហើយនេះបានចាកឆ្ងាយពី

[42]ក្រុមប្រឹក្សាធម្មនុញ្ញនៃប្រទេសកម្ពុជា, សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (ឆ្នាំ២០០៧)

បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ហើយអាចត្រូវបានគេបំពានតាមអំពើចិត្ត ដើម្បីរឹតត្បិតដល់ការប្រើប្រាស់សិទ្ធិមូលដ្ឋានទាំងនេះ។

អ្នកការពារសិទ្ធិមនុស្សក្នុងនាទីជាមួយរដ្ឋសភាវិញ ក៏ត្រូវទទួលបានការការពារតាមរយៈមាត្រា៨០ នៃរដ្ឋធម្មនុញ្ញផងដែរ ដែលជានាថា«*តំណាងរាស្ត្រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ*»។

ថ្វីបើសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សត្រូវបានធានាក្រោមច្បាប់ជាតិ និងអន្តរជាតិក្តី មានចំណុចជាច្រើនដែលច្បាប់ជាតិបានដើរផ្ទុយពីកិច្ចធានានេះ ហើយបានដាក់បន្ទុកច្បាប់លើសលប់ និងជាឧបសគ្គដល់ការងារអ្នកការពារសិទ្ធិមនុស្ស។[43]

## ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ (ក្រមព្រហ្មទណ្ឌ) ចូលជាធរមានក្នុងខែធ្នូ ឆ្នាំ២០១០ ហើយក្រមនេះផ្ទុកនូវបញ្ញត្តមិនច្បាស់លាស់ជាច្រើនដែលរឹតត្បិតដល់សេរីភាព ហើយដែលជាហេតុរាំងស្ទះដល់ការងារអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា។

យោងតាមមាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ រាល់ការអះអាងដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទនៃបុគ្គល ឬនៃស្ថាប័ន គឺជាបរិហារកេរ្តិ៍។ ចេតនារបស់ជនជាប់ចោទ ឬការការពារចំពោះទំនៀមទំលាប់ដែលត្រូវបានគេកាត់ក្តីនៅដែនសមត្ថកិច្ចដទៃទៀតនោះដូចជាការផ្តល់សេចក្តីអធិប្បាយដែលសមស្រប[44] គឺមិនមានស្ថានទម្ងន់លើបទល្មើសនោះឡើយ។

បន្ថែមលើសនេះទៀតមាត្រា៣០៧ បានកំណត់ថាគ្រប់ពាក្យប្រមាថ គ្រប់ពាក្យមើលងាយ ឬគ្រប់ពាក្យទ្រគោះ ដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយ គឺជាការជេរប្រមាថ។ បទល្មើសនេះអាចត្រូវបានប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយ ដូចជាតាមរយៈសារព័ត៌មាន តាមពាក្យសំដី លិខិតឬគំនូរ ឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍។ និយមន័យនៃការជេរប្រមាថនេះមានលក្ខណៈទូលាយ ដែលនេះអាចប្រើប្រាស់ដើម្បីអនុវត្តចំពោះអ្នករិះគន់ ឬអ្នកនិពន្ធជៀលត្មះ។

---

[43]អង្គការលីកាដូ, «ការបំភ័ន្តភ្នែកនៃការអភិវឌ្ឍន៍៖ ការវាយបកផ្នែកច្បាប់នៅកម្ពុជាចំពោះសេរីភាពក្នុងការបញ្ចេញមតិ» (របាយការណ៍) (ខែតុលាឆ្នាំ២០១១ http://www.licadho-cambodia.org/reports/files/162LICADHOReport-LegislativeAssaultFreedomExpression2011-English.pdf

[44]សេចក្តីអធិប្បាយដែលសមស្រប ជាបរិបទដែលគេប្រើប្រាស់ដើម្បីការពារដល់ទង្វើសរសេរបរិហាកេរ្តិ៍ ដែលអនុវត្តចំពោះសេចក្តីថ្លែងការណ៍របស់អ្នកនិពន្ធ (ឧ.តាមរយៈបណ្តាញសារព័ត៌មាន) ក្នុងន័យសំដែងនូវជំនឿថាជាការពិត ពាក់ព័ន្ធនឹងទង្វើរបស់មន្ត្រីរាជការ ហើយបើទោះបីជាសេចក្តីថ្លែងការណ៍នោះមិនពិតយ៉ាងក៏ដោយ។ សេចក្តីអធិប្បាយដែលសមស្របត្រូវតែផ្អែកលើអង្គហេតុ ដែលបានបញ្ជាក់ ដោយមិនមានបំណងអាក្រក់ ឬមិនគួរឲ្យគោរពដែលឆ្លុះបញ្ចាំងតាមអង្គហេតុនោះ ហើយត្រូវតែជាការបញ្ចេញមតិដោយស្មោះត្រង់របស់អ្នកនិពន្ធ។

មាត្រា៣១១ បានកំណត់ការប្ដឹងបរិហាបង្កាត់កេរ្ដិ៍ ជាបទព្រហ្មទណ្ឌ ហើយបានផ្ដល់និយមន័យថាជាអំពើប្ដឹងបរិហារអំពីអំពើដែលគេដឹងថាមិនពិត ហើយដែលនាំឲ្យមានទណ្ឌកម្មព្រហ្មទណ្ឌ ឬវិន័យ។ បុគ្គលណាមួយក៏ដោយអាចត្រូវបានគេចោទពីបទធ្វើឲ្យបាត់ជំនឿលើសេចក្ដីសម្រេចរបស់តុលាការ។[45]

បរិបទអន្តរជាតិទំនងទោរទន់ទៅរកការលុបចោលបទបរិហាកេរ្ដិ៍ជាបទព្រហ្មទណ្ឌ ដែលនេះបង្ហាញថារដ្ឋជាច្រើនមានសមត្ថភាពគ្រប់គ្រាន់ការពារសិទ្ធិបុគ្គល ក្នុងការរក្សាបានកិត្តិយសដោយមិនចាំបាច់ប្រើច្បាប់ព្រហ្មទណ្ឌនោះទេ។[46] គណៈកម្មាការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ[47] អណ្ដត្តិពិសេសទាំងបួនស្ដីពីសេរីភាពក្នុងការបញ្ចេញមតិ[48] និងគណៈកម្មាការអាហ្វ្រិច[49] បានអំពាវនាវដល់រដ្ឋទាំងអស់ឲ្យលុបចោលបទបរិហារកេរ្ដិ៍ជាបទល្មើសព្រហ្មទណ្ឌ។

ជាងនេះទៅទៀត បទដ្ឋានអន្តរជាតិ ដូចជាគោលការណ៍ស៊ីរ៉ាកូសាស្ដីពីបញ្ញត្តកំហិតនិងការលើកលែងចំពោះកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងយ៉ាងច្បាស់ថាសិទ្ធិក្នុងការបញ្ចេញមតិមិនអាចត្រូវបានកំហិតដើម្បីការពាររដ្ឋ ឬមន្ត្រីរាជការរបស់រដ្ឋពីការរិះគន់នោះទេ។[50] គណៈកម្មាការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដូចបានថ្លែងក្នុងសេចក្ដីអធិប្បាយទូទៅលេខ៣៤បានគូសបញ្ជាក់ពីគុណតម្លៃដូចដែលមានចែងក្នុង ក.អ.ស.ព.ន អំពីការបញ្ចេញមតិដែលមិនអាចត្រូវបានហាមឃាត់ពាក់ព័ន្ធនឹងការជជែកវែកញែកខាងនយោបាយ ហើយបានបញ្ជាក់យ៉ាងច្បាប់ថា រដ្ឋមិនអាចហាមឃាត់ការរិះគន់អំពីស្ថាប័ន ហើយថាមន្ត្រីសាធារណៈគួរតែរំពឹងទុកនូវមតិរិះគន់និងការប្រឆាំង ហើយមិនអាចទទួលបាននូវការការពារពីកិច្ចការទាំងនេះទេ។[51]

## ច្បាប់ស្ដីការធ្វើបាតុកម្មដោយសន្តិវិធី

[45]មាត្រា៥២៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[46]ប្រទេសហ្គាណា តូហ្គោ ម៉ិចស៊ីកូ ចក្រភពអង់គ្លេស អៀឡង់ដ៍ ស្រីលង្កា ចដជៀរ និងប្រទេសម៉ាឡៅវ បានលុបចោលបទបរិហារកេរ្ដិ៍ចេញពីបទព្រហ្មទណ្ឌ ហើយសាធារណរដ្ឋអាហ្វ្រិចកណ្ដាលបានលុបចោលការផ្ដន្ទាទោសបទឧក្រិដ្ឋក្នុងការសរសេរបរិហាកេរ្ដិ៍ផងដែរ។

[47]ការអង្កេតរួមលើប្រទេសអ៊ីតាលី (CCPR/C/ITA/CO/5), ការអង្កេតរួមលើអតីតសាធារណរដ្ឋយូហ្គោស្លាវីនៃម៉ាស៊ីដូណា (CCPR/C/MKD/CO/2)

[48]សេចក្ដីប្រកាសរួមគ្នារបស់អ្នករាយការណ៍ពិសេសស្ដីពីសេរីភាពក្នុងការប្រកាន់មតិ និងបញ្ចេញមតិ តំណាងរបស់ អូ.អេស.ស៊ី.អ៊ី ស្ដីពីសេរីភាពខាងសារព័ត៌មាន និងអ្នករាយការណ៍ពិសេររបស់ អូ.អេ.អេស ស្ដីពីសេរីភាពក្នុងការបញ្ចេញមតិ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០២។ សម្រាប់ព័ត៌មានបន្ថែមសូមចូលមើល៖http://www.osce.org/documents/rfm/2004/10/14893_en.pdf

[49]ដូចខាងលើកំណត់សម្គាល់ទី៣៥។

[50]គណៈកម្មាការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, «គោលការណ៍ស៊ីរ៉ាកូសាស្ដីពីការកំហិតនិងការលើកលែងចំពោះបញ្ញត្តក្នុងកតិការសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ» (ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៨៤) ឯកសាររបស់អង្គការសហប្រជាជាតិលេខ E/CN.4/1984/4http://www.unhcr.org/refworld/docid/4672bc122.html

[51]គណៈកម្មាការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ «សេចក្ដីអធិប្បាយទូទៅលេខ៣៤ ស្ដីពីមាត្រា១៩៖ សេរីភាពក្នុងការប្រកាន់មតិនិងបញ្ចេញមតិ» (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១) ឯកសាររបស់អង្គការសហប្រជាជាតិលេខ CCPR/C/GC/34ប្រយោគទី៣៨ http://www2.ohchr.org/english/bodies/hrc/docs/GC34.pdf

ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានកែទម្រង់ក្នុងឆ្នាំ២០០៩។ ខណៈដែលការកែទម្រង់នេះជាចំណុចវិជ្ជមាននោះមានចំណុចព្រួយបារម្ភខ្លះពាក់ព័ន្ធនឹងការអនុវត្តន៍ច្បាប់នេះ ហើយនឹងភាពជាក់លាក់នៃបញ្ញត្តមួយចំនួន។[52]

មាត្រា២នៃច្បាប់បាតុកម្មនេះ ចែងពីគោលបំណងនៃច្បាប់ដែលថាដើម្បីធានាការពារសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី។ ជាថ្មីម្ដងទៀត នេះជាបញ្ហាដោយសារថា សិទ្ធិនេះចែងធានាតែពលរដ្ឋជនជាតិខ្មែរតែប៉ុណ្ណោះហើយមិនតម្រូវសម្រាប់គ្រប់បុគ្គលនោះទេ។ សិទ្ធិនេះត្រូវបានតម្រូវដោយបញ្ញត្តដែលបញ្ជាក់ថាសិទ្ធិនេះមិនអាចត្រូវបានប្រើប្រាស់ធ្វើឲ្យ «ប៉ះពាល់ដល់ទំនៀមទំលាប់ល្អរបស់សង្គមជាតិ ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ»។ ដូចបានរៀបរាប់ខាងលើ ការរឹតបន្តឹងបែបនេះនឹងអាចត្រូវបានបំពានតាមអំពើចិត្តដើម្បីរឹតបន្តឹងដល់ការប្រើប្រាស់សិទ្ធិមូលដ្ឋាន។

អ្វីដែលគួរឲ្យព្រួយបារម្ភផងនោះគឺច្បាប់បាតុកម្មនេះបានបង្កើត «សួនសេរីភាព» ដែលជាកន្លែងដែលសាលាក្រុងនិងខេត្តត្រូវរៀបចំឡើងដើម្បីឲ្យសាធារណៈជនប្រមូលផ្ដុំ និងធ្វើបាតុកម្ម។[53] ថ្វីបើច្បាប់បាតុកម្មនេះបានចែងថា ការបង្កើតទីកន្លែងសម្រាប់បញ្ចេញមតិនេះនឹងមិនរារាំងឲ្យពលរដ្ឋធ្វើបាតុកម្មនៅកន្លែងផ្សេងក៏ដោយ បញ្ញត្តនេះអាចត្រូវបានគេបំពានដើម្បីរឹតបន្តឹងដល់បាតុករក្នុងការជ្រើសរើសទីតាំងដើម្បីធ្វើបាតុកម្ម។ ការបង្ខំបាតុករឲ្យទៅធ្វើបាតុកម្មនៅទីកន្លែងដែលមនុស្សមិនសូវមើលឃើញ ឬដឹងឮនោះជាការបំពានដល់បទដ្ឋានអន្តរជាតិស្ដីពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនិងសេរីភាពក្នុងការប្រជុំ។

## ច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ២០១០

យោងតាមច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ២០១០ «ក្នុងករណីបណ្ដឹងបរិហារកេរ្តិ៍ ឬព័ត៌មានមិនពិត... ដែលបង្កឲ្យខាតពេលដល់ការស៊ើបអង្កេតនោះ» បុគ្គលអាចត្រូវប្រឈមជាប់ពន្ធនាគារចំនួន៦ខែ ឬពិន័យជាប្រាក់១លានទៅ១០លានរៀល។

ដូចបានរៀបរាប់ខាងដើម យន្តការអន្តរជាតិជាច្រើនបានផ្ដល់ជាអនុសាសន៍ឲ្យលុបបទបរិហារកេរ្តិ៍ចេញពីបទព្រហ្មទណ្ឌ។ សម្រាប់បរិបទច្បាប់ប្រឆាំងអំពើពុករលួយវិញការដាក់ទោសពិន័យព្រហ្មទណ្ឌដែលបង្កដោយសារការធ្វើឲ្យមានការស៊ើបអង្កេតដែលមិនត្រឹមត្រូវ ឬមិនបានការនោះគឺមានលក្ខណៈមិនច្បាស់លាស់ ហើយទំនងនឹងរាំងស្ទះដល់អ្នកផ្ដល់ដំណឹងក្នុងការបេកអាក្រាតអំពើពុករលួយ។ ដូចនេះបញ្ញត្តបែបនេះមិនបានផ្ដល់នូវកិច្ចធានានិងការលើកទឹកចិត្តដល់បុគ្គលិកផ្សេងៗសោះឡើយ។ យ៉ាងហោចណាស់ ការដាក់ទោសពិន័យក្នុងការលាតត្រដាងព័ត៌មានគួរត្រូវបានចែងក្នុងក្រមរដ្ឋប្បវេណី ក្នុងករណីដែលជនជាប់ចោទបានដឹងថាព័ត៌មាននោះមិនពិតហើយតែនៅតែប្រព្រឹត្តក្នុងគោលបំណងធ្វើឲ្យខូចកិត្តិយសរបស់រូបវន្ត ឬនិតិបុគ្គល។

---

[52]ម.ស.ម.ក, «កម្រងច្បាប់៖ ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី (សលាកប័ត្រ) (ខែសីហា ឆ្នាំ២០១១) http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=7&id=5
[53]មាត្រា១៤នៃច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី

## ច្បាប់របបសារព័ត៌មានឆ្នាំ១៩៩៥

ច្បាប់របបសារព័ត៌មានឆ្នាំ១៩៩៥ ត្រូវបានអនុម័តដោយមានសំពាធពីសំណាក់ម្ចាស់ជំនួយអន្តរជាតិ ដើម្បីជំនួសលើច្បាប់របបសារព័ត៌មានឆ្នាំ១៩៧២ ដែលមិនមានអំណោយផលដល់សេរីភាព។ ច្បាប់របបសារព័ត៌មានបច្ចុប្បន្ននេះផ្ទុកនូវបញ្ញត្តិវិជ្ជមានជាច្រើនដើម្បីលើកកម្ពស់សេរីភាពក្នុងការបញ្ចេញមតិ ដែលស្របតាមសិទ្ធិធម្មនុញ្ញ រាប់បញ្ចូលទាំង៖ ការធានាដល់ «សេរីភាពសារព័ត៌មាន» និង «សេរីភាពបោះពុម្ពផ្សាយ» (មាត្រា ១) ការធានាថាប្រភពព័ត៌មាននឹងត្រូវបានការពារ (មាត្រា២) ការធានាប្រឆាំងនឹង«ការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយ» (មាត្រា ៣) និងធានាថាការបោះពុម្ពផ្សាយនូវព័ត៌មានផ្លូវការមិនអាចត្រូវបានផ្តន្ទាទោសបានឡើយ ប្រសិនបើការផ្សាយនោះមានលក្ខណៈសមស្របតាមសភាពពិតពេញលេញ ឬសេចក្តីសង្ខេបត្រឹមត្រូវតាមរឿងពិត (មាត្រា ៤)។

ទោះជាមានបទបញ្ញត្តទាំងនេះក្តី អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានបានរិះគន់ដល់ច្បាប់របបសារព័ត៌មាននេះដោយឈរលើមូលដ្ឋានថាបញ្ញត្តនេះបានបន្ថែមឧបសគ្គដល់ការបញ្ចេញមតិ តាមរយៈពាក្យសំដី ឬការបោះពុម្ពផ្សាយដោយអ្នកសារព័ត៌មាន។[54] តួយ៉ាង យោងតាមច្បាប់នេះអ្នកសារព័ត៌មានអាចត្រូវបានគេផ្តន្ទាទោសជាប់ពន្ធនាគារ ក្នុងករណីរកឃើញមានពិរុទ្ធភាពពីបទបរិហារកេរ្តិ៍និងសរសេរបរិហារកេរ្តិ៍ដោយអត្ថបទសំណេរនោះអាចប៉ះពាល់«សន្តិសុខជាតិ» ឬ «ស្ថេរភាពនយោបាយ»[55] (មាត្រា១២)។ វាក្យស័ព្ទ «សន្តិសុខជាតិ» និង «ស្ថេរភាពនយោបាយ» មិនត្រូវបានផ្តល់និយមន័យច្បាស់លាស់ក្នុងច្បាប់របបសារព័ត៌មាននេះទេ ដែលនេះអនុញ្ញាតឲ្យមានឆន្ទានុសិទ្ធិខាងតុលាការច្រើន និងការគំរាមកំហែងដែលអាចប្រឈមចំពោះបុគ្គលដែលអាជ្ញាធរយល់ថាអាចទាញចូលឲ្យជាប់ក្នុងបញ្ញត្តនេះ។ បញ្ញត្តមិនច្បាស់លាស់ដទៃទៀតក្នុងច្បាប់របបសារព័ត៌មាននេះរាប់បញ្ចូលទាំងការហាមប្រាមការបោះពុម្ពផ្សាយព័ត៌មានដែលជេរប្រមាថដល់ «ស្ថាប័នជាតិ»[56] ឬដែលអាច «ប៉ះពាល់ដល់ទំនៀមទម្លាប់ល្អរបស់សង្គមជាតិ»[57]។ ការរឹតបន្តឹងតាមរយៈពាក្យពេចន៍ដែលមានលក្ខណៈទូទៅនិងមិនច្បាស់លាស់នេះ មានឥទ្ធិពលគាបសង្កត់ដល់អ្នកសារព័ត៌មាន និងងាយដកហូតនូវសមត្ថភាពរបស់ពួកគាត់ក្នុងការរាយការណ៍ដោយសេរី និងមានប្រសិទ្ធភាពដើម្បីផលប្រយោជន៍សាធារណៈ។

## សេចក្តីព្រាងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល

សេចក្តីព្រាងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ផ្ទុកនូវបញ្ញត្តទូទៅនិងមិនច្បាស់លាស់ជាច្រើន ដែលអាចត្រូវបានគេប្រើប្រាស់តាមអំពើចិត្ត ដើម្បីបដិសេធចំពោះការចុះឈ្មោះឬបិទអង្គការមិនមែន

[54] អង្គការមាត្រា១៩, «អនុសារណៈលើច្បាប់របបសារព័ត៌មានខ្មែរ» (ខែតុលា ឆ្នាំ២០០៤)
http://www.article19.org/data/files/pdfs/analysis/cambodia-press-law-oct-2004.pdf

[55] ដូចខាងលើ។

[56] មាត្រា១៣នៃច្បាប់របបសារព័ត៌មានឆ្នាំ១៩៩៥

[57] មាត្រា១៤នៃច្បាប់របបសារព័ត៌មានឆ្នាំ១៩៩៥

រដ្ឋាភិបាល ឬសមាគម ហើយច្បាប់នេះតម្រូវឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ត្រូវចុះឈ្មោះមុននឹងត្រូវបានគេអនុញ្ញាតឲ្យធ្វើសកម្មភាពក្នុងប្រទេសកម្ពុជា។ ជាងនេះទៅទៀត និតិវិធីក្នុងការចុះឈ្មោះទៀតសោត គឺខ្វះការជានានិងតម្លាភាពផងដែរ។[58]

នាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្យួរសេចក្តីព្រាងច្បាប់នេះកាលពីខែធ្នូ ឆ្នាំ២០១១ បន្ទាប់ពីមានការរិះគន់ពីសហគមន៍ជាតិនិងអន្តរជាតិ ប៉ុន្តែនេះមិនត្រូវបានបោះចោលទាំងស្រុងទេ ហើយនឹងត្រូវបានគេលើកមកពិភាក្សាឡើងវិញក្នុងរបៀបវីរៈច្បាប់នាពេលអនាគតឆាប់ៗនេះ។ ការតាក់តែងច្បាប់នេះឡើង បន្តឲ្យមានការគំរាមកំហែងធ្ងន់ធ្ងរដល់សេរីភាពខាងចូលរួមជាសមាគម និងសេរីភាពបញ្ចេញមតិរបស់សង្គមស៊ីវិល។

## សេចក្តីព្រាងច្បាប់ស្តីពីសហជីព

ស្រដៀងគ្នានឹងរបត់នៃពង្រាងច្បាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលដែរនោះ សេចក្តីព្រាង ច្បាប់ស្តីពីសហជីពនេះក៏បានដាក់ការរឹតបន្តឹងខ្លាំងដល់សមាជិកសហជីព និងសកម្មជនសិទ្ធិការងារ។ ជាឧទាហរណ៍ ពង្រាងច្បាប់សហជីពនេះ ផ្ទុកនូវបទល្មើសព្រហ្មទណ្ឌជាច្រើនដែលអនុវត្តចំពោះសហជីពនិងកម្មករ ដែលបទល្មើសទាំងនោះត្រូវបានផ្តល់និយមន័យយ៉ាងទូលាយ និងទទួលការផ្តន្ទាទោសធ្ងន់ធ្ងរ។ មាត្រា៦៨នៃសេចក្តីព្រាងច្បាប់នេះហាមប្រាមកម្មករនិងសហជីព ពីការបំពានលើកិច្ចព្រមព្រៀងចរចាររួម ការធ្វើបាតុកម្មខុសច្បាប់ និងការរំខានដល់សន្តិភាពដើម្បីគោលបំណងនយោបាយ។ ជាងនេះទៅទៀត សេចក្តីព្រាងច្បាប់នេះ ដាក់បន្ទុកធ្ងន់ធ្ងរក្នុងតម្រូវការចុះឈ្មោះក្នុងការបង្កើតសហជីព ដូចមានចែងក្នុងមាត្រា១២ និងតម្រូវការឲ្យធ្វើរបាយការណ៍ហិរញ្ញវត្ថុដែលលើសលុប ដូចមានចែងក្នុងមាត្រា១៧។

[58]ម.ស.ម.ក, «ពង្រាងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល» (សលាកប័ត្រ) (ខែឧសភា ឆ្នាំ២០១១) http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=1&id=5

# ការវាយតម្លៃលើភាពប្រថុយប្រថានរបស់អ្នកការពារសិទ្ធិមនុស្សកម្ពុជា

## វិសាលភាព និងវិធីសាស្ត្រ

ម.ស.ម.ក និងអង្គការមាត្រា១៩បានធ្វើបទសម្ភាសជាមួយអ្នកការពារសិទ្ធិមនុស្សចំនួន២២នាក់ដើម្បីស្វែងយល់ពីសូចនាករត្រឹមត្រូវមួយ ជុំវិញភាពប្រថុយប្រថានដែលអ្នកការពារសិទ្ធិមនុស្សជាច្រើនបានប្រឈម។[59] ក្រុមគោលដៅទាំងនោះរាប់បញ្ចូលទាំង៖ មន្ត្រីរាជការ អ្នកជំនាញផ្នែកច្បាប់ អ្នកជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយ សកម្មជនមូលដ្ឋាន សកម្មជនសហជីព អង្គការសិទ្ធិមនុស្ស និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលជាដើម។ ឈ្មោះរបស់អ្នកតបសម្ភាសន៍ និងអង្គការមួយចំនួន ត្រូវបានដកចេញពីរបាយការណ៍នេះ ដើម្បីធានាដល់សុវត្ថិភាពរបស់ពួកគាត់។

គោលបំណងនៃការធ្វើបទសម្ភាសន៍នេះ គឺដើម្បីស្វែងយល់ឲ្យដឹងច្បាស់ពីហានិភ័យដល់អ្នកការពារសិទ្ធិមនុស្ស និងដើម្បីកំណត់នូវសភាពធ្ងន់ធ្ងរនៃហានិភ័យនោះ និងប្រូបាបដែលហានិភ័យនោះអាចកើតឡើងពិតប្រាកដ ឬនិយាយម្យ៉ាងទៀតគឺកម្រិតនៃភាពប្រថុយប្រថាន។ អង្គការមាត្រា១៩ និង ម.ស.ម.ក ព្យាយាមស្វែងយល់អំពីប្រភពនៃហានិភ័យ កម្រិតធ្ងន់ធ្ងរនៃហានិភ័យ កត្តាទាំងឡាយដែលនាំឲ្យអ្នកការពារសិទ្ធិមនុស្សទទួលរងនូវហានិភ័យនោះ និងការត្រៀមខ្លួនជាស្រេចរបស់អ្នកការពារសិទ្ធិមនុស្សប្រឆាំងតបនឹងហានិភ័យទាំងនោះ។ ព័ត៌មានទាំងនេះត្រូវបានប្រមូលឡើងដើម្បីតាក់តែងជាអនុសាសន៍សម្រាប់ជាយន្តការការពារដែលអាចធ្វើទៅបាន។

បទសម្ភាសន៍ទាំងនេះ ដើរតួសំខាន់ដើម្បីជាចំណុចចាប់ផ្តើមនៃរបាយការណ៍នេះ។ ឆ្លងតាមព័ត៌មានដែលប្រមូលបានជុំវិញហានិភ័យដែលអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាបានប្រឈម បន្ទាប់មក ម.ស.ម.ក បានធ្វើការតាមដានស៊ីជម្រៅលើស្ថានភាពអ្នកការពារសិទ្ធិមនុស្ស ពេញមួយឆ្នាំ២០១២ និងដើមឆ្នាំ២០១៣។

---

[59]អង្គការមាត្រា១៩ បានចុះបេសកកម្មដល់ប្រទេសកម្ពុជា ពីថ្ងៃទី១៤-១៩ ខែមករា ឆ្នាំ២០១២ ហើយបានប្រើប្រាស់ការស្រាវជ្រាវបែបសម្ភាសន៍របស់ខ្លួនដើម្បីប្រមូលព័ត៌មាន។ ម.ស.ម.ក ជាអ្នកជ្រើសរើសអ្នកតបសម្ភាសន៍ និងរៀបចំការធ្វើបទសម្ភាសន៍។ ដោយសារពេលវេលាមានកំណត់ រាល់ការធ្វើបទសម្ភាសន៍ត្រូវបានរៀបចំធ្វើនៅរាជធានីភ្នំពេញ។ អង្គការមាត្រា១៩ និងម.ស.ម.ក បានសម្ភាសន៍អ្នកការពារសិទ្ធិមនុស្សមានមូលដ្ឋាននៅរាជធានីភ្នំពេញ ក៏ដូចគ្នាចំពោះអ្នកដែលបំរើការនៅតាមបណ្តាខេត្តឯទៀតដែលអាចធ្វើដំណើរមកកាន់រាជធានីភ្នំពេញ។ ក្នុងនោះក៏មានការធ្វើបទសម្ភាសន៍តាមប្រព័ន្ធអេឡិចត្រូនិកទៅកាន់ខេត្តរតនៈគិរីដែលស្ថិតនៅប៉ែកឦសាននៃប្រទេសផងដែរ។

ការតាមដាននេះ ធ្វើឡើងតាមរយៈទំនាក់ទំនងយ៉ាងជិតស្និតជាមួយអ្នកការពារសិទ្ធិមនុស្ស ក្រោមគម្រោងអ្នកការពារសិទ្ធិមនុស្សរបស់ ម.ស.ម.ក[60] ដែលបានផ្តល់ជំនួយគាំពារ និងតាមរយៈការឃ្លាំមើលយ៉ាងយកចិត្តទុកដាក់លើបណ្តាញសារព័ត៌មានភាសាខ្មែរ និងអង់គ្លេស។

ជំពូកនេះចែកចេញជាពីរអនុផ្នែកៈ «ប្រភេទអ្នកការពារសិទ្ធិមនុស្ស» និង «ការវាយតម្លៃភាពប្រថុយប្រថាន»។ អនុផ្នែកទីមួយនឹងធ្វើការសម្លឹងមើលប្រភេទអ្នកការពារសិទ្ធិមនុស្សផ្សេងៗគ្នាពោលគឺ តំណាងរាស្ត្រគណបក្សប្រឆាំង មេធាវីសិទ្ធិមនុស្ស អ្នកសារព័ត៌មាន/អ្នកជំនាញការខាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន សកម្មជនសិទ្ធិដីធ្លីមូលដ្ឋាន សកម្មជនសហជីព សកម្មជនសិទ្ធិដីធ្លីជាស្ត្រី អង្គការមិនមែនរដ្ឋាភិបាល និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល។ តាមរយៈការប្រើប្រាស់ករណីសិក្សានោះនឹងអាចបង្ហាញជារូបភាពទូទៅ និងគួរឲ្យចាប់អារម្មណ៍ ជុំវិញហានិភ័យជាញឹកញាប់ដែលអ្នកការពារសិទ្ធិមនុស្សប្រភេទផ្សេងៗគ្នាបានប្រឈមដោយសារការងាររបស់ពួកគាត់ និងកម្រិតនៃភាពងាយរងគ្រោះខុសៗគ្នា។ អនុផ្នែកទីពីរនឹងប្រើប្រាស់យុទ្ធសាស្ត្របែបប្រៀបធៀប តាមរយៈការប្រើប្រាស់ «សូចនាករវាយតម្លៃភាពប្រថុយប្រថាន» ដើម្បីកំណត់ភាពប្រថុយប្រថានទូទៅដែលដាក់បន្ទុកចំពោះអ្នកការពារសិទ្ធិមនុស្សផ្សេងៗគ្នាទៅតាមហានិភ័យផ្សេងៗដែលបានកំណត់ ដោយពិចារណាលើកម្រិតដែលងាយរងគ្រោះដែលអ្នកការពារសិទ្ធិមនុស្សប្រឈមផ្សេងៗគ្នា។

បរិបទនិតិបញ្ញត្ត ជាកត្តាមួយ ដែលមានឥទ្ធិពលលើស្ថានភាពសន្តិសុខរបស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាថ្វីបើមានកត្តាផ្សេងៗទៀតក៏ដោយ។ សន្តិសុខក្នុងន័យនេះគឺសំដៅដល់ការមានសុវត្ថិភាព និងរួចផុតពីហានិភ័យនានា។ នេះអាចមានន័យដល់ការមានសុវត្ថិភាពរួចផុតពីការវាយប្រហារផ្នែករាងកាយ (សន្តិសុខខាងផ្លូវកាយ) ការការពាររបស់ទ្រព្យ (សន្តិសុខខាងទ្រព្យសម្បត្តិ) និងការការពារពីការដែលបុគ្គលដទៃមានលទ្ធភាពទទួលបានព័ត៌មានឯកជនរបស់ខ្លួន (សន្តិសុខខាងព័ត៌មាន)។ សន្តិសុខក៏អាចសំដៅដល់ការមានអារម្មណ៍សុវត្ថិភាពផងដែរ។[61] អ្នកការពារសិទ្ធិមនុស្សនៅទូទាំងប្រទេសកម្ពុជា ជាទូទៅប្រឈមនូវបញ្ហាសន្តិសុខ ដោយសារតែការដើរតួរបស់ខ្លួនក្នុងការការពារសិទ្ធិមនុស្ស។ អ្នករំលោភបំពានសិទ្ធិមនុស្ស ជាញឹកញយច្រើនជាបុគ្គលដែលមានអំណាច ដែលបានប្រតិកម្មនឹងការប្រឈមនានាដែលអ្នកការពារសិទ្ធិមនុស្សបានលើកឡើង តាមរយៈការគំរាមកំហែងដល់សន្តិសុខរបស់អ្នកការពារសិទ្ធិមនុស្ស។[62]

ខណៈដែលអ្នកតបសម្ភាសន៍បានលើកឡើងនូវអំពើហឹង្សាខាងរាងកាយធ្ងន់ធ្ងរ តួយ៉ាងឃាតកម្មបានធ្លាក់ចុះក្នុងប៉ុន្មានឆ្នាំមកនេះ តែឆ្នាំ២០១២បានប្រែក្លាយជាឆ្នាំបង្ហូរឈាមសម្រាប់អ្នកការពារសិទ្ធិមនុស្ស ដែល

---

[60]គម្រោងអ្នកការពារសិទ្ធិមនុស្សរបស់ ម.ស.ម.ក មានគោលបំណងផ្តល់ជាជំនួយដល់អ្នកការពារសិទ្ធិមនុស្សដែលប្រឈមនឹងគ្រោះថ្នាក់ តាមរយៈការផ្តល់ជាជំនួយផ្នែកច្បាប់ មនុស្សធម៌និងជំនួយដទៃទៀត និងតាមរយៈការតស៊ូមតិជាតិ និងអន្តរជាតិ។ សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោងនេះលោកអ្នកអាចស្វែងរកតាមរយៈ
http://www.cchrcambodia.org/index_old.php?url=project_page/project_page.php&p=project_profile.php&id=3&pro=HRDP&show=show

[61]អង្គការស្ពានទៅកាន់សន្តិភាពកម្ពុជា, «សៀវភៅណែនាំស្តីពីសុវត្ថិភាពផ្ទាល់ខ្លួនសំរាប់អ្នកការពារសិទ្ធិមនុស្ស» (ខែសីហា ឆ្នាំ២០១០) http://www.babcambodia.org/securityguide/

[62]ដូចខាងលើ។

ក្នុងនោះបាតុកម្មសិទ្ធិដីធ្លី និងសិទ្ធិការងារដោយសន្តិវិធីជាច្រើនបានប្រែក្លាយទៅជាអំពើហឹង្សា។ អាជ្ញាធរបានបាញ់រះដល់បាតុករ ដែលយ៉ាងហោចណាស់មាន៨ករណីមកហើយចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១១មក។[63]

# ប្រភេទអ្នកការពារសិទ្ធិមនុស្ស

## តំណាងរាស្ត្រគណបក្សប្រឆាំង

អ្នកនយោបាយនិងអ្នកតំណាងរាស្ត្រមកពីគណបក្សប្រឆាំងជាច្រើន ធ្វើការលើកកម្ពស់និងការពារសិទ្ធិមនុស្សសម្រាប់ពលរដ្ឋខ្លួនដោយមិនញញើតខ្លាចក្រែងអ្វីឡើយ។ ជាលទ្ធផល ពួកគាត់ជាញឹកញយ តែងប្រឈមហានិភ័យនិងការគំរាមកំហែង ព្រមទាំងការរំខាននានាដល់ការងាររបស់ពួកគាត់។ អ្នកតំណាងរាស្ត្រមកពីគណបក្សដែលមានសម្លេងតិចតួច ប្រឈមនឹងបទបញ្ញាផ្ទៃក្នុងដែលរារាំងដល់លទ្ធភាពរបស់ពួកគាត់ក្នុងការនិយាយស្តីដោយសេរី។ ឧទាហរណ៍ បទបញ្ញារដ្ឋសភាតម្រូវឲ្យអ្នកតំណាងរាស្ត្រត្រូវអង្គុយរួមគ្នាជាសមាជិក១០រូបដើម្បីអាចមានសិទ្ធិក្នុងនិយាយក្នុងរដ្ឋសភា។ គណបក្សដែលមានសម្លេងតិចតួច ពិតជាលំបាកក្នុងការបំពេញតាមចំនួនកំណត់នោះហើយនេះបានដកហូតសិទ្ធិរបស់ពួកគាត់ពីការជជែកវែកញែក។ សេរីភាពក្នុងការបញ្ចេញមតិរបស់គណបក្សប្រឆាំង ក៏ត្រូវបានរឹតបន្តឹងខ្លាំងក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោតផងដែរ។ ក្នុងអំឡុងពេលបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១២ គណបក្សប្រឆាំងបានប្រឈមនឹងផលលំបាកក្នុងការពាំនាំសាររបស់ខ្លួនដោយសារតែការគ្រប់គ្រងរបស់រដ្ឋាភិបាលទៅលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ អ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិបានរកឃើញនូវភាពមិនប្រក្រតីជាច្រើនក្នុងអំឡុងពេលបោះឆ្នោត ក្នុងនោះរាប់បញ្ចូលទាំងការបំពានក្នុងការប្រើប្រាស់ធនធានរដ្ឋដើម្បីជួយដល់យុទ្ធនាការឃោសនារបស់គណបក្សប្រជាជនកម្ពុជា ដូចជាអាគារនិងឡានរបស់រដ្ឋនិងការប្រើប្រាស់កងកម្លាំងយោធានិងមន្ត្រីនគរបាលជាដើម។[64]

មិនត្រឹមតែអ្នកនយោបាយបក្សប្រឆាំងបានប្រឈមនឹងការរំខានដល់ការបំពេញភារកិច្ចរបស់ពួកគាត់នោះទេ តែអ្នកនយោបាយបក្សប្រឆាំងជាច្រើន ដែលដើរតួជាអ្នកការពារសិទ្ធិមនុស្សនោះត្រូវបានរងការគំរាមកំហែង និងយាយីពីសំណាក់អាជ្ញាធរផងដែរ។

ហានិភ័យមួយក្នុងចំណោមហានិភ័យធ្ងន់ធ្ងរ ដែលសមាជិកគណបក្សប្រឆាំងដែលមានសម្លេងតិចតួចប្រឈមក្នុងរដ្ឋសភានោះគឺការត្រូវបានគេដកហូតអភ័យឯកសិទ្ធិ ដែលទង្វើនេះនឹងធ្វើឲ្យពួកគាត់ងាយរងបទចោទព្រហ្មទណ្ឌ ដូចជាការផ្តល់ព័ត៌មានមិនពិតបទបរិហារកេរ្តិ៍ បទញុះញង់ និងបទរំខានប្រព័ន្ធយុត្តិធម៌ ដែលនេះសុទ្ធសឹងតែកើតឡើងដោយសារការបំពេញភារកិច្ចរបស់ខ្លួន។ បទចោទប្រកាន់ទាំងនេះ សំអាងតាមក្រុម

---

[63]របាយការណ៍អង្គការលីកាដូ, «ការវាយប្រហារនិងហានិភ័យចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ២០១០-២០១២» (ភ្នំពេញឆ្នាំ២០១២) ទំព័រទី១៥ http://www.licadho-cambodia.org/collection/15/attack_hrd_2010_2012

[64]អង្គការខុមហ្វ្រែល, «របាយការណ៍ស្តីពីការបំពានក្នុងការប្រើប្រាស់ធនធានរដ្ឋដើម្បីគោលបំណងបក្ស» (ខែឧសភា ឆ្នាំ២០១២) http://www.comfrel.org/eng/index.php?option=com_content&view=article&id=537:report-on-misuse-of-state-resource-for-political-party-purposes&catid=188:other

ព្រហ្មទណ្ឌនិងច្បាប់ប្រឆាំងអំពើពុករលួយ។ អ្នកតំណាងរាស្ត្រ ត្រូវទទួលបានការការពារក្រោមមាត្រា៨០នៃរដ្ឋធម្មនុញ្ញដែលធានាថាពួកគាត់អាចសំដែងមតិដោយសេរីក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តីរដ្ឋសភាដែលមានសមាសភាពបក្សប្រជាជនកម្ពុជាពីភាគបីនោះអាចដកហូតនូវខែលការពារនេះពីសមាជិកគណបក្សប្រឆាំងបានតាមរយៈការបោះឆ្នោត។

**ករណីអ្នកការពារសិទ្ធិមនុស្ស៖លោកស្រីមូរ សុខហួ**

លោកស្រី មូរ សុខហួរ អ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ីត្រូវបានសម្ភាសន៍សម្រាប់គោលបំណងនៃរបាយការណ៍នេះហើយលោកស្រីបានអនុញ្ញាតដល់អង្គការមាត្រា១៩ និង ម.ស.ម.ក ឲ្យបង្ហាញឈ្មោះលោកស្រីក្នុងរបាយការណ៍នេះ។ គណបក្សសមរង្ស៊ី ជាគណបក្សប្រឆាំងធំជាងគេបង្អស់ដែលថ្មីៗនេះបានប្របាច់ចូលគ្នាជាមួយគណបក្សសិទ្ធិមនុស្ស បង្កើតជាគណបក្សសង្គ្រោះជាតិ។

លោកស្រី មូរ សុខហួរ បាននិយាយមិនសំចៃមាត់ពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្សដែលកើតឡើងនៅទូទាំងប្រទេស ហើយជាលទ្ធផលអភ័យឯកសិទ្ធិសភារបស់លោកស្រី ត្រូវបានគេដកហូតកាលពីឆ្នាំ២០០៩ បន្ទាប់ពីលោកស្រីបានដាក់ពាក្យបណ្តឹងប្រឆាំងនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានធ្វើសេចក្តីអធិប្បាយប្រមាថដល់លោកស្រី។ លោកស្រីបានចាញ់ក្នុងបណ្តឹងនេះ ខណៈដែលលោក ហ៊ុន សែនបានប្តឹងតបតហើយឈ្នះក្តីនេះ។ លោកស្រី មូរ សុខហួរ ត្រូវបានគេរកឃើញថាមានពិរុទ្ធភាពពីបទបរិហាកេរ្តិ៍ និងតម្រូវឲ្យបង់ប្រាក់ពិន័យ។ នៅពេលដែលលោកស្រីបដិសេធមិនបង់ចំនួនប្រាក់ពិន័យទាំងនោះត្រូវបានគេកាត់ចេញដោយស្វ័យប្រវត្តិពីប្រាក់ខែតំណាងរាស្ត្ររបស់លោកស្រី។ លោកស្រីបានតវ៉ាអស់រយៈពេល៣ឆ្នាំ ទើបអភ័យឯកសិទ្ធិរបស់លោកស្រីត្រូវបានប្រគល់ជូនវិញហើយក្នុងរយៈពេល៣ឆ្នាំនោះលោកស្រីឋិតក្នុងភាពហានិភ័យនៃការចាប់ខ្លួនគ្រប់ពេល ដោយសារតែភាពមិនសំចៃមាត់របស់លោកស្រី។ លោកស្រីបានកត់សម្គាល់ថានេះជាការងាយស្រួលបំផុតសម្រាប់គណបក្សកាន់អំណាច ក្នុងការដាក់ពាក្យបណ្តឹងថ្មីផ្សេងទៀតប្រឆាំងនឹងរូបលោកស្រី ដោយហេតុថាប្រព័ន្ធយុត្តិធម៌គឺបំពេញតាមបំណងរដ្ឋាភិបាល និងថាជាក់ស្តែង ប៉ូលីសមិនត្រូវការមានដីកាចាប់ខ្លួននោះទេ។ នៅថ្ងៃទី០៣ខែសីហា ឆ្នាំ២០១២លោកស្រី មូរ សុខហួរ ទទួលបានអភ័យឯកសិទ្ធិមកវិញបន្ទាប់ពីការធ្វើយុទ្ធនាការជាច្រើនកន្លងមក។ ទោះជាយ៉ាងនេះក្តីបណ្តឹងមួយផ្សេងទៀតត្រូវបានព្យួរពាក់ព័ន្ធនឹងការចោទប្រកាន់ពីការពាក់ព័ន្ធរបស់លោកស្រីក្នុងការគេចខ្លួនរបស់សកម្មជនដីធ្លី ពីមជ្ឈមណ្ឌលឃុំឃាំងមួយនៅទីក្រុងភ្នំពេញ ដែលសកម្មជនទាំងអស់នោះត្រូវបានគេឃុំខ្លួនដោយមិនមានបទចោទកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១២។[65] អ្នកជាប់ឃុំទាំងនោះដែលសុទ្ធតែជាស្ត្រីនិងកុមារត្រូវបានគេឃាត់ខ្លួន បន្ទាប់ពីបានធ្វើបាតុកម្មប្រឆាំងនឹងការបណ្តេញចេញពីតំបន់បុរីកីឡានៅទីក្រុងភ្នំពេញ។ ខណៈពេលដែលលោកស្រី មូរ សុខហួរ បានចូលសួរសុខទុក្ខនៅមជ្ឈមណ្ឌលឃុំឃាំងនោះដើម្បីអំពាវនាវឲ្យមានការដោះលែងបាតុករទាំងនោះពួកគាត់បានគេចខ្លួនតាមរបង។

[65] ម.ស.ម.ក, «អ្នកតំណាងរាស្ត្របក្សប្រឆាំងដែលនិយាយមិនសំចៃមាត់នោះបានប្រឈមនឹងបទចោទពីបទបរិហាកេរ្តិ៍ និងបទញុះញង់» (សេចក្តីប្រកាសអាសន្ន) (ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២) http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=14&id=5

ក្នុងអំឡុងពេលសម្ភាសន៍ជាមួយអង្គការមាត្រា១៩ លោកស្រី មូរ សុខហួរ បានលើកឡើងនូវឧបវទ្ទហេតុគួរឲ្យសង្ស័យបានកើតឡើងដែលនេះធ្វើឲ្យលោកស្រីជឿជាក់ថាលោកស្រីឋិតក្រោមការតាមដានពិនិត្យជានិច្ច។ លោកស្រីបានកត់សម្គាល់ពីឧទាហរណ៍ដែលលោកស្រីមិនអាចចូលទៅកាន់គេហទំព័រផ្ទាល់ខ្លួនរបស់លោកស្រីកាលពីខែមករា ឆ្នាំ២០១២ ដោយហេតុថា «បំពានលក្ខខណ្ឌព្រមព្រៀង»។

ជាក់ស្ដែង អភ័យឯកសិទ្ធិតំណាងរាស្ត្រ គ្រាន់តែជាសភាពផ្លូវការតែប៉ុណ្ណោះហើយអ្នកនយោបាយគណបក្សប្រឆាំងអាចត្រូវប្រឈមនឹងផលលំបាកផ្នែកច្បាប់ ដោយសារបានរិះគន់គោលនយោបាយគណបក្សកាន់អំណាច។

ស្រដៀងគ្នានឹងលោកស្រីមូរ សុខហួរអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី គឺលោកហូ វ៉ាន់ ក៏ត្រូវបានគេដកអភ័យឯកសិទ្ធិតំណាងរាស្ត្រផងដែរកាលពីឆ្នាំ២០០៩។

ពាក់ព័ន្ធនឹងករណីលោកស្រីមូរ សុខហួរ នាយករដ្ឋមន្ត្រីហ៊ុន សែនបានមានប្រសាសន៍ថា «ការដកអភ័យឯកសិទ្ធិតំណាងរាស្ត្ររបស់លោកស្រីមូរ សុខហួរ គឺងាយដូចបកចេកដោយសារថា (បក្សប្រជាជនកម្ពុជា) មានសម្លេងបោះឆ្នោតគ្រប់គ្រាន់»។[66]

## មេធាវីសិទ្ធិមនុស្ស

ចំនួនមេធាវីខ្មែរដែលពេញចិត្តក្នុងការការពារក្ដីពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្សនោះ គឺមានតិចតួចបំផុតដោយសារកម្រិតនៃភាពប្រថុយប្រថានខ្ពស់ហើយមានការបារម្ភពីការសងសឹងជាដើម។ មេធាវីដែលធ្វើការតស៊ូមតិខាងសិទ្ធិមនុស្ស គឺងាយនឹងរងគ្រោះពីហានិភ័យនៃការជាប់ចោទផ្នែកច្បាប់ ឬត្រូវបានគេដកហូតសមាជិកភាពជាមេធាវី។ មេធាវីមិនត្រឹមតែទទួលរងនូវការគំរាមកំហែងតាមរយៈការប្រើប្រាស់ច្បាប់ពីសំណាក់រដ្ឋាភិបាល ឬអ្នកទាំងឡាយដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាលនោះទេ តែពួកគាត់ក៏បានទទួលសំពាធពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ ដើម្បីបំពេញសេចក្ដីបំណងរបស់រដ្ឋាភិបាលនោះ។

កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ គណៈមេធាវីបានប្រកាសថាខ្លួននឹងធ្វើការអនុវត្តន៍ឲ្យបានម៉ត់ចត់ចំពោះបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនក្នុងការគ្រប់គ្រងមេធាវីធ្វើការទំនាក់ទំនងជាមួយប្រព័ន្ធសារព័ត៌មាន។ បទបញ្ជានេះនឹងរារាំងមេធាវីពីការតស៊ូមតិលើករណីក្ដីរបស់ខ្លួន ឬរិះគន់សាលក្រមតាមរយៈបណ្ដាញសារព័ត៌មាន ហើយនឹងប្រឈមបទចោទព្រហ្មទណ្ឌ ក្នុងករណីបំពានលើបទបញ្ជានេះ។[67]

---

[66] ម.ស.ម.ក, «លទ្ធិប្រជាធិបតេយ្យត្រូវបានគេបំបិទមាត់៖ លទ្ធិប្រជាធិបតេយ្យឋិតក្នុងសភាពគ្រោះថ្នាក់» (របាយការណ៍ឆ្នាំ២០១០) http://www.cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=13&id=5
[67] អាប៊ីសេហ្វ និងឆាយច័ន្ទនីដា, «ការបំបិតមាត់កំពុងរីកដុះដាល៖ គណៈមេធាវី» កាសែតឌឹភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១២) ទំព័រទី១។

លោកជួង ជូងី ជាមេធាវីសិទ្ធិមនុស្សនិងរបស់បក្សប្រឆាំងត្រូវបានចោទប្រកាន់ក្រោមមាត្រា ៥៦៥ នៃក្រមព្រហ្មទណ្ឌ កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១ ពីបទជួយកូនក្តីរបស់លោកឲ្យគេចខ្លួនពីពន្ធនាគារខេត្តកណ្តាល។ បទចោទប្រកាន់នេះ ត្រូវបានលើកឡើងឆ្លើយតបនឹងការដោះលែងកូនក្តីរបស់លោកមេធាវី ជួង ជូងី គឺលោកមាស ប៉េងដែលជាអនុមេឃុំបន្ទាយដែក នៃស្រុកគៀនស្វាយខេត្តកណ្តាល ឲ្យចេញពីពន្ធនាគារកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១។ តាមប្រភពតុលាការខេត្តកណ្តាលទង្វើរបស់លោក ជួង ជូងី ក្នុងការជួយឲ្យកូនក្តីរបស់ខ្លួនរត់គេចពីពន្ធនាគារនោះ មិនអនុលោមតាមច្បាប់វិជ្ជាជីវៈរបស់គាត់ទេហើយទង្វើនេះចាត់ទុកថាជាការជួយឲ្យកូនក្តីគេចខ្លួន ដែលនេះជាបទល្មើសព្រហ្មទណ្ឌ។ ផ្ទុយទៅវិញលោក ជួងជូងី បានអះអាងថាគាត់គ្រាន់តែធ្វើតាមច្បាប់ក្នុងការការពារកូនក្តីរបស់គាត់តែប៉ុណ្ណោះ ហើយប្រសិនបើគាត់បានប្រព្រឹត្តកំហុសមែននោះមានតែគណៈមេធាវីទេដែលមានសិទ្ធិក្នុងការកាត់ទោសពីកំហុសវិជ្ជាជីវៈជាមេធាវី។ ដោយយល់ថា លោកជួង ជូងី បានការពារក្តីជាច្រើនដែលកូនក្តីសុទ្ធតែល្បីឈ្មោះ (រាប់បញ្ចូលទាំង លោកសម រង្ស៊ីផងនោះ) ហើយក្នុងករណីនេះ កូនក្តីរបស់គាត់ ជាប់ពាក់ព័ន្ធនឹងករណីជម្លោះដីធ្លីដែលជាបញ្ហាស្មុគស្មាញនៅកម្ពុជានាពេលបច្ចុប្បន្ន ហេតុនេះហើយ ការចោទប្រកាន់ប្រឆាំងនឹងរូបលោក ជាឧទាហរណ៍មួយនៃការគំរាមកំហែងតាមរយៈប្រព័ន្ធតុលាការលើអ្នកអាជីពមេធាវី។[68] លោកជួង ជូងី ត្រូវបានតុលាការខេត្តកណ្តាលកោះហៅសាកសួរកាលពីថ្ងៃទី៥ ខែមីនាឆ្នាំ២០១២ ហើយត្រូវបានដោះលែងវិញដោយឋិតក្រោមការត្រួតពិនិត្យរបស់តុលាការ។ ជាលទ្ធផលលោកត្រូវបានគេរឹតត្បិតខ្លាំងលើសេរីភាពរាប់បញ្ចូលទាំង៖ ត្រូវហាមចេញក្រៅប្រទេស ត្រូវហាមផ្លាស់ប្តូរលំនៅដ្ឋានដោយមិនមានការអនុញ្ញាតពីតុលាការ និងតម្រូវឲ្យបង្ហាញខ្លួនតាមកាលកំណត់របស់ការិយាល័យមន្ត្រីនគរបាល ឬយោធា។

អ្នកតបសម្ភាសន៍ជាច្រើនបានប្រាប់ឲ្យដឹងថារដ្ឋាភិបាលតែងតែទម្លាក់បទចោទវិញ ក្នុងករណីដែលអ្នកទាំងនោះនឹងចុះចូលជាមួយបក្សកាន់អំណាច ស្រដៀងគ្នានឹងករណីរបស់លោកគង់ សំអុន ដូចរៀបរាប់ខាងក្រោម។

**ករណីអ្នកការពារសិទ្ធិមនុស្ស៖លោកគង់ សំអុន**

ករណីរបស់លោក គង់ សំអុន អតីតមេធាវីឲ្យតំណាងរាស្ត្រដ៏ល្បីឈ្មោះ គឺលោកស្រី មូរ សុខហួរ ឆ្លុះឲ្យឃើញនូវវិសាលភាពដែលរដ្ឋាភិបាលមានសមត្ថភាពក្នុងការប្រើប្រាស់ប្រព័ន្ធតុលាការដែលលំអៀង ក្នុងការកាត់ទោសអ្នកការពារសិទ្ធិមនុស្ស និងបំបិទមាត់អ្នករិះគន់ដោយស្របច្បាប់។

ដោយសារតែគាត់បានដើរតួតំណាងមេធាវីឲ្យលោកស្រី មូរ សុខហួរ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩

[68]ម.ស.ម.ក, «ការគំរាមកំហែងតាមរយៈប្រព័ន្ធតុលាការចំពោះមេធាវីការពារក្តីឲ្យសកម្មជនបក្សប្រឆាំង» (សេចក្តីប្រកាសព័ត៌មានបន្ទាន់) (ថ្ងៃទី១ ខែមីនា ឆ្នាំ២០១២)

លោកគង់ សំអុន ត្រូវបានចោទពីបទព្រហ្មទណ្ឌបរិហារកេរ្តិ៍ នៅពេលពេលនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្តឹងតបតវិញ។[69] បន្ថែមលើសពីបណ្តឹងបរិហារកេរ្តិ៍ប្រឆាំងមកលើរូបលោកស្រី មូរ សុខហួរ និងលោក គង់ សំអុន មេធាវីតំណាងឲ្យលោកនាយករដ្ឋមន្ត្រី ក៏បានដាក់បណ្តឹងទៅគណៈមេធាវីប្រឆាំងនឹងលោក គង់ សំអុន ផងដែរ។ គណៈមេធាវី ដែលមានទំនាក់ទំនងជិតស្និតជាមួយសមាជិករបស់គណបក្សកាន់អំណាច បានចាត់វិធានការជំនុំជំរះក្រមវិន័យលើបទចោទប្រកាន់ដែលថាបានបំពានក្រមសីលធម៌មេធាវី ដែលទោសពិន័យអាចឈានដល់ការព្យួរ និងដកហូតសមាជិកភាពជាមេធាវី។[70]

បទចោទប្រឆាំងមកលើរូបលោក គង់ សំអុនត្រូវបានទម្លាក់ចោលវិញកាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩[71] ក្រោយពីលោកបានដកខ្លួនចេញពីតំណាងមេធាវីឲ្យលោកស្រី មូរ សុខហួរ ហើយដោយបានធ្វើការសុំទោសដល់នាយករដ្ឋមន្ត្រីនិងបានចុះចូលជាមួយបក្សប្រជាជនកម្ពុជា។ លោកស្រី មូរ សុខហួរ ដែលបដិសេធធ្វើការសុំទោសលោកនាយករដ្ឋមន្ត្រីនោះត្រូវធ្វើការតស៊ូអស់រយៈពេល៣ឆ្នាំ ទើបអភ័យឯកសិទ្ធិតំណាងរាស្ត្ររបស់លោកស្រីត្រូវបានប្រគល់ជូនវិញ។

## អ្នកសារព័ត៌មាន និងអ្នកជំនាញការខាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅប្រទេសកម្ពុជា គឺត្រូវបានគេរឹតបន្តឹងយ៉ាងខ្លាំង ហើយឋិតក្រោមការគ្រប់គ្រងស្ទើរតែទាំងស្រុងពីសំណាក់គណបក្សប្រជាជនកម្ពុជា។ អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលរាយការណ៍រឿងរសើបតែងត្រូវបានអាជ្ញាធរយាយី។ ពួកគាត់បានប្រឈមនឹងហានិភ័យផ្នែកច្បាប់ និងផ្លូវកាយហើយក្នុងករណីខ្លះរហូតដល់រងគ្រោះថ្នាក់បាត់បង់ជីវិតក៏មាន។[72] ក្លឹបអ្នកកាសែតកម្ពុជា បានកត់ត្រាការចាប់ខ្លួនអ្នកសារព័ត៌មានចំនួន៧រូប ក្នុងឆ្នាំ២០១២។[73]

អង្គការមាត្រា១៩ និង ម.ស.ម.ក បានសម្ភាសន៍អ្នកសារព័ត៌មានដែលបានប្រឈមនឹងគ្រោះថ្នាក់ជាក់ស្តែងជាច្រើន ដូចជាការសម្លុតគំរាមលើផ្លូវកាយ ការទទួលទូរស័ព្ទចូលពីជនអនាមិក ដែលទាំងនេះបានប៉ះពាល់ដល់លទ្ធភាពក្នុងការបំពេញការងារ ហើយជះផលអវិជ្ជមានដល់សុខភាពផ្លូវចិត្ត និងផ្លូវកាយរបស់ពួក

---

[69]អ្នកសង្កេតការណ៍ការពារអ្នកការពារសិទ្ធិមនុស្ស, «កម្ពុជា៖ ការយាយីផ្នែកតុលាការដែលលោក គង់ សំអុន បានប្រឈម» (ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៩) http://www.omct.org/human-rights-defenders/urgent-interventions/cambodia/2008/06/d20068/

[70]ម.ស.ម.ក, «ការវិភាគផ្នែកច្បាប់ស្តីពីករណីក្តីរវាងព្រះរាជាណាចក្រកម្ពុជា និងលោកស្រី មូរសុខហួ (ខែឧសភា ឆ្នាំ២០១០) http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=11&id=5

[71]អង្គការឃ្លាំមើលសិទ្ធិមេធាវីនៃប្រទេសកាណាដា, «លោក គង់ សំអុន៖ ការព្រួយបារម្ភពីឯករាជ្យភាពរបស់មេធាវី (សេចក្តីប្រកាសបន្ទាន់) (ចេញផ្សាយនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៩ និងត្រូវបានធ្វើបច្ចុប្បន្នភាពថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៩) http://www.lrwc.org/kong-sam-onn-concerns-about-independence-of-lawyers/

[72]សូមមើលផែនទីការយាយីដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងផែនទីអ្នកសារព័ត៌មានត្រូវបានគេធ្វើឃាត ដែលមាននៅលើគេហទំព័រសិទ្ធិមនុស្ស ៖http://www.sithi.org/temp.php?url=jour_case.php& និង http://www.sithi.org/temp.php?url=journalists.html&

[73]ការត្រួតពិនិត្យបានកើនឡើង ខណៈដែលសន្ទស្សន៍សេរីភាពសារព័ត៌មាននៅកម្ពុជាធ្លាក់ចុះ» កាសែតឌឹខេមបូឌៀដេលី (ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៣) http://www.cambodiadaily.com/news/censorship-rising-as-cambodia-slips-down-press-freedom-index-8973/

គាត់។ ហានិភ័យដែលលេចធ្លោប្រឆាំងនឹងអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននោះ គឺបទចោទតាមនីតិវិធីច្បាប់ ប៉ុន្តែឧបាយកលមួយផ្សេងទៀតដែលរដ្ឋាភិបាលបានប្រើប្រាស់នោះ គឺការគំរាមកំហែងបិទប្រភពព័ត៌មានឯករាជ្យ ឬក៏ប្រានពួកគាត់រហូតដល់ចំណុចមួយដែលពួកគាត់ត្រូវបង្ខំចិត្តបិទ ដោយសារតែខ្វះប្រិយភាពរបស់អ្នកអាន និងដៃគូផ្នែកហិរញ្ញវត្ថុ។[74] ដោយសារតែលទ្ធផលនៃការឃាឃីនេះទទ្បីករណ៍ជាច្រើនចង្អុលបង្ហាញនូវវប្បធម៌នៃការត្រួតពិនិត្យជាមុនដោយខ្លួនឯងក្នុងចំណោមអ្នកជំនាញការខាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលព្យាយាមជៀសវាងបោះពុម្ពផ្សាយនូវព័ត៌មានដែលរដ្ឋាភិបាលយល់ថាជាការប្រមាថ ឬជាការរសើបផ្នែកនយោបាយ។[75]

**ករណីអ្នកការពារសិទ្ធិមនុស្ស៖លោកម៉ម សូណង់ដូ**

លោក ម៉ម សូណង់ដូប្រធានស្ថានីយ៍វិទ្យុសំបុកឃ្មុំ និងជាប្រធានសមាគមអ្នកប្រជាធិបតេយ្យ ត្រូវបានគេចាប់ខ្លួនកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២។ លោកត្រូវបានគេចោទប្រកាន់ថាបានដឹកនាំឲ្យមានចលនាអបគមន៍នៅខេត្តក្រចេះ។ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៤ ខែកញ្ញា លោកម៉ម សូណង់ដូត្រូវបាននាំខ្លួនមកជំនុំជំរះក្តីនៅសាលាដំបូងរាជធានីភ្នំពេញ ហើយនៅថ្ងៃទី១ ខែតុលា លោកត្រូវបានគេរកឃើញថាមានពិរុទ្ធភាពរាល់បទចោទប្រកាន់ប្រឆាំងមកលើរូបលោកហើយត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល២០ឆ្នាំ។[76]

ការចាប់ខ្លួនរូបលោកម៉ម សូណង់ដូ ត្រូវបានគេជឿថាជាប់ពាក់ព័ន្ធនឹងរបាយការណ៍មួយដែលត្រូវបានគេចាក់ផ្សាយលើស្ថានីយ៍វិទ្យុសំបុកឃ្មុំ ដែលធ្វើការពិភាក្សាលើការទទួលបានពាក្យបណ្តឹងរបស់មន្ត្រីអយ្យការនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៃទំនាក់ទំនងដែលចុះផ្សាយដោយប្រធានចលនាអំណាចពលរដ្ឋខ្មែរ ដែលបានចោទប្រកាន់ពីការជាប់ពាក់ព័ន្ធរបស់រដ្ឋាភិបាលក្នុងករណីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នាយករដ្ឋមន្ត្រីហ៊ុន សែន បានអំពាវនាវឲ្យចាប់ខ្លួនលោក ម៉ម សូណង់ដូ មួយថ្ងៃបន្ទាប់ពីរបាយការណ៍នោះត្រូវបានគេចាក់ផ្សាយ។ នៅពេលមានដីកាចាប់ខ្លួននោះលោក ម៉ម សូណង់ដូ នៅពេលនោះគឺកំពុងនៅបរទេសនៅឡើយដែលលោក

---

[74]ឧទាហរណ៍ ដូចជា ករណីកាសែតដែលមានជំហរទៅរកបក្សប្រឆាំង គឺកាសែតមនសិការខ្មែរ ជាកាសែតដែលមានវ័យចំណាស់ជាងគេបង្អស់ ព្រមទាំងជាកាសែតប្រឆាំងដែលមានឥទ្ធិពលខ្លាំង។ និពន្ធនាយករបស់កាសែតនេះគឺលោកដាំ សិទ្ធិ ត្រូវបានបង្ខំឲ្យបិទកាសែតនេះកាលពីខែកក្កដា ឆ្នាំ២០០៩ ដើម្បីរួចផុតពីការផន្តន្ទាទោសពីបទព្រហ្មទណ្ឌរិះគន់មន្ត្រីរដ្ឋាភិបាល។ កាសែតនេះត្រូវបានបិទកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៩។ បទចោទប្រឆាំងមកលើរូបលោក ដាំ សិទ្ធិនេះត្រូវបានគេរាយការណ៍ថាជាប់ពាក់ព័ន្ធនឹងខ្លឹមសារអត្ថបទជាច្រើនដែលបានបោះពុម្ពផ្សាយក្នុងចន្លោះខែកុម្ភៈនិងខែឧសភា។ ការដែលឈានដល់ការបិទប្រតិបត្តិការកាសែតនេះ គឺធ្វើឡើងបន្ទាប់ពីមានការគំរាមកំហែងធ្ងន់ធ្ងរអស់រយៈពេលមួយឆ្នាំ ពីការកាត់ទោសបទព្រហ្មទណ្ឌកាលដែលបានរិះគន់មន្ត្រីរដ្ឋាភិបាល។ សូមមើលរបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស, «កម្ពុជា៖ បញ្ចប់ការវាយប្រការលើអ្នករិះគន់ប្រឆាំង» (ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩) http://www.hrw.org/news/2009/07/14/cambodia-end-assault-opposition-critics

[75]ម.ស.ម.ក និងអង្គការដទៃទៀត, «កម្ពុជាត្រូវបានបំបិទមាត់៖ លទ្ធិប្រជាធិបតេយ្យឋិតក្នុងសភាពគ្រោះថ្នាក់? (របាយការណ៍) (ខែកញ្ញា ឆ្នាំ២០១០) http://www.article19.org/data/files/pdfs/publications/cambodia-gagged-democracy-at-risk-.pdf

[76]ម.ស.ម.ក, «ម.ស.ម.ក ថ្កោលទោសចំពោះសាលក្រមរកឃើញពិរុទ្ធភាពប្រឆាំងលោកម៉ម សូណង់ដូ ថាជាការកំហុស និងជាក្តីអាម៉ាស់ដល់កិត្តិយសរបស់ប្រទេសកម្ពុជា» (សេចក្តីថ្លែងការណ៍) (ថ្ងៃទី១ ខែតុលា ឆ្នាំ២០១២) http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=293&id=5

កំពុងធ្វើការរាយការណ៍ផ្ទាល់ពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ លោកបានវិលត្រឡប់មកមាតុភូមិវិញនៅថ្ងៃទី១២ ខែកក្កដា ហើយលោកត្រូវបានគេចាប់ខ្លួននៅថ្ងៃបន្ទាប់នោះ។[77]

នេះជាឧបទ្ទវហេតុថ្មីបំផុត ក្នុងចំណោមយុទ្ធនាការសម្លុតគំរាមជាច្រើនប្រឆាំងមកលើរូបលោក ម៉មសូណង់ដូ និងស្ថានីយ៍វិទ្យុសំបុកឃ្មុំ។ កាលពីឆ្នាំ២០០៣អ្នកសារព័ត៌មានរូបនេះ ត្រូវបានគេដាក់ពន្ធនាគារពីបទញុះញង់ឲ្យមានកុប្បកម្មប្រឆាំងនឹងប្រទេសថៃឡងដ៍។ នៅឆ្នាំ២០០៥ លោក ម៉ម សូណង់ដូ ត្រូវបានគេដាក់ពន្ធនាគារម្តងទៀតបន្ទាប់ពីបទសម្ភាសន៍មួយត្រូវបានចាក់ផ្សាយលើវិទ្យុសំបុកឃ្មុំ រិះគន់ពីការពាក់ព័ន្ធរបស់នាយករដ្ឋមន្រ្តី ហ៊ុន សែន ក្នុងការផ្តល់សម្បទានបូរណភាពទឹកដីដល់ប្រទេសវៀតណាម។[78]

បទចោទប្រកាន់ប្រឆាំងមកលើរូបលោក ម៉ម សូណង់ដូជាប់ពាក់ព័ន្ធនឹងជម្លោះដីធ្លីដ៏រ៉ាំរ៉ៃមួយ និងនីតិវិធីបណ្តេញចេញពីដីធ្លីនៅខេត្តក្រចេះ ដែលជាប់ពាក់ព័ន្ធនឹងក្រុមហ៊ុនរុស្ស៊ីមួយឈ្មោះ កាសូទីម។ អ្នកភូមិបានបដិសេធក្នុងការរើចេញពីដីធ្លីនោះក្នុងអំឡុងពេលប្រតិបត្តិការបណ្តេញចេញ ហើយត្រូវបានរដ្ឋាភិបាលចោទប្រកាន់ពីបទធ្វើអបគមន៍ និងផែនការបង្កើតរដ្ឋក្នុងរដ្ឋរបស់សមាគមអ្នកប្រជាធិបតេយ្យ។ មេដឹកនាំនៃចលនាអបគមន៍នៅខេត្តក្រចេះ គឺលោកប៊ុន រដ្ឋាបានអះអាងហើយថាសកម្មភាពទាំងនោះមិនមានទំនាក់ទំនងអ្វីនឹងសមាគមអ្នកប្រជាធិបតេយ្យនោះឡើយ។ លើសនេះទៀត មិនមានភស្តុតាងណាមួយបានបង្ហាញក្នុងការដាក់បន្ទុកដល់ការចោទប្រកាន់ពីបទរៀបចំផែនការអបគមន៍នោះទេ។[79]

បទចោទប្រកាន់ប្រឆាំងមកលើរូបលោក ម៉ម សូណង់ដូនោះគឺៈ ការចូលរួមក្នុងចលនាអបគមន៍ តាមមាត្រា ៤៥៦ និងមាត្រា៤៥៧ នៃក្រមព្រហ្មទណ្ឌ ការញុះញង់ពលរដ្ឋឲ្យកាន់អាវុធប្រឆាំងនឹងអាជ្ញាធរស្របច្បាប់តាមមាត្រា៤៦៤ ការប្រឆាំងនឹងអ្នករាជការសាធារណៈ តាមមាត្រា៥០៤ និងការជ្រៀតជ្រែកដោយខុសច្បាប់ទៅក្នុងការបំពេញមុខងារសាធារណៈតាមមាត្រា៦០៩។ លោក ម៉ម សូណង់ដូក៏ត្រូវបានគេចោទប្រកាន់និងរកឃើញថាមានពិរុទ្ធភាពពីបទផ្តើមគំនិតនូវរាល់បទល្មើសខាងដើម តាមមាត្រា២៨ នៃក្រមព្រហ្មទណ្ឌ ដែលបានឲ្យនិយមន័យដល់អ្នកផ្តើមគំនិតជាបទឧក្រិដ្ឋ ឬបទមជ្ឈិម យោងតាមច្បាប់ជាតិ។[80]

កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ លោក ម៉ម សូណង់ដូ បានដាក់បណ្តឹងសារទុក្ខ ប៉ុន្តែសាលាដំបូងរាជធានីភ្នំពេញខកខានក្នុងការបញ្ជូនករណីនោះទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល១០ថ្ងៃ តាមច្បាប់បានកំណត់ ហើយករណីនេះត្រូវបានពន្យាពេល។ នៅថ្ងៃទី៥ ខែធ្នូឆ្នាំ២០១២ មេធាវីរបស់លោកបានដាក់បណ្តឹងដល់សាលាឧទ្ធរណ៍សុំដោះលែងកូនក្តីឲ្យមានសេរីភាពនៅក្រៅឃុំ តាមមាត្រា ៣០៦ និងមាត្រា៣០៧នៃក្រមនីតិវិធីព្រហ្ម

[77]ម.ស.ម.ក, «ករណីអ្នកការពារសិទ្ធិមនុស្ស លោក ម៉ម សូណង់ដូ» (របាយការណ៍សង្ខេប) (ខែសីហា ឆ្នាំ២០១២) http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=20&id=5

[78]ដូចខាងលើ។

[79]ដូចខាងលើ។

[80]ដូចខាងលើ។

ទណ្ឌ ឆ្នាំ២០០៧។ សាលាឧទ្ធរណ៍នៃរាជធានីភ្នំពេញបានចេញសាលក្រមមួយកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ បដិសេធការដោះលែងលោក ម៉ម សូណង់ដូឲ្យនៅក្រៅឃុំ។[81] ទោះជាយ៉ាងនេះក្តីនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣សាលាឧទ្ធរណ៍បានទម្លាក់បទចោទធ្ងន់ៗជាច្រើនប្រឆាំងមកលើរូបលោកហើយបានសម្រាលទោសពី២០ឆ្នាំទៅនៅត្រឹម៥ឆ្នាំវិញ ដែលទោសពិន័យជាប់ពន្ធនាគារនេះត្រូវបានបង្គ្រប់នឹងពេលវេលាដែលគាត់បានជាប់ឃុំកន្លងមកអស់រយៈពេល៨ខែ ហើយនៅសេសសល់ទាំងប៉ុន្មានគឺត្រូវព្យួរ។[82] លោកម៉ម សូណង់ដូត្រូវបានគេដោះលែងនៅថ្ងៃបន្ទាប់ ប៉ុន្តែលោកឋិតក្រោមការតាមដានរបស់តុលាការនៅឡើយ។

## សកម្មជនសិទ្ធិនៅមូលដ្ឋាន

នៅកម្ពុជា សកម្មជនសិទ្ធិនៅមូលដ្ឋានភាគច្រើន ជាសកម្មជនដីធ្លី។ ហានិភ័យមកលើសកម្មជនសិទ្ធិដីធ្លីនៅមូលដ្ឋានជាទូទៅ បណ្តាលមកពីការគិតប្រយោជន៍ផ្ទាល់ខ្លួនរបស់រដ្ឋាភិបាលលើដីសម្បទាន ហើយក៏បណ្តាលមកពីកម្រិតនៃការតស៊ូមតិដែលបានផុសផុលដោយសារការបណ្តេញចេញពីដីធ្លី។ មូលហេតុមួយទៀតដែលបង្កជាហានិភ័យដល់សកម្មជនសហគមន៍មូលដ្ឋាន គឺភាពនៅដាច់ស្រយាលរបស់សហគមន៍ទាំងនោះដែលនេះមានន័យថា តំបន់ទាំងនោះនៅឆ្ងាយពីអង្គការមិនមែនរដ្ឋាភិបាលនិងបណ្តាញសារព័ត៌មាន។

អ្នកការពារសិទ្ធិមនុស្ស ដែលមកពីសហគមន៍ដែលរងផលប៉ះពាល់ពីការបំពានយកដីធ្លីបានប្រាប់ដល់អង្គការមាត្រា១៩ និង ម.ស.ម.ក ថារាល់សកម្មភាពបាតុកម្មរបស់ពួកគាត់តែងប្រឈមនឹងដំបងឆក់ ឧស្ម័នបញ្ចេញទឹកភ្នែក ទឹកពន្លត់អគ្គីសភ័យ ដំបងនិងការវាយដំពីសំណាក់អាជ្ញាធរ។ ជាងនេះទៀត សកម្មជនដីធ្លីបានរាយការណ៍ ថាមានការគំរាមកំហែងតាមរយៈទូរស័ព្ទ និងការតាមដានពិនិត្យជាញឹកញាប់ពីសំណាក់នគរបាល ឬមនុស្សមិនស្គាល់អត្តសញ្ញាណជិះម៉ូតូ ហើយពេលខ្លះមានប្រដាប់ដោយអាវុធផងដែរ។ ការគំរាមកំហែងក៏បានកើតឡើងចំពោះកូនៗរបស់អ្នកការពារសិទ្ធិមនុស្សនៅមូលដ្ឋាន ដែលភាគច្រើននេះជាយុទ្ធសាស្ត្ររបស់អាជ្ញាធរប្រើប្រាស់ចំពោះស្ត្រីការពារសិទ្ធិមនុស្ស។ ដូចបានរៀបរាប់ខាងដើម សកម្មជនដីធ្លីចំនួន២០១នាក់ត្រូវបានគេចាប់ខ្លួនកាលពីឆ្នាំ២០១២មកនេះ។

ការមិនអធ្យាស្រ័យរបស់រដ្ឋាភិបាលចំពោះភាពសកម្មរបស់សកម្មជនមូលដ្ឋាន ត្រូវបានបង្ហាញឲ្យឃើញច្បាស់តាមរយៈប្រតិកម្មរបស់អាជ្ញាធរទៅលើសន្និបាតពលរដ្ឋមូលដ្ឋានអាស៊ាន។ សន្និបាតនេះត្រូវបានប្រឈមនឹងការរាំងពីសំណាក់រដ្ឋាភិបាល ខណៈពេលរៀបចំសិក្ខាសាលានិងសកម្មភាពផ្សេងៗទៀតពាក់ព័ន្ធ

[81] ម.ស.ម.ក, «ម.ស.ម.កសំដែងនូវការខកចិត្តយ៉ាងខ្លាំងចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ក្នុងការបដិសេធការសុំដោះលែងឲ្យនៅក្រៅឃុំរបស់អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សគឺលោកម៉មសូណង់ដូ» (ថ្ងៃទី១៤ខែធ្នូឆ្នាំ២០១២) http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=326&id=5

[82] ម.ស.ម.ក, «ម.ស.ម.កស្វាគមន៍ចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ដែលបានដោះលែងលោក ម៉មសូណង់ដូប៉ុន្តែបានសង្កេតឃើញថាសាលក្រមនេះជាឧទាហរណ៍សាមញ្ញមួយនៃការគ្រប់គ្រងប្រទេសដោយច្បាប់ ជាជាងនិតិរដ្ឋ» (សេចក្តីថ្លែងការណ៍) (ថ្ងៃទី២០ខែមិនាឆ្នាំ២០១៣) http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=371&id=5

នឹងកិច្ចប្រជុំកំពូលអាស៊ានដែលរៀបចំនៅទីក្រុងភ្នំពេញ ពីថ្ងៃទី១៨ ដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១២។[83] នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២ចំពេលកម្មវិធីបើកនៃសន្និបាតពលរដ្ឋមូលដ្ឋានអាស៊ាន ដែលត្រូវបានរៀបចំនៅភោជនីយដ្ឋានមួយហើយមានអ្នកចូលរួមជាង១៥០០នាក់នោះត្រូវបានគេរំខាន ដោយប្រព័ន្ធអគ្គីសនីនៅទីតាំងនោះត្រូវបានគេកាត់ផ្តាច់។ យោងតាមអ្នកនាំពាក្យរបស់សន្និបាតនោះបានប្រាប់ឲ្យដឹងថាម្ចាស់ភោជនីយដ្ឋានត្រូវបានអាជ្ញាធរមូលដ្ឋានគាបសង្កត់ឲ្យរំខាននិងលុបចោលនូវការទទួលរៀបចំព្រឹត្តការណ៍នេះ។[84] លើសនេះទៀតសិក្ខាសាលានៃសន្និបាតពលរដ្ឋមូលដ្ឋានអាស៊ានដែលគ្រោងនឹងចាប់ផ្តើមនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ ត្រូវបានគេលុបចោលលែងជួលទីតាំងឲ្យនៅនាទីចុងក្រោយហើយមានអ្នកចូលរួមជាង២៥០នាក់ត្រូវបានផ្ទះសំណាក់ជាច្រើននៅទីក្រុងភ្នំពេញមិនជួលបន្ទប់ឲ្យ ដោយសារទទួលនូវគំនាបពីសំណាក់អាជ្ញាធរមូលដ្ឋានដែលត្រូវបានគេមើលឃើញថាបានយាយីដល់ម្ចាស់ផ្ទះសំណាក់។[85] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ អ្នករៀបចំកម្មវិធីជួបជុំនោះបានដាក់សំណើទៅរដ្ឋាភិបាល ដែលជាប្រធានអាស៊ាននាពេលនោះពីការដែលសេចក្តីជូនដំណឹងរបស់ខ្លួនត្រូវបានសាលាក្រុងនិងក្រសួងមហាផ្ទៃបដិសេធ។ យោងតាមសន្និបាតពលរដ្ឋមូលដ្ឋានអាស៊ានរដ្ឋាភិបាលក៏បានព្រមានដល់ពួកគាត់ថាអ្នកណាដែលនឹងចូលរួមក្នុងការធ្វើបាតុកម្មជាសាធារណៈ ក្នុងអំឡុងកិច្ចប្រជុំកំពូលអាស៊ាន នឹងត្រូវចាប់ខ្លួន។[86]

ព្រឹត្តិការណ៍សង្គមស៊ីវិលដទៃទៀតគឺសន្និសីទសង្គមស៊ីវិលអាស៊ាន/វេទិកាពលរដ្ឋអាស៊ាន ដែលរៀបចំនៅថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែវិច្ឆិកាត្រូវបានគេរាយការណ៍ថាប្រឈមនឹងការរំខាននិងត្រូវបានផ្លាស់ប្តូរទីតាំងរៀបចំកម្មវិធីពីរដងដោយសារមានការសម្លុតគំរាម។ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជាបានរាយការណ៍ថាអ្នករៀបចំកម្មវិធីជាច្រើនបានទទួលរងនូវការព្រមានដោយមានការកត់ត្រាឈ្មោះនិងថតរូប ឬមួយក៏ទីតាំងរៀបចំកម្មវិធីត្រូវបានគេលុបចោល។[87]

ក្នុងពេលជាមួយគ្នានោះដែរនៅភូមិថ្មគោលជិតព្រលានយន្តហោះអន្តរជាតិភ្នំពេញ អាជ្ញាធរបានចាប់ខ្លួនអ្នកភូមចំនួន៨នាក់ ក្នុងនោះស្ត្រី៦នាក់និងបុរស២នាក់ ដែលបានផ្តួចផ្តើមគូសលាបអក្សរ «អេស.អូ.អេស (ជួយផង)»នៅលើដំបូលរបស់ខ្លួន ក្នុងគោលបំណងសូមឲ្យប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា

[83]ហ្វ្រូនឡាញ, «កម្ពុជាៈព្រឹត្តការណ៍សង្គមស៊ីវិលត្រូវបានអាជ្ញាធររារាំងមុនពេលកិច្ចប្រជុំកំពូលអាស៊ានឋិតជិតមកដល់» (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១២) http://www.frontlinedefenders.org/node/20836

[84]ដូចខាងលើ។

[85]ដូចខាងលើ។

[86]ដូចខាងលើ។

[87]អង្គការសង្គមស៊ីវិលជាច្រើន, «កម្ពុជាៈបញ្ឈប់ការរំខានព្រឹត្តការណ៍សង្គមស៊ីវិលនិងការរឹតត្បិតលើសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំ មុនពេលកិច្ចប្រជុំកំពូលអាស៊ានឈានចូលមកដល់» (សេចក្តីថ្លែងការណ៍) (ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២) http://www.forum-asia.org/?p=15599។ សូមមើលអត្ថបទរបស់ សៃមុនឡេវីសនិងឃួនណារិម, «ការសម្លុតគំរាមដល់អង្គការមិនមែនរដ្ឋាភិបាលបន្តមុនពេលកិច្ចប្រជុំកំពូលអាស៊ាន» កាសែតឌឹខេមបូឌៀដេលី (ភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២) http://www.cambodiadaily.com/news/intimidation-of-civil-society-groups-continues-before-summits-5627/

ដែលនឹងធ្វើទស្សកិច្ចមកទីក្រុងភ្នំពេញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន ធ្វើការស្នើសុំដល់រដ្ឋាភិបាលកម្ពុជាឲ្យបញ្ឈប់នូវការបណ្ដេញចេញ។[88]

**ករណីអ្នកការពារសិទ្ធិមនុស្ស៖ លោកឈុត វុទ្ធី**

កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ សកម្មជនមូលដ្ឋានខាងបរិស្ថាន លោកឈុត វុទ្ធី ត្រូវបានមន្ត្រីយោធាបាញ់សម្លាប់ នៅក្នុងខេត្តកោះកុង ខណៈពេលដែលលោកកំពុងតែថតរូបការកាប់ឈើខុសច្បាប់។[89] លោក ឈុត វុទ្ធីបានអមដំណើរអ្នកកាសែតចំនួនពីររូប ទៅកាន់តំបន់កាប់ព្រៃឈើខុសច្បាប់ ខណៈពេលនោះ យានជំនិះរបស់លោកត្រូវបានមន្ត្រីយោធាបញ្ឈប់ ហើយបញ្ជាឲ្យលោកប្រគល់មេម៉ូរីកាតពីម៉ាស៊ីនថតរូបរបស់លោកឲ្យទៅគេ។ លោកបដិសេធមិនព្រមធ្វើតាមបញ្ជា ហើយជាលទ្ធផល លោកត្រូវបានគេបាញ់សម្លាប់។ មន្ត្រីយោធាឈ្មោះ អ៊ិន រតនា ក៏ត្រូវបានសម្លាប់ដោយការបាញ់ប្រហារនៅក្នុងព្រឹត្តិការណ៍នោះដែរ។ អ្នកកាសែតចំនួនពីរនាក់ត្រូវបានឃុំខ្លួន និងក្នុងពេលដែលពួកគេត្រូវបានឃុំខ្លួនពួកគេបានឮមន្ត្រីយោធានិយាយគ្នាពីការចង់សម្លាប់ពួកគេដើម្បីបំបិទព្រឹត្តិការណ៍នេះ។[90] សំណាងល្អ ពួកគេត្រូវបានដោះលែងវិញ។

ការពន្យល់ពីមន្ត្រីរដ្ឋាភិបាលចំពោះព្រឹត្តិការណ៍នេះមានភាពច្របូកច្របល់ និងមានលក្ខណៈចម្រូងចម្រាស់។ អ្នកនាំពាក្យក្រសួងមហាផ្ទៃលោកខៀវ សុភ័ក្ត្រ ដែលបានស៊ើបអង្កេតព្រឹត្តិការណ៍នេះ អះអាងថាមន្ត្រីយោធាបានប្រាប់លោកថាលោកឈុត វុទ្ធី ជាអ្នកបាញ់មុន។[91] អ្នកនាំពាក្យ លោកខេង ទីតូ បានអះអាងថា លោក ឈុត វុទ្ធី មានកាំភ្លើងជាប់ខ្លួន ប៉ុន្តែមិនអាចនិយាយបានថាតើលោកឈុត វុទ្ធីបានប្រើអាវុធរបស់គាត់ឬក៏អត់ ហើយប្រសិនបើដូច្នេះមែនគាត់គឺជាអ្នកចាប់ផ្ដើមមុន។[92] ប៉ុន្តែលោក ខេង ទីតូ អះអាងថាលោកអ៊ិន រតនា "បានធ្វើតាមភារកិច្ចរបស់គាត់" ពេលដែលគាត់បាញ់លោកឈុត វុទ្ធី។[93] ស្នង

---

[88] សន្និបាតពលរដ្ឋមូលដ្ឋានអាស៊ាន, «សេចក្ដីថ្លែងការណ៍បន្ទាន់ និងសេចក្ដីថ្លែងការណ៍រួមរបស់សន្និបាត ចុះថ្ងៃទី១៥ ខែវិច្ឆិកា» (ភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២) http://aseanagpa.wordpress.com/2012/11/15/statement-for-immediate-release-agpas-joint-statement-november-15/

[89] May Titthara and David Boyle, 'Environmental activist Chut Wutty shot dead' *The Phnom Penh Post* (27 April 2012) <http://www.phnompenhpost.com/2012042655803/National/environmental-activist-chut-wutty-shot-dead.html>

[90] Olesia Plokhii, 'Murders in the Forest' *Reuters* (20 September 2012) <http://blogs.reuters.com/great-debate/2012/09/20/murders-in-the-forest/>

[91] Saing Soenthrith and Abby Seiff, 'Chut Wutty, Prominent Environmental Activist, Shot Dead in Koh Kong' *The Cambodia Daily* (26 April 2012) <http://www.cambodiadaily.com/news/chut-wutty-prominent-environmental-activist-shot-dead-in-koh-kong-1816/>

[92] ម៉ៃទិត្យថារ៉ានិងដាវីដប៊ិលយ៍ 'សកម្មជនបរិស្ថានលោកឈុតវុទ្ធីត្រូវបានបាញ់ស្លាប់'សារព័ត៌មានឌឹភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២) <http://www.phnompenhpost.com/2012042655803/National/environmental-activist-chut-wutty-shot-dead.html>

[93] 'នគរបាលកម្ពុជាបាញ់សម្លាប់អ្នកតស៊ូមតិប្រឆាំងការកាប់ឈើខុសច្បាប់'សារព័ត៌មានឌឹហ្គាឌៀន (ទីក្រុងឡុងដ៍ខែមេសា ឆ្នាំ២០១២) <http://www.guardian.co.uk/world/2012/apr/26/cambodia-police-shoot-dead-antilogging-activist>

ការនគរបាលរងខេត្ត លោកស៊ិន សេនអះអាងថាលោកអ៊ិន រតនាបានបាញ់ លោក ឈុត វុទ្ធីនិងបន្ទាប់មកសម្លាប់ខ្លួនឯង។[94] អ្នកស៊ើបអង្កេតរបស់អង្គការសម្ព័ន្ធខ្មែរជំរឿនដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស (លីកាដូ) បានសន្និដ្ឋានថា លោកអ៊ិន រតនា បានបាញ់កាំភ្លើង ពេលដែលលោក ឈុតវុទ្ធីព្យាយាមបើកឡានគេច បណ្តាលឲ្យបាញ់លោកឈុត វុទ្ធីស្លាប់ហើយលោកអ៊ិនរតនាក៏ត្រូវបានសម្លាប់ដោយសារតែគ្រាប់ផ្លាតចេញពីកាំភ្លើងរបស់រូបលោក។[95]

ការស៊ើបអង្កេតលើព្រឹត្តិការណ៍ថ្ងៃទី២៦ ខែមេសា មានភាពមិនប្រក្រតីជាច្រើន។ កាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០១២ ក្នុងសវនាការដែលមានរយៈពេល៩០នាទី តុលាការខេត្តកោះកុងបានខកខានមិនបានពិចារណាលើភស្តុតាងជាក់ស្តែង តែផ្ទុយទៅវិញពឹងលើកំណត់ហេតុដែលចម្រូងចម្រាស់និងមិនច្បាស់លាស់របស់សាក្សីដែលជាច្រើនរូបមិនបានបង្ហាញខ្លួនពេលសួរចម្លើយ។[96] តុលាការក៏ខកខានមិនបានពិចារណាពីតួនាទីរបស់ក្រុមហ៊ុន ធីមប៊ឺគ្រីន ក្នុងព្រឹត្តិការណ៍នេះផងដែរ ទោះបីជាលោកខេងទីតូបាននិយាយអះអាងកាលពីខាងដើមថា នគរបាលបានរារាំង លោកឈុតវុទ្ធីដោយសារតែសំណើរបស់ក្រុមហ៊ុន។[97] កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ចៅក្រមតុលាការខេត្ត បានសន្និដ្ឋានថា លោកអ៊ិនរតនាត្រូវបានស្លាប់ដោយសារកាំភ្លើងរាលកៃ ក្នុងពេលប្រតាយប្រតប់ជាមួយលោក រ៉ាន់ បូរ័ត្ន ជាសន្តិសុខឯកជនដែលជួលដោយ ក្រុមហ៊ុនធីមប៊ឺគ្រីន ដែលព្យាយាមដកហូតកាំភ្លើងរបស់លោក អ៊ិន រតនា។[98] សេចក្តីសម្រេចរបស់តុលាការត្រូវបានប្រកាស ទោះបីជាខ្វះខាតនូវភស្តុតាង និងមិនមានមូលហេតុច្បាស់លាស់ថាហេតុអ្វីបានជា លោក អ៊ិន រតនាសម្លាប់លោកឈុត វុទ្ធី មុនពេលលោក រ៉ាន់ បូរ័ត្នធ្វើអន្តរាគម។ លោក រ៉ាន់ បូរ័ត្នត្រូវបានរកឃើញថាធ្វើបែបនេះដើម្បីការពារខ្លួន និងត្រូវផ្តន្ទាទោសរយៈពេល២ឆ្នាំក្នុងពន្ធនាគារ។ បីភាគបួននៃទោសរបស់លោកត្រូវបានព្យួរ។ ដោយសារតែជនសង្ស័យថាជាឃាតករស្លាប់ទៅហើយ ការស៊ើបអង្កេតជាច់ដោយឡែក មកលើការសម្លាប់ លោកឈុត វុទ្ធីត្រូវបានទម្លាក់ចោល។

---

94 អូលេស៊ីប្លូគី'ការសម្លាប់ក្នុងព្រៃ'រ៉យទ័រ(ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២) <http://blogs.reuters.com/great-debate/2012/09/20/murders-in-the-forest/>

95 ម៉ៃទិត្យថារ៉ាំនិងដាវីដបិលយ៍ 'សកម្មជនបរិស្ថានលោកឈុត វុទ្ធីត្រូវបានបាញ់ស្លាប់'សារព័ត៌មានឌឹភ្នំពេញប៉ុស្ដិ៍ (ថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០១២) <http://www.phnompenhpost.com/2012042655803/National/environmental-activist-chut-wutty-shot-dead.html>

96 លីកាដូ 'សេចក្តីសន្និដ្ឋាននៃករណីចំនួនពីរដែលពាក់ព័ន្ធនឹង ការសម្លាប់ លោកឈុត វុទ្ធីបន្សល់នូវចម្ងល់ជាជាងចម្លើយ' (សេចក្តីថ្លែងការណ៍) (ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២) <http://www.licadho-cambodia.org/pressrelease.php?perm=293>

97 ម៉ៃទិត្យថារ៉ាំនិងដាវីដបិលយ៍ 'សកម្មជនបរិស្ថានលោកឈុត វុទ្ធីត្រូវបានបាញ់ស្លាប់'សារព័ត៌មានឌឹភ្នំពេញប៉ុស្ដិ៍ (ថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០១២) <http://www.phnompenhpost.com/2012042655803/National/environmental-activist-chut-wutty-shot-dead.html>

98 វិជ័យ អាណន្ទ"ការបញ្ចប់យ៉ាងឆាប់រហ័សលើសវនាការឃាតកម្ម"(វិទ្យុអាស៊ីសេរីថ្ងៃទី៤ខែតុលាឆ្នាំ២០១២) http://www.rfa.org/english/news/cambodia/chut-wutty-10042012160930.html

គណៈដឹកនាំសង្ឃនៅកម្ពុជាត្រូវបានជឿថាមានទំនាក់ទំនងជាមួយនឹងគណបក្សប្រជាជនកម្ពុជា មានន័យថាក្នុងការអនុវត្តន៍ជាក់ស្តែង ព្រះសង្ឃត្រូវហាមឃាត់មិនឲ្យចូលរួមសកម្មនិយមនយោបាយ។[99] ប៉ុន្តែ ព្រះតេជគុណលួន សុវ៉ាត ដែលជាសកម្មជនមូលដ្ឋានដ៏លេចធ្លោ ត្រូវបានដៅមុខសញ្ញានៃការគំរាមកំហែងដោយសារតែសកម្មនិយមដីធ្លី និងការងារសិទ្ធិមនុស្សរបស់ព្រះតេជគុណ។ ព្រះតេជគុណលួន សុវ៉ាតត្រូវបានគេហាមឃាត់មិនឲ្យស្នាក់នៅក្នុងវត្តអារាមនានានៅក្នុងទីក្រុងភ្នំពេញ។ ព្រះតេជគុណត្រូវបានគេប៉ុនប៉ងចាប់ខ្លួនម្តងក្នុងខែមេសា ឆ្នាំ២០១១ ពេលព្រះតេជគុណចូលរួមក្នុងការប្រមូលផ្តុំដោយសន្តិវិធី ដែលមានក្រុមអង្គការសង្គមស៊ីវិល សារព័ត៌មាន និងសកម្មជនបឹងកក់ចូលរួមនៅមុខសាលារាជធានីភ្នំពេញ។ ព្រះតេជគុណបានគេចខ្លួនយ៉ាងប្រកិត ពេលបាតុករដទៃទៀតបានប្រមូលផ្តុំជុំវិញខ្លួនព្រះតេជគុណ និងដើរហែហមព្រះអង្គឲ្យចាកចេញដោយសុវត្ថិភាព។[100] ករណីបឹងកក់នឹងត្រូវបានរៀបរាប់លម្អិតបន្ថែមខាងក្រោម។ ព្រះតេជគុណ លួនសុវ៉ាត ត្រូវបានចាប់ឃុំខ្លួនមួយរយៈពេលខ្លី កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ បន្ទាប់ពីត្រូវបានចាប់ខ្លួននៅក្នុងបាតុកម្មរបស់សកម្មជនបឹងកក់ធ្វើឡើងនៅក្រៅតុលាការរាជធានីភ្នំពេញ ដើម្បីទាមទារឲ្យមានការដោះលែងស្ត្រីសកម្មជនចំនួន១៣នាក់។[101] អាជ្ញាធរត្រូវបានគេអះអាងថាបានប៉ុនប៉ងបញ្ចុះបញ្ចូលព្រះតេជគុណឲ្យចុះហត្ថលេខាលើឯកសារដែលបញ្ជាក់ថា ព្រះតេជគុណនឹងមិនបន្តកិច្ចការងារផ្នែកតស៊ូមតិរបស់ព្រះតេជគុណនោះទេ។ ព្រះតេជគុណលួនសុវ៉ាត បដិសេធមិនចុះហត្ថលេខា ទោះបីជាមានការគំរាមកំហែងចាប់ព្រះតេជគុណផ្សឹកក៏ដោយ។[102]

## សកម្មជនសហជីព

តាមស្តង់ដារអន្តរជាតិ កម្មកររោងចក្រនៅកម្ពុជា គឺនៅក្នុងចំណោមបុគ្គលដែលទទួលបានប្រាក់ឈ្នួលទាបបំផុតក្នុងឧស្សាហកម្មការងាររបស់ពួកគេ។ ក្នុងខែកញ្ញា ឆ្នាំ២០១០ សកម្មជនសហជីពចំនួន២៦១នាក់មកពីរោងចក្រ ២០ផ្សេងៗគ្នាត្រូវបានបញ្ឈប់ការងារដោយខុសច្បាប់ ឬព្យួរការងារដោយគ្មានការប្តឹងជំទាស់ដោយសារតែលទ្ធផលនៃការធ្វើបាតុកម្ម។[103] ទោះបីជាបានផ្តល់ដំណឹងបានមុនពេលវេលា ទៅកាន់រដ្ឋាភិបាល

---

[99] ‘ព្រះសង្ឃដែលត្រូវចាប់ផ្សឹក ថ្កោលទោសចំពោះការសម្រេចដោយ‘លម្អៀង’’, វិទ្យុអាស៊ីសេរី(ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២) <http://www.rfa.org/english/news/cambodia/defrocked-05222012162403.html/>

[100] អ្នកការពារនៅជួរមុខ ‘កម្ពុជា ៖ ការយាយីមកលើអ្នកការពារសិទ្ធិមនុស្ស ព្រះតេជគុណលួនសុវ៉ាត’ (ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២) <http://www.frontlinedefenders.org/node/18467>

[101] ‘ព្រះសង្ឃដែលជាសកម្មជនត្រូវបានឃុំខ្លួនក្នុងវត្តបទុម’, សារព័ត៌មាន ឌឹភ្នំពេញប៉ុស្តិ៍( ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២) <http://www.phnompenhpost.com/2012052556389/National/activist-monk-detained-at-wat-botum.html>ខែកុម្ភៈ ឆ្នាំ២០១៣។ សូមអាន ម.ស.ម.ក ‘ថ្ងៃនៃការបង្ក្រាប– សកម្មជនបឹងកក់ចំនួន១៣នាក់ត្រូវបានចាប់ខ្លួនខណៈពេលដែល “ព្រះសង្ឃពហុប្រព័ន្ធសារព័ត៌មាន″ ត្រូវបានចាប់ឃុំនិងចាប់ផ្សឹក’ (សេចក្តីប្រកាសព័ត៌មានបន្ទាន់) (ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=22&id=5>

[102] អ្នកការពារនៅជួរមុខ‘កម្ពុជា៖ការយាយីមកលើអ្នកការពារសិទ្ធិមនុស្សព្រះតេជគុណលួនសុវ៉ាត’ (ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២) <http://www.frontlinedefenders.org/node/18467>

[103] យុទ្ធនាការសម្លៀកបំពាក់ស្អាតស្អំ‘ថ្នាក់ដឹកនាំសហជីពប្រហែលជាង២០០នាក់ត្រូវបានព្យួរការងារឬបញ្ឈប់ការងារដោយខុសច្បាប់បន្ទាប់ពីកូដកម្មទ្រង់ទ្រាយធំបានបញ្ចប់’ (ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០) <http://www.cleanclothes.org/news/2010/09/24/over-200-cambodian-trade-union-leaders-suspended-or-illegally-dismissed-after-mass-strike-ends>

ក៏ដូចជាធានាថាបាតុកម្មរបស់ពួកគេ នឹងអនុវត្តទៅតាមតម្រូវការនៃការធ្វើបាតុកម្មដោយស្របច្បាប់ ប៉ុន្តែអ្នករៀបចំបាតុកម្មមួយចំនួន ទទួលរងការគំរាមកំហែងផ្នែកច្បាប់ និងអំពើហិង្សាដោយសារបានបង្កឲ្យមានបាតុកម្មកើតឡើង។រោងចក្រចំនួន១០ បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងអ្នកដឹកនាំសហជីព ហាមមិនឲ្យពួកគេធ្វើការងារបន្ត។ ជាលទ្ធផលបាតុកម្មកាន់តែច្រើនបានកើតឡើង។ជាចុងក្រោយ លោកនាយករដ្ឋមន្ត្រី ហ៊ុនសែន បានធ្វើអន្តរាគមន៍ បញ្ជាឲ្យរោងចក្រទម្លាក់បទចោទប្រកាន់ និងបញ្ជាឲ្យបាតុករទាំងអស់ត្រលប់ទៅធ្វើការវិញ។

ចាប់ពីថ្ងៃទី១៣ដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១កម្មកររោងចក្រចំនួន២០០,០០០នាក់បានធ្វើបាតុកម្មដើម្បីទាមទារឲ្យមានការតម្លើងប្រាក់ខែ។ ស្ថានភាពនេះមិនទាន់ប្រសើរឡើងនោះទេ រហូតមកដល់ឆ្នាំ២០១២។ អាជ្ញាធរបន្តសម្លុតបំភ័យ យាយីមកលើរូបរាងកាយនិងប្រើប្រាស់វិធានការផ្នែកច្បាប់ប្រឆាំងនឹងសកម្មជនសហជីពនិងសកម្មជនដទៃទៀត។ ក្នុងឆ្នាំ២០១២ ក្នុងចំណោមបាតុកម្មចំនួន៨៧ដែល ម.ស.ម.ក បានតាមដានមានករណី១៧បាតុកម្មដែលបាតុកររងការរំលោភបំពានពីនគរបាល ទាហានអាជ្ញាធរមូលដ្ឋានឬម្ចាស់រោងចក្រ។[104] ឧទាហរណ៍ ក្នុងខែកក្កដាឆ្នាំ២០១២ នគរបាលបានវាយដំមកលើសកម្មជនគឺលោក វ៉ុង បញ្ញាមុននឹងចាប់ខ្លួនលោកនិងឃុំខ្លួនលោក ព្រោះតែលោកបានចូលរួមក្នុងបាតុកម្មទាមទារសិទ្ធិជាមួយក្រុមកម្មករ។ ក្រោយមកក្នុងថ្ងៃដដែល លោកត្រូវបានគេដោះលែងវិញ ដោយមិនត្រូវបានគេចោទប្រកាន់ពីបទព្រហ្មទណ្ឌនោះទេ។[105] នគរបាលដែលបានវាយដំមកលើរូបលោកមិនត្រូវបានដាក់ទណ្ឌកម្មសោះឡើយ។

កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ស្ត្រីបីនាក់រងការបាញ់ប្រហារ និងរងគ្រោះយ៉ាងធ្ងន់ធ្ងរក្នុងបាតុភាពបាតុកម្មមួយនៅរោងចក្រកៅវ៉េយ៍ស្ពត នៅក្រុងបាវិត ក្នុងតំបន់សេដ្ឋកិច្ចពិសេសម៉ាតហាថាន ខេត្តស្វាយរៀង។ លោកឈូក បណ្ឌិតអតីតអភិបាលក្រុង ដែលកាលពីដំបូងបានសារភាពថាបាញ់ប្រហារទៅលើក្រុមអ្នកធ្វើបាតុកម្ម ប៉ុន្តែក្រោយមកទៀតប្រានចោលចម្លើយនោះ។[106] ខណៈពេលដែលតុលាការទម្លាក់រឿងក្តីនេះចោលក្នុងខែធ្នូ រឿងក្តីនេះត្រូវបានសាលាឧទ្ធរណ៍នៃរាជធានីភ្នំពេញទទួលរយៈពេលបីខែក្រោយមក ប៉ុន្តែ ថ្ងៃកំណត់សវនាការរបស់លោកត្រូវបានពន្យាពេលម្តងហើយម្តងទៀត និងមិនទាន់មានការកាត់សេចក្តីនៅឡើយ។ ប្រសិនបើគិតមើលពីពេលវេលាក្នុងការស្វែងរកយុត្តិធម៌លើករណីនេះ ទោះបីជាមានភស្តុតាងច្បាស់ៗដាក់បន្ទុកលើជនជាប់ចោទក៏ដោយតែជនរងគ្រោះក៏ដូចជាអង្គការសិទ្ធិមនុស្សនៅមិនទាន់ជឿជាក់ថា លទ្ធផលនៃសវនាការនេះនឹងមានភាពយុត្តិធម៌នោះទេ។[107]

---

[104]ទិន្នន័យដែលមិនបោះពុម្ពផ្សាយ ប្រមូលដោយ ម.ស.ម.ក។

[105]ម.ស.ម.ក ‘ការឆ្លើយតបដោយអំពើហិង្សាចំពោះការធ្វើបាតុកម្មរបស់កម្មករ’ (សលាកប័ត្រព័ត៌មាន) (ខែកក្កដា ២០១២) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=52&id=5>

[106]ម៉ែនគឹមសេង ‘វិសមភាពយេនឌ័របានរកឃើញក្នុងករណីបាញ់ប្រហារនៅបាវិត’ សំឡេងអាមេរិក| ខ្មែរ(ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ) <http://www.voacambodia.com/content/cambodia-gender-inequality-seen-in-bavet-shooting-case/1573588.html>

[107]ម៉ៃ ទិត្យថារ៉ា “លើកទី២ ក្នុងករណីបណ្ឌិត ដែលត្រូវបានជាប់គាំងកាលពីខែឧសភា” សារព័ត៌មាន ឌឹភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣) <http://www.phnompenhpost.com/2013042565227/National/round-2-in-bandith-case-locked-for-may.html>

អ្វីដែលសំខាន់ដូចបានរៀបរាប់ពីខាងដើម ប្រទេសកម្ពុជា កំពុងរង់ចាំការអនុម័តនៃសេចក្តីស្នើច្បាប់ស្តីពីសហជីព ដែលនឹងអនុញ្ញាតឲ្យកម្មករក្រៅប្រព័ន្ធ ដូចជាម៉ូតូរ៉ឺម៉កកង់បីនិងអ្នករត់ម៉ូតូឌុប អាចបង្កើតសហជីពបាន។ សេចក្តីព្រាងច្បាប់ស្តីពីសហជីព ដែលត្រូវដាក់ស្នើក្នុងឆ្នាំ២០១១ និងបច្ចុប្បន្នកំពុងតែស្ថិតនៅគណៈរដ្ឋមន្ត្រីនៃក្រសួងការងារ។ ហាក់ដូចជា មានការស្នាក់ស្ទើរពីសំណាក់រដ្ឋាភិបាលក្នុងការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីសហជីពដែលនឹងអនុញ្ញាតឲ្យកម្មករក្រៅប្រព័ន្ធអាចរួមគ្នាជាសហជីពនិងអាចមានការចរចាជាសមូហភាពដើម្បីទាមទារលក្ខខណ្ឌការងារប្រសើរជាងមុន។[108] សកម្មជនសហជីពខ្លះទៀតក៏បានលើកឡើងពីការព្រួយបារម្ភថាសេចក្តីព្រាងអាចនឹងកាត់បន្ថយសិទ្ធិរបស់សហជីពនិងមិនគោរពតាមបទដ្ឋានសិទ្ធិពលករអន្តរជាតិផងដែរ។[109]

**ករណីអ្នកការពារសិទ្ធិមនុស្ស៖ លោករ៉ុង ឈុន**

លោករ៉ុងឈុន ជាប្រធានសម្ព័ន្ធសហជីពកម្ពុជា ដែលតំណាងឲ្យកម្មករប្រហែល៩០,០០០នាក់ និងបានប្រឹងប្រែងទាមទារឲ្យមានការគោរពសិទ្ធិការងារ។ ឧទាហរណ៍ថ្មីៗនេះ លោកបានក្លាយទៅជាសកម្មជនដ៏ឈានមុខក្នុងយុទ្ធនាការដើម្បីទាមទារយុត្តិធម៌ ពីអតីតអភិបាលក្រុងបាវិតដែលត្រូវបានចោទពីបទបាញ់ប្រហារលើកម្មកររោងចក្រចំនួនបីនាក់ក្នុងអំឡុងពេលធ្វើបាតុកម្ម (ដូចបានបញ្ជាក់ខាងដើម) និងដើម្បីដោះលែងបុរសពីររូបដែលជឿជាក់ថារងការចោទប្រកាន់ដោយមិនត្រឹមត្រូវ ថាជាអ្នកសម្លាប់មេដឹកនាំសហជីព លោកជាវិជ្ជា។[110] លោករ៉ុងឈុន ក៏បានដឹកនាំនូវការចរចា ដើម្បីសុំបង្កើនប្រាក់ឈ្នួលអប្បបរិមាឲ្យកម្មករកាត់ដេរសម្លៀកបំពាក់និងស្បែកជើង និងបានចូលរួមជាមួយបាតុកម្មរយៈពេលជាងពីរខែ នៅសហគ្រាសតៃយ៉ាងដែលចាប់ផ្តើមនៅថ្ងៃទី២៥ខែមិថុនាឆ្នាំ២០១២។ បាតុកម្មនេះពាក់ព័ន្ធនឹងរោងចក្រសម្លៀកបំពាក់ ដែលត្រូវបានរាយការណ៍ថាបដិសេធបង់ប្រាក់បំណាច់លើកទឹកចិត្ត ដូចមានចែងក្នុងច្បាប់ជាតិ។[111] ជាលទ្ធផល លោករ៉ុងឈុនត្រូវបានកោះហៅដើម្បីសាកសួរនៅតុលាការខេត្តកណ្តាលកាលពីថ្ងៃទី១១និងថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២។[112] លោកដេកលូវ៍ អគ្គនាយកនៃសហគ្រាស តៃ យ៉ាង ចោទលោករ៉ុង ឈុន ពីបទញុះញង់កម្មករឲ្យធ្វើបាតុកម្ម។ លោករ៉ុង ឈុនអះអាងថា លោកចូលរួមក្នុងសកម្មភាពនេះដោយសារតែបានទទួលលិខិតពីកម្មកររោងចក្រកាត់ដេរ សំណូមពរឲ្យលោកជួយ។ លោកដេកលូវ៍ ក៏បានចោទលោករ៉ុង ឈុនពីបទបញ្ចេញមតិដែលមានលក្ខណៈបរិហារកេរ្តិ៍ ក្នុងអំឡុងពេលធ្វើបាតុកម្មនិងយោងតាមមាត្រា៣០៥ (បទព្រហ្មទណ្ឌបរិហារកេរ្តិ៍) នៃក្រមព្រហ្មទណ្ឌ។

---

[108]ស្បេន វ៉ររ៉ែល និងមុំ គន្ធា “មិនទាន់មានដំណើរការពាក់ព័ន្ធនឹងច្បាប់ស្តីពីសហជីព” *សារព័ត៌មានឌឹភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២) <http://www.phnompenhpost.com/2012090458479/National/still-no-motion-on-union-law.html>

[109]អ្នកការពារសិទ្ធិពលរដ្ឋ “អ្នកការពារសិទ្ធិពលរដ្ឋ៖ កម្ពុជា” (របាយការណ៍) (ខែឧសភា ឆ្នាំ២០១២) <http://www.civilrightsdefenders.org/files/Cambodia-report.pdf>

[110]ម៉ៃទិត្យថារ៉ា“ការចោទប្រកាន់សាជាថ្មីលើបណ្ឌិតៈ សហជីព” (សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍) (ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣) <http://www.phnompenhpost.com/2013011560784/National/re-charge-bandith-unionists.html>

[111]អ្នកការពារនៅជួរមុខ ‘កម្ពុជា៖ ដីកាកោះហៅរបស់តុលាការ ត្រូវបានបញ្ជូនទៅអ្នកដឹកនាំសហជីពនិងអ្នកការពារសិទ្ធិមនុស្ស លោករ៉ុង ឈុន’ (ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ ) <http://www.frontlinedefenders.org/node/19749>

[112]អ្នកការពារនៅជួរមុខ‘កម្ពុជា៖ ថ្មីៗ អ្នកដឹកនាំសហជីព និងអ្នកការពារសិទ្ធិមនុស្ស លោករ៉ុង ឈុន ត្រូវបានសាកសួរក្នុងតុលាការពាក់ព័ន្ធនឹងបទញុះញង់ និងបរិហារកេរ្តិ៍’ (ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១២) <http://www.frontlinedefenders.org/node/19973>

ការសាកសួរជាបន្តបន្ទាប់លើរូបលោករ៉ុងឈុន ចាត់ទុកជាការយាយីតាមផ្នែកប្រព័ន្ធតុលាការ។ ការយាយីមកលើរូបលោក ត្រូវបានជឿជាក់ថាមានឫសគល់មកពីសកម្មភាពសិទ្ធិមនុស្សដ៏លេចធ្លោរបស់លោក តំណាងឲ្យកម្មករ។ខណៈពេលដែល លោករ៉ុងឈុន មិនដែលត្រូវបានចោទប្រកាន់ជាផ្លូវការ ប៉ុន្តែនិយោជិកចំនួន៥៣នាក់ត្រូវបាត់បង់ការងារ ជាលទ្ធផលនៃការធ្វើបាតុកម្ម និងចាញ់បណ្តឹងឧទ្ធរណ៍ក្នុងបណ្តឹងទាមទារប្រាក់បំណាច់បញ្ចប់កិច្ចសន្យា កាលពីថ្ងៃទី១៣ខែធ្នូឆ្នាំ២០១២។[113] សាលក្រមនេះ និងការយាយីដែលលោករ៉ុងឈុនបានប្រឈម ជាឧទាហរណ៍សំខាន់មួយនៃវប្បធម៌និទណ្ឌភាពដែលកើតមាននៅកម្ពុជាពាក់ព័ន្ធនឹងបទឧក្រិដ្ឋប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស។

លោក ជា វិជ្ជាអតីតប្រធានសហជីពសេរីកម្មករកម្ពុជា ត្រូវបានគេបាញ់សម្លាប់ទាំងកណ្តាលថ្ងៃត្រង់កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ នៅទីក្រុងភ្នំពេញ។[114] លោកបានធ្វើការប្រឆាំងយ៉ាងសស្រាក់សស្រាំដើម្បីទាមទារឲ្យបង្កើនប្រាក់ឈ្នួលអប្បបរិមាឲ្យដល់កម្មករក្នុងវិស័យកាត់ដេរ។ ដើម្បីឆ្លើយតបទៅនឹងការទាមទាររកយុត្តិធម៌របស់សាធារណជនបុរសពីររូបត្រូវបានចាប់ខ្លួនយ៉ាងឆាប់រហ័ស ថាពួកគេជាឃាតករសម្លាប់លោកជាវិជ្ជា។ លោកប៊ិន សំណាង និងលោក សុខ សំអឿន ត្រូវបានចោទប្រកាន់និងផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល២០ឆ្នាំ ប៉ុន្តែក្នុងឆ្នាំ២០០៨ ពួកគេត្រូវបានដោះលែងនៅក្រៅឃុំ បន្ទាប់ពីតុលាការកំពូលរកឃើញភស្តុតាងចង្អុលបង្ហាញពីភាពគ្មានទោសរបស់ពួកគេ។ ទោះបីជាបែបនោះក៏ដោយកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ សាលាឧទ្ធរណ៍រាជធានីភ្នំពេញបានសម្រេចតម្កល់ទោស រយៈពេល ២០ឆ្នាំ ហើយបុរសទាំងពីរត្រូវបានបញ្ជូនត្រលប់ទៅពន្ធនាគារវិញ។[115] លោកប៊ិនសំណាង និង សុខសំអឿន ត្រូវបានសហគមន៍សិទ្ធិមនុស្សយ៉ាងច្រើនជឿថា ពួកគេជាអ្នកទទួលកំហុសជំនួស ក្នុងរឿងឃាតកម្មដែលពាក់ព័ន្ធនឹងនយោបាយ។[116]

## ស្ត្រីសកម្មជនសិទ្ធិដីធ្លី

ចាប់ផ្តើមក្នុងឆ្នាំ២០១២ ស្ត្រីសកម្មជនសិទ្ធិដីធ្លីបានចូលទៅជួរមុខក្នុងសមរភូមិរបស់ប្រជាពលរដ្ឋប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំនៅទូទាំងប្រទេសកម្ពុជា។ ស្ត្រីកម្ពុជាបច្ចុប្បន្នកំពុងតែងើបឈរឡើងប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំនិងការដណ្តើមយកដីដែលមានរដ្ឋាភិបាលនៅពីក្រោយខ្នង និងដឹកនាំការតស៊ូដើម្បីស្វែងរកយុត្តិធម៌តំណាងឲ្យសហគមន៍របស់ពួកគេ ស្របពេលជាមួយគ្នានោះក៏បានធ្វើឲ្យខ្លួនពួកគេទទួលរងភាពប្រថុយប្រថានជាខ្លាំង។ ក្នុងអំឡុងបទសម្ភាសន៍ សកម្មជនសិទ្ធិដីធ្លីជាស្ត្រី ប្រាប់ដល់អង្គការមាត្រា១៩ និង ម.ស.ម.ក ថាសហគមន៍ដែលត្រូវបណ្តេញចេញ បានធ្វើការសម្រេចចិត្តជាយុទ្ធសាស្ត្រក្នុងការ

[113]មុំគន្ធានិង ស្បែនរ៉ូវ៉ែល 'បាតុកររោងចក្រ តៃយ៉ាងចាញ់ក្តីនៅអាជ្ញាកណ្តាល' *សារព័ត៌មានឌឺភ្នំពេញប៉ុស្តិ៍*(ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២) <http://phnompenhpost.com/2012121760318/National/tai-yang-strikers-lose-arbitration.html>

[114]ជេមស៍ វ៉េលស៍ និង ប្រាក់ចាន់ថុល'កេរ្តិ៍ដំណែលដែលបានចាញ់' *សារព័ត៌មានឌឹខែមបូឌាដេលី*(ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៩) <http://www.cambodiadaily.com/features/a-lost-legacy-1389/>

[115]គីមសារ៉ុមប៉ិតរស្មីនិង អែប៊ីសើហ្វ 'សាលក្រមដែលរកឃើញថាមានទោសត្រូវបានតម្កល់ ក្នុងរឿងឃាតកម្ម លោកជា វិជ្ជា' *សារព័ត៌មានឌឺភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២)

[116]ជេមស៍វ៉េលស៍និង ប្រាក់ ចាន់ថុល'កេរ្តិ៍ដំណែលដែលបានចាញ់' *សារព័ត៌មានឌឹខែមបូឌាដេលី*(ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៩) <http://www.cambodiadaily.com/features/a-lost-legacy-1389/>

ប្រមូលផ្តុំនិងធ្វើការតវ៉ាប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ដោយគិតថាអាជ្ញាធរនឹងឆ្លើយតបមកវិញដោយលក្ខណៈទន់ភ្លន់ពេលប្រឈមមុខជាមួយនឹងសកម្មជនជាស្ត្រី ជាងជាមួយសកម្មជនជាបុរស។ជាពិសេសស្ត្រីនៅតំបន់បឹងកក់បានទាក់ទាញចំណាប់អារម្មណ៍ពីសារព័ត៌មានជាតិនិងអន្តរជាតិ ដោយសារតែក្នុងនាមជាស្ត្រីពួកគេកំពុងបង្ហាញនូវសកម្មនិយមបែបថ្មីនៅកម្ពុជា។

ចំណុចនេះ មានភាពលេចធ្លោក្នុងករណីបឹងកក់និងបុរីកីឡាតំបន់ពីរនៅទីក្រុងភ្នំពេញដែលរងគ្រោះដោយការចាប់យកដីនិងការបណ្តេញចេញដោយបង្ខំហើយមិនបានទទួលប្រាក់សំណងបានសមរម្យ។ គ្រួសាររបស់សហគន៍បឹងកក់បានតវ៉ាជាមួយនឹងការបណ្តេញចេញតាំងពីឆ្នាំ២០០៧ ពេលដែលរដ្ឋាភិបាលបានជួលដីរបស់ពួកគេទៅឲ្យក្រុមហ៊ុនឯកជន ឈ្មោះស៊ូកាគូអ៊ីន ដើម្បីធ្វើការអភិវឌ្ឍន៍។ ចំណែកសហគមន៍បុរីកីឡាក្រុមហ៊ុនផានអ៊ីម៉ិច បានរំលោភបំពានលើកិច្ចសន្យា មិនព្រមសាងសង់អគារនៅនឹងកន្លែង ដើម្បីជាលំនៅដ្ឋានសម្រាប់បុគ្គលដែលត្រូវបានបណ្តេញចេញ។ ក្រុមហ៊ុននេះសាងសង់ត្រឹមតែ ៨អគារនៅលើដីដែលបានសន្យាបណ្តាលឲ្យមានបុគ្គលដេលត្រូវបានបណ្តេញចេញជាច្រើន មិនបានទទួលសំណងជំងឺចិត្តក្នុងបែបណាមួយនោះទេ។

កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១២នគរបាលបានចាប់ខ្លួនស្ត្រីដែលជាអ្នកតវ៉ាចំនួន២២នាក់ និងក្មេងចំនួន៦នាក់ដែលកំពុងធ្វើបាតុកម្មប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ក្នុងសហគមន៍បុរីកីឡា។[117] បាតុករទាំងនោះត្រូវបានឃុំខ្លួនក្នុងមណ្ឌលព្រៃស្ពឺ រយៈពេលពីរបីថ្ងៃ មុនពេលដែលស្ត្រីបីនាក់ត្រូវបានដោះលែងនៅថ្ងៃទី១៦ ខែមករា និងម្នាក់ទៀតនៅថ្ងៃទី១៧ ខែមករា ពេលដែលពួកគេព្រមប្តូរទៅនៅទីតាំងថ្មី។ ចំណែកអ្នកនៅសល់បានគេចចេញពីមណ្ឌលឃុំខ្លួន កាលពីថ្ងៃទី១៨ ខែមករាដោយឡើងតាមជញ្ជាំង នៅថ្ងៃដែលលោកស្រីមូរសុខហួរ បានទៅសួរសុខទុក្ខពួកគេ ដូចបានរៀបរាប់ខាងដើម។[118]

កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ "សកម្មជនបឹងកក់ ១៣នាក់" ត្រូវបានចាប់ខ្លួនខណៈពេលដែលពួកគេកំពុងតែធ្វើបាតុកម្មដោយសន្តិវិធីនិងសន្និសីទព័ត៌មានក្នុងភូមិ១ តំបន់បឹងកក់។ ក្នុងពេលបាតុកម្មដែលចូលរួមដោយមនុស្សជាង ២០០នាក់ ហើយអ្នកចូលរួមមួយចំនួនសម្រេចសាងសង់ផ្ទះរបស់ពួកគេឡើងវិញ ដោយសារតែផ្ទះទាំងនោះត្រូវបានបំផ្លាញជាងពីរឆ្នាំមុន ដោយក្រុមហ៊ុន ស៊ូកាគូអ៊ីន។ បន្ទាប់ពីត្រូវបានសន្តិសុខឯកជន ស្រែកគំរាមដាក់និងវាយដំ ជាលទ្ធផលមានសកម្មជនចំនួន៣នាក់ ត្រូវសន្លប់បាត់ស្មារតី និងសកម្មជនជាច្រើនរងរបួស សកម្មជនចំនួន១៣នាក់ត្រូវបានចាប់ខ្លួននិងនាំទៅប៉ុស្តិ៍នគរបាលនៅទីក្រុងភ្នំពេញ។[119]

---

[117]ភោគជន'បាតុករបុរីកីឡាត្រូវបានឃុំខ្លួនក្នុងមណ្ឌលព្រៃស្ពឺ' *សារព័ត៌មានឌឹខេមបូឌាដេលី* (ថ្ងៃទី១១ ខែមករា ឆ្នាំ២០១២) <http://www.cambodiadaily.com/news/borei-keila-protesters-detained-at-prey-speu-565/>

[118]វេទិកាអាស៊ី'កម្ពុជា៖ ការបណ្តេញចេញនៅបុរីកីឡា និងការឃុំខ្លួនដោយគ្មានមូលដ្ឋាន របស់ស្ត្រី២២នាក់និងក្មេង៦នាក់' (លិខិត) (ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២) <http://www.forum-asia.org/?p=11990>

[119]ម.ស.ម.ក "អ្នករស់នៅបឹងកក់ ត្រូវបានចាប់ខ្លួនដោយនគរបាលខណៈពេលដែលរៀបចំបាតុកម្មដោយសន្តិវិធី" (សេចក្តីប្រកាសព័ត៌មានបន្ទាន់) (ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១២) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=20&id=5>

ក្រោយមកពួកគេត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសពីបទ "ប្រឆាំងនឹងអ្នករាជការសាធារណៈដោយមានស្ថានទម្ងន់ទោស" ក្នុងមាត្រា ៥០៤នៃក្រមព្រហ្មទណ្ឌ និងកាន់កាប់ដីខុសច្បាប់ក្នុងមាត្រា៣៤នៃច្បាប់ភូមិបាល។[120] ស្ត្រីចំនួន៧នាក់ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ៦ខែ ស្ត្រីចំនួន ៥នាក់ត្រូវផ្តន្ទាដាក់ទោសឲ្យជាប់ពន្ធនាគារចំនួន២ឆ្នាំ (ទោសចំនួន៦ខែត្រូវបានព្យួរ) និងស្ត្រីម្នាក់ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួនមួយឆ្នាំ (ទោសរយៈពេល១ឆ្នាំនិង៦ខែត្រូវព្យួរ)។[121] ដោយសារតែមានការចូលរួម និងការយកចិត្តទុកដាក់សហគមន៍អន្តរជាតិជាច្រើនលើករណីរបស់ សកម្មជនបឹងកក់១៣នាក់ ពួកគេត្រូវបានដោះលែងពីពន្ធនាគារ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ បន្ទាប់ពីសាលាឧទ្ធរណ៍បន្ថយទោសរបស់ពួកគេទៅត្រឹមតែ១ខែ ៣ថ្ងៃ ជាចំនួនថ្ងៃដែលពួកគេបានឃុំខ្លួនរួចហើយនោះ។ ប៉ុន្តែ បទចោទរបស់ពួកគេមិនត្រូវបាន ទម្លាក់ចោលនោះទេ។[122]

រដ្ឋាភិបាលមិនស្ទាក់ស្ទើរក្នុងការបង្រ្កាបលើទម្រង់ថ្មីនៃសកម្មនិយមនេះទេ។ សកម្មជនដីធ្លីជាស្ត្រី កំពុងតែរងគ្រោះដោយសារតែការប្រើអំពើហិង្សាលើរូបរាងកាយក្នុងកម្រិតខ្ពស់ក្នុងកណ្តាប់ដៃនគរបាលនិងទាហាន ដែលបានបង្កើនការប្រើប្រាស់ដំបង និងអាវុធ ដើម្បីវាយប្រហារលើអ្នកការពារសិទ្ធិមនុស្សជាស្ត្រី។ ឧទាហរណ៍ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ អ្នកស្រីបូវ ស្រីស្រស់ដែលកំពុងមានផ្ទៃពោះ បានធ្វើបាតុកម្មក្នុងអំឡុងពេលសវនាការរបស់បងស្រីអ្នកស្រី ជាស្ត្រីម្នាក់ក្នុងចំណោមសកម្មជនបឹងកក់១៣នាក់ និងត្រូវបាននគរបាលទាត់ត្រូវចំពោះ ធ្វើឲ្យអ្នកស្រីត្រូវរំលូតកូន។[123] ពេលអ្នកស្រីប្រកាសថា អ្នកស្រីនឹងប្តឹងបុរសបីនាក់ដែលត្រូវបានឃើញថាជាអ្នកទទួលខុសត្រូវ ដែលក្នុងនោះមានលោក ភួង ម៉ាឡៃ ស្នងការនគរបាលរងនៃអគ្គស្នងការរាជធានីភ្នំពេញ ពេលនោះអ្នកស្រីទទួលនូវមតិមាក់ងាយ ពីសំណាក លោកភួង ម៉ាឡៃ លើបណ្តាញសារព័ត៌មាន។[124] ក្នុងអំឡុងពេលដែលសរសេររបាយការណ៍នេះ មិនទាន់មានការចាត់វិធានការផ្នែកច្បាប់ណាមួយមកលើអគ្គស្នងការរងរូបនោះទេទោះបីជាមានការដាក់ពាក្យបណ្តឹងលើរូបលោក នៅតុលាការរាជធានីភ្នំពេញក្នុងខែកក្កដា ឆ្នាំ២០១២ក៏ដោយ។

**ករណីអ្នកការពារសិទ្ធិមនុស្ស៖អ្នកស្រី យ៉ោម បុប្ផា**

---

[120]ម.ស.ម.ក'ម.ស.ម.កចេញផ្សាយការវិភាគផ្នែកច្បាប់បទចោទនិងការដាក់ទោសសកម្មជនបឹងកក់ទាំង ១៣នាក់ កាលពីថ្ងៃទី២៤ខែឧសភាឆ្នាំ២០១២' (សេចក្តីថ្លែងការណ៍) (ថ្ងៃទី១១ខែមិថុនា) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=257&id=5>

[121]ដូចខាងលើ។

[122]ស្បែនវ៉ែរលៃនិងយុតសុភ័ក្រ្តចរិយា'សំឡេងសេរីភាពសម្រាប់បឹងកក់១៣នាក់' *សារព័ត៌មាន ឌឹភ្នំពេញប៉ុស្តិ៍*(ថ្ងៃទី២៨ខែមិថុនាឆ្នាំ ២០១២): http://www.phnompenhpost.com/index.php/2012062857085/National-news/freedom-boeung-kak-13.html

[123] 'សកម្មជនសិទ្ធិដីធ្លីត្រូវបានដោះលែង' *វិទ្យុអាស៊ីសេរី* (ថ្ងៃទី២៧ខែមិថុនាឆ្នាំ២០១២) <http://www.rfa.org/english/news/cambodia/boeung-kak-06272012162146.html>>

[124]ម.ស.ម.ក"លិខិតចំហ ជូនមន្ត្រីរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងមតិយោបល់រើសអើង ដែលអគ្គស្នងការរងនៃអគ្គស្នងការនគរបាលទីក្រុងភ្នំពេញ" (លិខិតចំហ) (ថ្ងៃទី៨ខែសីហាឆ្នាំ២០១២) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=277&id=5>

ពេលសកម្មជនបឹងកក់ ១៣នាក់ត្រូវបានផ្តន្ទាទោស សកម្មជនម្នាក់ទៀតក្នុងតំបន់បឹងកក់គឺអ្នកស្រី យ៉ោម បុប្ផា បានងើបឡើងចូលទៅកាន់ជួរមុខក្នុងយុទ្ធនាការដើម្បីទាមទារឲ្យមានការដោះលែងពួកគេ។ អ្នកស្រីលេចធ្លោ និងមានវត្តមានក្នុងបាតុកម្មទាំងអស់ ហើយអ្នកស្រីបានក្លាយជាអ្នករិះគន់យ៉ាងខ្លាំងក្លាប្រឆាំងមកលើរដ្ឋាភិបាល។ ជាលទ្ធផល អ្នកស្រី យ៉ោម បុប្ផា ត្រូវបានគំរាមកំហែងដោយផ្ទាល់មាត់ យាយីនិងសម្លុតបំភ័យ ដោយអាជ្ញាធរ។ នគរបាលបានប្រាប់អ្នកស្រីជាបន្តបន្ទាប់ថា អ្នកស្រី "ស្ថិតក្នុងបញ្ជីខ្មៅ" និងអ្នកស្រី "នឹងមានបញ្ហាក្នុងពេលឆាប់ៗ"។[125]

កាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២ អ្នកស្រី យ៉ោម បុប្ផានិងស្វាមីរបស់អ្នកស្រី គឺលោកលួស សាខនត្រូវបានចោទប្រកាន់ពីបទនៅពីក្រោយការវាយប្រហារលើអ្នករត់ម៉ូតូឌុបចំនួនពីរនាក់។ ស្វាមីភរិយាទាំងពីរត្រូវបានចោទប្រកាន់ពីបទ "អំពើហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស" យោងតាមមាត្រា២១៨នៃក្រមព្រហ្មទណ្ឌ។ យោងតាមការអះអាងរបស់ព្រះរាជអាជ្ញា "អ្នកស្រីយ៉ោម បុប្ផានិងស្វាមីបានរៀបចំផែនការវាយប្រហារមកលើបុរសពីរនាក់ ដែលអង្គុយផឹកស្រា និងបន្ទាប់មកមានវត្តមានចាំមើលផែនការរបស់ពួកគេបានដំណើរការយ៉ាងណា"។[126] កាលពីថ្ងៃទី២៧ ខែធ្នូអ្នកស្រីយ៉ោមបុប្ផា និងស្វាមីត្រូវបានរកឃើញថាមានទោសនិងត្រូវផ្តន្ទាទោសចំនួនបីឆ្នាំក្នុងពន្ធនាគារ។ ប៉ុន្តែខណៈពេលដែល យ៉ោម បុប្ផា ត្រូវនាំយកទៅពន្ធនាគារព្រៃសក្លាមៗ ទោសរបស់ស្វាមីអ្នកស្រី ត្រូវបានព្យួរ ហើយលោកអាចមានសេរីភាព។[127]

ក្រៅអំពីពីនីតិវិធីជាច្រើនដែលខុសប្រក្រតីក្នុងអំឡុងពេលសវនាការ រួមទាំងបងប្អូនប្រុសទាំងពីររបស់អ្នកស្រីយ៉ោមបុប្ផា ដែលត្រូវបានផ្តន្ទាទោសដោយកំបាំងមុខ មិនមានភស្តុតាងណាត្រូវយកមកបង្ហាញនៅក្នុងតុលាការដើម្បីបញ្ជាក់ថា អ្នកស្រី យ៉ោម បុប្ផានិងលួស សាខន បានប្រព្រឹត្តអំពើហិង្សាលើអ្នករត់ម៉ូតូឌុបនោះទេ។ ការពិតមិនមានចម្លើយណាដែលសាក្សីផ្តល់ឲ្យបញ្ជាក់ថា អ្នកស្រីយ៉ោម បុប្ផា និងស្វាមីបានចូលរួមក្នុងការវាយប្រហារនោះទេ។ ព្រះរាជអាជ្ញាបានអះអាងថា ទោះបីជាអ្នកស្រីយ៉ោមបុប្ផា មិនបានប្រព្រឹត្តអំពើហិង្សាដោយផ្ទាល់ ប៉ុន្តែពួកគេបានរៀបចំផែនការ។ សាក្សីមួយចំនួននិយាយថា ពួកគេបានឃើញ អ្នកស្រីយ៉ោម បុប្ផា និងស្វាមីនៅកន្លែងកើតហេតុ និងអ្នកស្រីយ៉ោម បុប្ផាបានជួយដោះលែងបងប្អូនប្រុសខ្លួនពេលដែលអ្នករត់ម៉ូតូឌុបបានចាប់ខ្លួនគេ ប៉ុន្តែមិនមានសាក្សីណាម្នាក់អាចនិយាយយ៉ាងច្បាស់ថា អ្នកស្រីយ៉ោម បុប្ផា ជាអ្នករៀបចំឲ្យមានការវាយប្រហារនោះទេ។ គួរបញ្ជាក់ផងដែរថា មានភាពមិនស្របស៊ីគ្នាយ៉ាងច្បាស់ក្រឡែត រវាងកំណត់ហេតុនិងការផ្តល់ចម្លើយនៅក្នុងបន្ទប់តុលាការរបស់សាក្សី រួមទាំងពេលវេលាដែលពួកគេបានមកដល់ហាងផឹកស៊ីពេលដែលអ្នកស្រីយ៉ោមបុប្ផានិងស្វាមីបានបង្ហាញខ្លួននិងពេលដែលការវាយប្រហារចាប់ផ្តើមកើតឡើង។ ទាំងអ្នកស្រី យ៉ោម បុប្ផា និងស្វាមីបានបញ្ជាក់ថាពួកគេមិនស្គាល់អ្នករត់ម៉ូតូឌុបទាំងពីរនាក់នោះទេពួកគេគ្រាន់តែបានឮសំឡេងស្រែក ពេលមានការវាយគ្នា និងចូលទៅមើលថាតើមានអ្វីកើតឡើង។[128] ទោះបីជាយ៉ាងណាក៏ដោយ អ្នកស្រី

---

[125] យុទ្ធនាការសម្លៀកបំពាក់ស្អាតស្អំ'ថ្នាក់ដឹកនាំសហជីពប្រហែលជាង២០០នាក់ត្រូវបានព្យួរការងារឬបញ្ឈប់ការងារដោយខុសច្បាប់បន្ទាប់ពីកូដកម្មទ្រង់ទ្រាយធំបានបញ្ចប់'

[126] លីកាដូ"ការសង្ខេបថ្មីៗ ៖ករណីយ៉ោមបុប្ផា" (ការសង្ខេបថ្មីៗ) (ខែមេសា ឆ្នាំ២០១៣) <http://www.licadho-cambodia.org/reports/files/177LICADHOBriefBopha2013-English.pdf>

[127] យុទ្ធនាការសម្លៀកបំពាក់ស្អាតស្អំ'ថ្នាក់ដឹកនាំសហជីពប្រហែលជាង២០០នាក់ត្រូវបានព្យួរការងារឬបញ្ឈប់ការងារដោយខុសច្បាប់បន្ទាប់ពីកូដកម្មទ្រង់ទ្រាយធំបានបញ្ចប់'

[128] លីកាដូ"ការសង្ខេបថ្មីៗ ៖ករណីយ៉ោមបុប្ផា" (ការសង្ខេបថ្មីៗ) (ខែមេសា ឆ្នាំ២០១៣)

យ៉ោមបុប្ផានិងស្វាមីត្រូវបានរកឃើញថាមានទោសទោះជាមិនមានភស្តុតាងជាក់លាក់។ ចំណុចនេះបានធ្វើឲ្យអង្គការមាត្រា១៩ និង ម.ស.ម.ក ជឿថា ការចោទប្រកាន់និងការផ្តន្ទាទោសមានហេតុផលពាក់ព័ន្ធផ្នែកនយោបាយ។ អ្នកស្រីយ៉ោមបុប្ផាដាក់ពាក្យបណ្តឹងឧទ្ធរណ៍ កាលពីខែមករា ឆ្នាំ២០១៣ ហើយសាលាឧទ្ធរណ៍នឹងធ្វើសវនាការរឿងក្តីរបស់អ្នកស្រីនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣។

អ្នកស្រី ទឹម សាក់មុន្នីជាសកម្មជនដីលេចឆ្លោមួយរូបក្នុងសហគមន៍ បុរីកីឡា ដែលត្រូវចាប់ខ្លួន និងឃុំខ្លួនមួយថ្ងៃក្រោយបន្ទាប់ពីអ្នកស្រីយ៉ោម បុប្ផា និងត្រូវបានចោទប្រកាន់ ពីបទ"ផ្តល់សេចក្តីប្រកាសដោយភូតកុហក" ក្នុងគោលបំណងដើម្បីទាមទារសិទ្ធិកាន់កាប់ផ្ទះឲ្យកូនប្រុសរបស់គាត់។[129] ខណៈពេលការចាប់ឃុំខ្លួនអ្នកស្រី ទឹម សាក់មុន្នីបានរស់នៅក្នុងស្ថានភាពដ៏អស់សង្ឃឹម បន្ទាប់ពីត្រូវបានបដិសេធមិនព្រមផ្តល់សំណងជាលំនៅដ្ឋាននៅនឹងកន្លែង។[130] បន្ទាប់ពីរយៈពេលជាងបីខែកន្លះ ស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន ករណីអ្នកស្រីទឹម សាក់មុន្នី ត្រូវបានសម្រេចនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ និងរកឃើញថាមានកំហុសដោយបទក្លែងបន្លំ។ ទោសរបស់អ្នកស្រី ដែលត្រូវជាប់ពន្ធនាគារចំនួន៦ខែ ត្រូវបានព្យួរ។[131] ដូចគ្នានឹងអ្នកស្រីយ៉ោមបុប្ផាអ្នកស្រី ទឹម សាក់មុន្នី ត្រូវបានចាប់ខ្លួនដើម្បីជាការគំរាមកំហែងដល់សកម្មជនដីធ្លីជាស្ត្រីដទៃទៀតមិនឲ្យបន្តការងាររបស់ពួកគាត់ពាក់ព័ន្ធនឹងការងារសិទ្ធិមនុស្ស។[132]

យោងតាមព័ត៌មានដែលអាចរកបាន និងការបញ្ជាក់បន្ថែមដែលប្រមូលបាន ការគំរាមកំហែងនិងភាពងាយរងគ្រោះ ដែលសកម្មជនជាស្ត្រី និងសកម្មជនជាបុរស ត្រូវប្រឈមមានកម្រិតប្រហាក់ប្រហែលគ្នា។ មិនមានភស្តុតាងជាក់ស្តែងណាមួយស្តីពីភាពខុសគ្នារវាងមូលដ្ឋានភេទក្នុងការកំណត់ការគំរាមកំហែងពីអាជ្ញាធរនោះទេ។ ប៉ុន្តែមានការចូលរួមពីស្ត្រីជាច្រើនក្នុងការធ្វើបាតុកម្មនិងតវ៉ាជាពិសេស ប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ។ ដោយសារតែតាមទំនៀមទម្លាប់ក្នុងប្រទេសកម្ពុជា ស្ត្រីជាអ្នកមើលថែគ្រួសារ ដូច្នេះបណ្តាលឲ្យមានភាពប្រថុយប្រថានប៉ះពាល់ដល់កុមារនិងសមាជិកគ្រួសារដទៃទៀតព្រោះថាស្ត្រីមួយចំនួន ដែលជាអ្នកការពារសិទ្ធិមនុស្សបានចូលរួមក្នុងការងារសិទ្ធិមនុស្ស និងធ្វើឲ្យកូនៗរបស់ពួកគេគ្មានអ្នកមើលថែ។ស្ត្រីមួយចំនួនដែលត្រូវបានសម្ភាសន៍បានរាយការណ៍ថា ពួកគេបានទទួលទូរស័ព្ទគំរាមកំហែងថានឹងធ្វើបាបកូនៗរបស់

---

<http://www.licadho-cambodia.org/reports/files/177LICADHOBriefBopha2013-English.pdf>

[129]ក្រុមអង្គការសង្គមស៊ីវិលផ្សេងៗ "រយៈពេលពីរថ្ងៃការឃុំខ្លួនបណ្តោះអាសន្នដោយគ្មានភាពយុត្តិធម៌ចំនួនពីរដងដាក់មកលើសកម្មជនដីធ្លីលេចឆ្លោនៅភ្នំពេញ" (សេចក្តីថ្លែងការណ៍រួម) (ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១២) <http://sithi.org/temp.php?url=publication_detail.php&lg=&mid=5809>

[130]យុតសុភ័ក្ត្រ ចរិយានិងស្បែនវីរ៉ែល "រដ្ឋាភិបាលកម្ពុជាដាក់ពន្ធនាគារ សកម្មជនសិទ្ធិដីធ្លីទីពីរ ក្នុងរយៈពេលពីរថ្ងៃ" *សារព័ត៌មាន ឌឹ ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១២) <http://www.phnompenhpost.com/2012090658543/National/cambodian-government-imprisons-second-land-activist-in-two-days.html>

[131]ដោះលែងសកម្មជនទាំង១៥នាក់ "សាក់មុន្នី ត្រូវបានរកឃើញថាមានកំហុស ប៉ុន្តែនឹងត្រូវដោះលែង" (ភ្នំពេញថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ១០១២)<http://freethe15.wordpress.com/2012/12/26/505/>

[132]លីកាដូ "អ្នកការពារសិទ្ធិមនុស្ស ទឹមសាក់មុន្នី ត្រូវបានដាក់ពន្ធនាគារដោយសារតែការទាមទារសិទ្ធិដីធ្លី" (របាយការណ៍សង្ខេប) (ខែកញ្ញា ឆ្នាំ២០១២)<http://www.licadho-cambodia.org/reports/files/174Free15+AI-SakmonyProfile-English.pdf>

ពួកគេប្រសិនបើពួកគេមិនបញ្ឈប់សកម្មនិយមទេនោះ។ បន្ថែមពីលើនោះទៀត សកម្មជនជាស្ត្រី អាចនឹងងាយរងគ្រោះចំពោះអំពើហិង្សាលើរូបរាងកាយ ឧទាហរណ៍ ក្នុងករណីដែលពួកគេកំពុងតែមានផ្ទៃពោះ។

## បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល

ពីដើមឡើយ ថ្នាក់ដឹកនាំរបស់អង្គការមិនមែនរដ្ឋាភិបាល ក៏ មិនមែនទទួលរួចផុតពីការគំរាមកំហែងជាងបុគ្គលិកធម្មតានោះទេ។ ក្នុងខែធ្នូ ឆ្នាំ២០០៥ ថ្នាក់ដឹកនាំអង្គការមិនមែនរដ្ឋាភិបាលត្រូវបានចាប់ខ្លួននិងឃុំខ្លួនពីបទបរិហារកេរ្តិ៍ ក្នុងអំឡុងការបង្រ្កាបអ្នកជំទាស់ដែលលេចធ្លោ។ ចំណុចនេះនាំឲ្យមានការថ្កោលទោសភ្លាមៗ ពីសំណាក់សហគមន៍អន្តរជាតិសកម្មជនសិទ្ធិមនុស្ស និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស។ក្នុងព្រឹត្តិការណ៍នេះលោកកឹម សុខាប្រធាន ម.ស.ម.ក និងលោក យ៉េង វីរៈ នាយកនៃ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ គឺនៅក្នុងចំណោមជនរងគ្រោះនៃយុទ្ធនាការបន្តបន្ទាប់របស់រដ្ឋាភិបាលក្នុងការដៅមុខសញ្ញាលើអ្នកធ្វើយុទ្ធនាការផ្នែកសិទ្ធិមនុស្សដែលលេចធ្លោ និងស្ថិតក្នុងថ្នាក់ដឹកនាំ។ ចំណុចចាប់ផ្តើមនៃរឿងនេះ គឺផ្ទាំងបដាដែលដាក់បង្ហាញក្នុងការអបអរទិវាសិទ្ធិមនុស្សអន្តរជាតិ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៥។ ផ្ទាំងបដាទាំងនោះសល់ពីអំឡុងពេលមុនការបោះឆ្នោតឆ្នាំ២០០៣ដែលមានមតិយោបល់សរសេរដោយដៃរបស់ប្រជាពលរដ្ឋកម្ពុជា ដែលបានបញ្ចេញទស្សនៈផ្នែកនយោបាយអំពី គ.ប.ក និងនាយករដ្ឋមន្ត្រីក៏ដូចជាពាក្យស្លោកថា "ខ្ញុំមិនបោះឆ្នោតឲ្យគណបក្សណាដែលសាបព្រោះភាពភ័យខ្លាចដល់ប្រជាពលរដ្ឋនោះទេ"។[133]

ទាំងលោក យ៉េង វីរៈនិងលោក កឹម សុខាត្រូវបានចាប់ខ្លួន និងត្រូវឲ្យនៅក្នុងពន្ធនាគារដោយគ្មានការដោះលែងឲ្យនៅក្រៅឃុំពីបទបរិហារកេរ្តិ៍ ដោយសារតែការរិះគន់រដ្ឋាភិបាលដែលបង្ហាញនៅលើផ្ទាំងបដា។ បន្ទាប់ពីចំណាយពេល១៧ថ្ងៃ ក្នុងពន្ធនាគារព្រៃស រដ្ឋាភិបាលត្រូវបានបង្ខំឲ្យសម្របសម្រួល តាមសំឡេងដ៏ខ្លាំងក្លាពីសំណាក់សហគមន៍អន្តរជាតិជាច្រើន និងបានដោះលែងបុគ្គលទាំងពីររូបឲ្យនៅក្រៅឃុំ ដោយសារតែបុគ្គលទាំងពីររូបមានការទទួលស្គាល់ពីសំណាក់អន្តរជាតិជាខ្លាំង។[134]

ក្នុងរយៈពេលថ្មីៗឆ្ពោះទៅរកការបោះឆ្នោតឆ្នាំ២០១២ នាយកនៃអង្គការមិនមែនរដ្ឋាភិបាលហាក់ដូចជាមានសុវត្ថិភាពពីការគំរាមកំហែងនិងសម្លុតបំភ័យច្រើនជាងបុគ្គលិកធម្មតា។ អភ័យឯកសិទ្ធិបែបនេះ ភាគច្រើនគឺដោយសារតែបុគ្គលទាំងនោះជាថ្នាក់ដឹកនាំ មានអ្នកស្គាល់ច្រើនក្នុងចំណោមបណ្តាញសារព័ត៌មានជាតិនិងអន្តរជាតិ។

---

[133] ការអង្កេតមើលការការពារអ្នកការពារសិទ្ធិមនុស្ស'កម្ពុជា៖ ការឃុំខ្លួនដោយគ្មានមូលដ្ឋាន លោកកឹម សុខានិង លោកយ៉េង វីរៈ' (ទិដ្ឋភាពទូទៅ) (ថ្ងៃទី៤ ខែមករា ឆ្នាំ២០០៦) <http://www.omct.org/human-rights-defenders/urgent-interventions/cambodia/2006/01/d17795/>

[134] អង្គការឃ្លាំមើលសិទ្ធិមនុស្ស'កម្ពុជា៖ហ៊ុន សែន បានបំបិទមាត់អ្នករិះគន់ជាប្រព័ន្ធ' (ថ្ងៃទី៤ ខែមករា ឆ្នាំ២០០៦) (បន្ទាន់សម័យ) <http://www.hrw.org/news/2006/01/03/cambodia-hun-sen-systematically-silences-critics>

កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១០លោកលាង សុខជឿន បុគ្គលិក អង្គការលីកាដូត្រូវបានចាប់ខ្លួន ដោយចោទប្រកាន់ថាបានចែកចាយខិតបណ្ណមានលក្ខណៈញុះញង់ក្នុងខេត្តតាកែវ។ ទោះបី លាង សុខជឿន អះអាងថាមិនបានពាក់ព័ន្ធនឹងខិតបណ្ណ ឬការបង្កើតខិតបណ្ណនេះទេ ហើយទោះបីជាដំណើរការនៃការចាប់ខ្លួន និងសវនាការ មានភាពមិនប្រក្រតីជាច្រើន លោកក៏នៅតែត្រូវបានផ្តន្ទាទោសពីបទញុះញង់ និងត្រូវជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ។[135] កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ លោកត្រូវបានដោះលែង បន្ទាប់ពីទទួលទោសរយៈពេលពីរឆ្នាំពេញ។[136]

ភាពខុសគ្នារវាងករណីនេះ និងករណីរបស់លោកយ៉េង វីរៈនិងលោកគឹម សុខាគឺកម្រិតនៃការថ្កោលទោសពីថ្នាក់អន្តរជាតិ។ ភាពលេចធ្លោក្នុងថ្នាក់អន្តរជាតិរបស់លោកយ៉េង វីរៈនិងលោក គឹម សុខា មានច្រើនជាងករណីរបស់ លោក លាងសុខជឿន ឧទាហរណ៍ មានពេលមួយរដ្ឋមន្ត្រីយុត្តិធម៌របស់ប្រទេសស៊ុយអែតបានមកសួរសុខទុក្ខ លោកគឹម សុខាក្នុងពន្ធនាគារ។ ករណីរបស់ លោក លាង សុខជឿន ផ្ទុយមកវិញមិនសូវទទួលបានការចាប់អារម្មណ៍ ហើយជាលទ្ធផលមិនសូវមានឥទ្ធិពលដល់លទ្ធផលចុងក្រោយរបស់រឿងក្តីនេះ។[137]

គួរកត់សម្គាល់ផងដែរថា ក្នុងអំឡុងពេលទស្សនកិច្ចរបស់ អង្គការមាត្រា១៩ នៅប្រទេសកម្ពុជា មានអង្គការជាច្រើនបង្ហាញពីភាពជឿជាក់ថា ការភ័យខ្លាចធំបំផុតរបស់រដ្ឋាភិបាលគឺការផ្តល់អំណាចសហគមន៍ដូច្នេះ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដែលមានបំណងរៀបចំវគ្គបណ្តុះបណ្តាល ឬសកម្មភាពសមូហភាពតែងតែប្រឈមនឹងការគំរាមកំហែង ដែលមានដូចជា បទព្រហ្មទណ្ឌនិងការចាប់ខ្លួន។ វគ្គបណ្តុះបណ្តាល និងវេទិកាសាធារណៈរបស់ ម.ស.ម.ក ត្រូវបានរំខានឬរាំងជាច្រើនលើកជាច្រើនសា ដែលជាទូទៅដោយសារតែកងកម្លាំងប្រដាប់អាវុធ។[138] ថ្មីៗ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ ក្នុងខេត្តរតនៈគិរី មានកិច្ចប្រជុំរៀបចំដោយ ម.ស.ម.ក និងសមាគមអាដហុកត្រូវបានរំខាន និងរារាំងដោយអាជ្ញាធរមូលដ្ឋាន ដែលមានម្នាក់ក្នុងចំណោមនោះមានកាន់កាំភ្លើងM-16។ នគរបាលបានប្រាប់បុគ្គលិករបស់ ម.ស.ម.ក ថា ប្រសិនបើពួកគេមិនចាកចេញពីតំបន់នេះទេសុវត្ថិភាពរបស់ពួកគេនឹងមិនត្រូវបានធានានោះទេ។[139]

## ករណីអ្នកការពារសិទ្ធិមនុស្ស៖លោកចាន់ សុវ៉េត សមាគម អាដហុក

[135]អាយហ្វិក‘ក្រុមអង្គការអន្តរជាតិថ្កោលទោស ចំពោះការដាក់ទោសលើបុគ្គលិកសិទ្ធិមនុស្ស’ (សេចក្តីប្រកាសព័ត៌មានបន្ទាន់) (ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១២) <http://www.ifex.org/cambodia/2010/09/01/leang_sentenced/>

[136] ‘បុគ្គលិកអង្គការលីកាដូ មានសេរីភាពបន្ទាប់ពីការឃុំខ្លួនរយៈពេលពីរឆ្នាំ’ *សារព័ត៌មានឌឹភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១២) <http://www.phnompenhpost.com/2012053156507/National/licadho-staffer-walks-after-two-year-lockup.html>

[137]អង្គការឃ្លាំមើលសិទ្ធិមនុស្ស ‘កម្ពុជា៖ ដោះលែង បុគ្គលិកសិទ្ធិមនុស្ស’ (ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១) <http://www.hrw.org/news/2011/07/14/cambodia-free-human-rights-worker>

[138]ម.ស.ម.ក ‘សលាកប័ត្រសេរីភាពមូលដ្ឋាន៖ កិច្ចប្រជុំនិងវគ្គបណ្តុះបណ្តាល’ (សលាកប័ត្រព័ត៌មាន) (ខែកញ្ញា ឆ្នាំ២០១១) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=12&id=5>

[139]អាដហុក-ម.ស.ម.ក ‘ការបន្តការរារាំងលើសកម្មភាពផ្តល់អំណាចសហគមន៍ ដែលរៀបចំដោយអង្គការសិទ្ធិមនុស្ស’ (សេចក្តីថ្លែងការណ៍រួម) (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=274&id=5>

កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២ តុលាការរាជធានីភ្នំពេញចេញដីកាកោះហៅលោកចាន់ សុវ៉េត មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់នៅសមាគម អាដហុក ដើម្បីឲ្យបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរថៃ វិរៈ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១២ ពាក់ព័ន្ធពីបទចោទ "ផ្តល់ជំនួយដល់ចារី" ក្នុងមាត្រា៥៤៤នៃក្រមព្រហ្មទណ្ឌ។[140]

បទចោទប្រកាន់លើលោកចាន់ សុវ៉េត កើតឡើងបន្ទាប់ពីសុន្ទរកថារបស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែន កាលពីថ្ងៃទី១ ខែសីហាចោទប្រកាន់ "បុគ្គលិកធ្វើការសិទ្ធិមនុស្ស" ដោយមិនបញ្ចេញឈ្មោះថាបានជួយដល់ឧក្រិដ្ឋជន។ មានការជឿជាក់ថា បុគ្គលិកធ្វើការសិទ្ធិមនុស្សដែលសំដៅដោយលោកនាយករដ្ឋមន្ត្រីហ៊ុន សែនគឺលោកចាន់ សុវ៉េតនិងការចោទប្រកាន់មកលើរូបលោក គឺដោយសារតែផ្អែកលើជំនួយមនុស្សធម៌ ដែលលោកជួយដល់សម្មជនសិទ្ធិដីធ្លីដែលមកពីខេត្តក្រចេះ ដែលបានមកដល់ការិយាល័យរបស់សមាគមអាដហុក ទាំងភាពនឿយហត់បន្ទាប់ពីបានដើរអស់ជាច្រើនថ្ងៃ។ សកម្មជនសិទ្ធិដីធ្លីដែលបានរៀបរាប់មកនេះ ត្រូវបានអះអាងថាពាក់ព័ន្ធនឹងចលនាអបគមន៍ ដែលមានបំណងបង្កើតរដ្ឋក្នុងរដ្ឋ នៅភូមិប្រម៉ា ជាទីតាំងដីសម្បទានសេដ្ឋកិច្ចចំនួន១៥,០០០ ហិកតា។ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ កងកម្លាំងនគរបាលនិងយោធាជាច្រើនរយនាក់ប្រដាប់ដោយអាវុធបានសម្រុកចូលភូមិប្រម៉ា ដើម្បីដេញអ្នកភូមិចំនួន១,០០០គ្រួសារ រស់នៅលើតំបន់ដីសម្បទាន។ពេលអ្នកភូមិដែលក្នុងចំណោមនោះក៏មានក្រុមបុគ្គលដែលត្រូវបានចោទថាជាអ្នករៀបចំបង្កើតតំបន់អបគមន៍ បានបដិសេធមិនព្រមចាកចេញពីដីរបស់ពួកគេ អាជ្ញាធរក៏ចាប់ផ្តើមការបាញ់ប្រហារ ធ្វើឲ្យក្មេងស្រីអាយុ១៤ឆ្នាំ ឈ្មោះហេង ចន្ថាត្រូវស្លាប់ ដូចបានរៀបរាប់ក្នុងរបាយការណ៍នេះពីខាងដើម។ ភស្តុតាងនៃចលនាអបគមន៍ក្នុងខេត្តក្រចេះមិនទាន់ត្រូវបានដាក់បង្ហាញនោះទេ។[141] គួរឲ្យកត់សម្គាល់ផងដែរថា សកម្មជនដែលលោក ចាន់ សុវ៉េតជួយនោះត្រូវបានតុលាការទម្លាក់បទចោទប្រកាន់ប៉ុន្តែបទចោទលើលោកចាន់សុវ៉េតនៅរក្សាទុកដដែល។

លោកចាន់ សុវ៉េត បានទទួលជំនួយរបស់ភាគីពាក់ព័ន្ធថ្នាក់អន្តរជាតិមួយចំនួន ដើម្បីចេញពីប្រទេសទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សនៅថ្ងៃកំណត់កោះហៅរូបលោក។ សមាគមអាដហុកបានសំណូមពរឲ្យតុលាការពន្យារពេល ហើយតុលាការក៏យល់ព្រមតាមសំណើ។ ចុងក្រោយលោកចាន់ សុវ៉េតបានបង្ហាញខ្លួនចំពោះមុខតុលាការរាជធានីភ្នំពេញតាមការកោះហៅ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២។ លោកមិនត្រូវបានចាប់ឃុំនោះទេ[142]ប៉ុន្តែ បទចោទនៅរក្សាដដែល រហូតទីបំផុតបានទម្លាក់ចោលនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣។

---

[140]ម.ស.ម.ក'បុគ្គលិកអង្គការត្រូវបានកោះហៅដោយ តុលាការរាជធានីភ្នំពេញ' (សេចក្តីប្រកាសព័ត៌មានបន្ទាន់) (ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=24&id=5>

[141]ដូចខាងលើ។

[142]សេចក្តីថ្លែងការណ៍សមាគមអាដហុក'អ្នកការពារសិទ្ធិមនុស្សចាន់សុវេត មិនត្រូវបានចាប់ខ្លួនបន្ទាប់ពីការសាកសួរ' (ភ្នំពេញថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២) <http://www.adhoc-cambodia.org/?p=2732>

លោកចាន់ សុវ៉េតត្រូវបានដៅមុខសញ្ញា ដោយសារតែលោកបានធ្វើការងារក្នុងនាមជាបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល។ មានការជឿជាក់ជាច្រើនថា គោលបំណងនៃការគំរាមកំហែងលើលោកចាន់ សុវ៉េត គឺដើម្បីផ្ញើសារគំរាមកំហែងលើបុគ្គលិកសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។

បន្ថែមពីលើករណី លោក ចាន់ សុវ៉េត មានករណីមួយចំនួនដែលត្រូវបានលើកមកចោទប្រកាន់លើបុគ្គលិករបស់ សមាគមអាដហុក ដែលមានទីតាំងនៅតំបន់ជនបទក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ លោក សោម ចាន់គា ត្រូវបានរកឃើញថាមានកំហុសពីបទបរិហារកេរ្តិ៍ ក្នុងខែមករា ឆ្នាំ២០១១ និងតម្រូវឲ្យបង់ប្រាក់ពិន័យជាច្រើន ដោយសារតែលោកនិយាយពីជម្លោះដីធ្លីក្នុងខេត្តកំពង់ នៅធំក្នុងបទសម្ភាសន៍វិទ្យុ[143]ក្នុងឆ្នាំ២០០៩ លោក ប៉ែន ប៊ុនណា និង ឆាយ ធី បុគ្គលិកថ្នាក់ខេត្ត មានទីតាំងនៅខេត្តរតនៈគិរី ក៏ត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងសកម្មភាពផ្តល់អំណាចដល់អ្នកភូមិដើម្បីការពារសិទ្ធិដីធ្លីរបស់ពួកគេដោយសន្តិវិធី។ ពួកគេបានបង្ហាញខ្លួននៅតុលាការ ដើម្បីសាកសួរពាក់ព័ន្ធនឹងករណីទាំងនេះក្នុងឆ្នាំ២០១១។ ពួកគេទាំងពីរមិនត្រូវបានឃុំខ្លួននោះទេ ប៉ុន្តែ បទចោទមិនទាន់បានទម្លាក់ចោលនៅឡើយ។[144]

រដ្ឋាភិបាល ហាក់ដូចជាចង់បង្ក្រាបនូវសកម្មភាពសកម្មនិយមគ្រប់កម្រិត ដោយសារតែការបោះឆ្នោតខែកក្កដា ឆ្នាំ២០១៣។ ក្នុងឆ្នាំ២០១២ ថ្នាក់ដឹកនាំអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនត្រូវប្រឈមនឹងការគំរាមកំហែង។ លោក អ៊ូ វីរៈ ប្រធាន ម.ស.ម.ក ត្រូវបានកោះហៅដើម្បីទៅសាកសួរក្នុងតុលាការខេត្តរតនៈគិរីស្តីពី បទចោទប្រកាន់កាលពីឆ្នាំ២០០៩។[145] ក្រុមនិស្សិតដែលគាំទ្ររដ្ឋាភិបាលគំរាមលើ លោកសៀ ភារម្យ នាយក នៃក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន ថានឹងមានអំពើហិង្សាបន្ទាប់ពីលោកបានរិះគន់ ការផ្តួចផ្តើមសកម្មភាពនិស្សិតវាស់វែងដីធ្លី នៅក្នុងបទសម្ភាសន៍តាមវិទ្យុ។[146] បន្ថែមពីលើនោះ ដូចបានរៀបរាប់ខាងដើម ប្រធានអង្គការមិនមែនរដ្ឋាភិបាល លោកឈុត វុទ្ធី ត្រូវបានបាញ់សម្លាប់ ហើយប្រធានអង្គការមិនមែនរដ្ឋា

---

[143] អង្គការមាត្រា១៩ /ម.ស.ម.ក 'កម្ពុជា ៖ ការផ្តន្ទាទោសលើ សោម ចាន់គា គឺជាការវាយប្រហារមកលើសេរីភាពបញ្ចេញមតិ' (សេចក្តីថ្លែងការណ៍រួម) (ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១)
<http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=4&id=5>
[144] ម.ស.ម.ក /សមាគម អាដហុក 'បុគ្គលិកសិទ្ធិមនុស្សបីនាក់ និងអ្នកសារព័ត៌មានម្នាក់ ត្រូវបានកោះហៅឲ្យទៅបង្ហាញខ្លួននៅមុខតុលាការខេត្តរតនៈគិរីពីបទញុះញង់' (សេចក្តីប្រកាសព័ត៌មានបន្ទាន់រួម) (ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២)
<http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=295&id=5>
[145] ពាក្យបណ្តឹងដែលដាក់ដោយ មេឃុំ គិត ចែម ចោទប្រកាន់ អ៊ូ វីរៈ ជាមួយ ប៉ែន ប៊ុនណា និង ឆាយ ធី អ្នកសម្របសម្រួលថ្នាក់ខេត្ត និងមន្ត្រីស៊ើបអង្កេតនៃអង្គការសិទ្ធិមនុស្ស អាដហុក និងអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី លោករដ្ឋា វិសាល ពីបទញុះញង់ក្រុមជនជាតិដើមភាគតិចឲ្យធ្វើបាតុកម្មដោយបង្កអំពើហិង្សាប្រឆាំងនឹងក្រុមហ៊ុន ឌី អ៊ីម គ្រុប ដោយសារតែជម្លោះដីធ្លីជុំវិញកៅស៊ូ និងកើតមានជាបន្តនៅស្រុកលំផាត់ ខេត្តរតនៈគិរី។
មើល ម.ស.ម.ក 'ប្រធាន ម.ស.ម.ក លោក អ៊ូ វីរៈ នឹងប្រឈមនឹងការចោទសួរដោយតុលាការ ខេត្តរតនៈគិរី នៅថ្ងៃច័ន្ទ ទី៨ ខែតុលា ឆ្នាំ២០១២' (សេចក្តីប្រកាសព័ត៌មាន) (ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១២)
<http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=296&id=5>
[146] ម.ស.ម.ក 'បុគ្គលិកអង្គការត្រូវបានគំរាមកំហែង បន្ទាប់ពីផ្តល់បទសម្ភាសន៍ជាមួយវិទ្យុអាស៊ីសេរី' (សេចក្តីប្រកាសព័ត៌មានបន្ទាន់) (ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២)
<http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=23&id=5>

ភិបាល និងជាអ្នកសារព័ត៌មានដ៏លេចធ្លោ លោក ម៉ម សូណាង់ដូ ដែលកាលពីដំបូងរកឃើញថាមានកំហុសពីបទបង្កើតអបគមន៍ ដោយគ្មានភស្តុតាងគាំទ្រសាលក្រមនោះទេ និងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន ២០ ឆ្នាំ មុនពេលដែលទោសរបស់លោកត្រូវបានកាត់បន្ថយដោយសាលាឧទ្ធរណ៍។

អង្គភាពទាំងមូលក៏រងការគំរាមកំហែង ដោយសារតែលទ្ធផលនៃការងាររបស់ពួកគេក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្សផងដែរ។ រដ្ឋាភិបាល វាយប្រហារមកលើអង្គការមិនមែនរដ្ឋាភិបាល កាលពីអតីតកាល ពេលដែលអង្គការមិនមែនរដ្ឋាភិបាលនិយាយប្រឆាំងនឹងគោលនយោបាយរបស់រដ្ឋាភិបាល ពេលដែលពួកគេមានបំណងចង់ជួយដល់ជនរងគ្រោះនៃការរំលោភបំពានសិទ្ធិមនុស្ស ដើម្បីដាក់ពាក្យបណ្តឹងប្រឆាំងនឹងអាជ្ញាធរ រៀបចំវគ្គបណ្តុះបណ្តាល ឬជួយដល់សហគមន៍ក្នុងការរៀបចំធ្វើបាតុកម្ម និងនៅពេលដែលអង្គការមិនមែនរដ្ឋាភិបាលបោះពុម្ពរបាយការណ៍ រិះគន់លើគោលនយោបាយរបស់រដ្ឋាភិបាល។ ក្នុងករណីមួយចំនួន អាជ្ញាធរបានដាក់ពាក្យបណ្តឹងប្រឆាំងនឹងបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល។ ករណីរបស់ ប៉ែន ប៊ុនណា ឆាយ ធី និង សោម ចាន់គា ពីសមាគមអាដហុក ជាឧទាហរណ៍ស្រាប់ ក៏ដូចជា ករណីរបស់លោក អ៊ូ វីរៈ និង លោក ចាន់ សុវេត ដូចបានរៀបរាប់ខាងលើ។ ប៉ុន្តែ បន្ថែមលើការដៅមុខសញ្ញាលើបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល រដ្ឋាភិបាលក៏បានគំរាមព្យួរសកម្មភាពរបស់អង្គការមួយចំនួន ដោយសារតែលទ្ធផលនៃសកម្មភាពការងារផ្នែកសិទ្ធិមនុស្សរបស់ពួកគេផងដែរ។

**ករណីអ្នកការពារសិទ្ធិមនុស្ស៖ សមាគមជាងត្នោត និង ស្ពានទៅកាន់សន្តិភាពកម្ពុជា**

កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ ក្រសួងមហាផ្ទៃព្យួរសកម្មភាពរបស់អង្គការសិទ្ធិដីធ្លីដ៏ល្បីល្បាញ គឺសមាគមជាងត្នោត។[147] ប៉ុន្មានឆ្នាំមុនការព្យួរសកម្មភាព សមាគមជាងត្នោត បានបង្កើនការរិះគន់គ្រោងការណ៍របស់រដ្ឋាភិបាលដែលមានទឹកប្រាក់ ចំនួន១៤២លានដុល្លារ ក្នុងការអភិវឌ្ឍបណ្តាញផ្លូវដែកកម្ពុជា ដោយបង្ហាញថាការបណ្តេញចេញដោយបង្ខំទៅលើសហគមន៍ដែលនៅជិតខ្សែផ្លូវដែក នឹងធ្វើឲ្យពួកអ្នកភូមិកាន់តែក្រីក្រទៅៗ។ រដ្ឋាភិបាល បានឆ្លើយតបចំពោះការរិះគន់ទាំងនេះ ដោយការព្យួរសកម្មភាពរបស់សមាគមជាងត្នោត។ ក្នុងលិខិតពីក្រសួងមហាផ្ទៃ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១១ សមាគមជាងត្នោតត្រូវបានប្រាប់ឲ្យ "ព្យួរសកម្មភាព" ក្នុងរយៈពេលប្រាំខែ។ លិខិតនេះបានចោទប្រកាន់ដោយអយុត្តិធម៌មកលើសមាគមជាងត្នោត ដោយសារតែការខកខានមិនបានបញ្ជាក់ពីរចនាសម្ព័ន្ធគ្រប់គ្រង និងបានធ្វើវិសោធនកម្មលើលក្ខន្តិកៈរបស់ខ្លួន ដែលមិនអាចទទួលយកបាន។ ទោះបីជាអ្វីដែលមានក្នុងលិខិតរបស់ក្រសួងមហាផ្ទៃជាការពិត ប៉ុន្តែមិនមានមូលដ្ឋានច្បាប់ណាដែលអនុញ្ញាតឲ្យព្យួរសកម្មភាពបែបនេះនោះទេ។[148] ក្រសួងមហាផ្ទៃ បានផ្តល់ការពន្យល់ម្តងទៀតស្តីពីការព្យួរសកម្មភាពរបស់សមាគមជាងត្នោត ក្នុងសេចក្តីប្រកាសថ្ងៃទី១៣ ខែសីហា ដែលបានដាក់បង្ហោះលើវែបសាយរបស់ក្រសួងមហាផ្ទៃ ដែលចោទថា សមាគមជាងត្នោតបានញុះញង់ឲ្យប្រជាពលរដ្ឋប្រឆាំងនឹងការអភិវឌ្ឍន៍ថ្នាក់ជាតិ តាមរយៈការងារតស៊ូមតិរបស់ពួកគេ។[149]ការព្យួរសកម្មភាពរបស់ សមាគមជាងត្នោតត្រូវបញ្ចប់នៅខែមករា ឆ្នាំ២០១២។

សមាគមជាងត្នោត គឺគ្រាន់តែជាឧទាហរណ៍មួយក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលដទៃទៀតដែលរិះគន់ពីគម្រោងផ្លូវរថភ្លើង ឧបត្ថម្ភដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ក្នុងលិខិតទៅកាន់ ហ៊ុន សែន មុនពេលការព្យួរសកម្មភាពរបស់ សមាគមជាងត្នោត រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោកគាត ឈុន បានស្នើសុំឲ្យមានការ "ចាត់វិធានការបន្ទាន់" មកលើសមាគមជាងត្នោត និងស្ពានទៅកាន់សន្តិភាពកម្ពុជាដោយសារតែសកម្មនិយមរបស់ពួកគេ។ លោកក៏ត្រូវបានគេថតសំឡេងដោយនិយាយថា "កុំអនុញ្ញាតឲ្យអង្គការបរទេសធ្វើសកម្មភាពតស៊ូមតិ [...] ឬជ្រៀតជ្រែក។"[150] កាលពីថ្ងៃទី១៨ ខែសីហា ស្ពានទៅកាន់សន្តិភាពកម្ពុជា និងអង្គការមួយទៀតគឺ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ទទួលបានបញ្ជាពីរដ្ឋាភិបាលដើម្បី "រៀបចំការងាររបស់គេសាជាថ្មី" និងចោទប្រកាន់ពួកគេពីបទញុះញង់ប្រជាពលរដ្ឋទាំងនោះប្រឆាំងនឹងការស្តារនីតិសម្បទាប្រព័ន្ធផ្លូវដែកកម្ពុជា។[151]

---

[147]ម.ស.ម.ក 'ការព្យួរសកម្មភាពរបស់អង្គការសិទ្ធិដីធ្លី បញ្ជាក់ពីភាពភ័យខ្លាចរបស់សង្គមស៊ីវិលពាក់ព័ន្ធនឹងច្បាប់អង្គការដែលនឹងត្រូវបានអនុម័តក្នុងពេលឆាប់ៗខាងមុខ' (សេចក្តីប្រកាសព័ត៌មានបន្ទាន់) (ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=5&id=5>

[148]អង្គការពិភពលោកប្រឆាំងនឹងការធ្វើទារុណកម្មលើអ្នកដទៃ 'ការព្យួរសកម្មភាពដោយគ្មានមូលដ្ឋាន មកលើអង្គការសិទ្ធិមនុស្ស សមាគមជាងត្នោត' (សេចក្តីប្រកាសព័ត៌មាន) (ខែសីហា ឆ្នាំ២០១១) <http://www.omct.org/human-rights-defenders/urgent-interventions/cambodia/2011/08/d21402/>

[149]ម.ស.ម.ក 'កម្រងអត្ថបទករណីសិក្សា ៖ សមាគមជាងត្នោត' (សលាកប័ត្រព័ត៌មាន) (ខែកញ្ញា ឆ្នាំ២០១១) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=13&id=5>

[150]សើបាស្ទៀន ស្ត្រេងហ្គូ 'អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាស្ថិតក្រោមការគំរាមកំហែង',*អាស៊ី ថាមស៍* (ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១) <http://www.atimes.com/atimes/Southeast_Asia/MI20Ae02.html>

[151]ម.ស.ម.ក 'អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានផ្តល់ដំបូន្មានដោយក្រសួងក្នុងការ 'កែតម្រូវ' ការងាររបស់ពួកគេជាថ្មី' (សេចក្តីប្រកាសព័ត៌មានបន្ទាន់) (ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=6&id=5>

# ការវាយតម្លៃភាពប្រថុយប្រថាន

មាននិន្នាការជាក់លាក់ សម្រាប់ប្រភេទនៃការគំរាមកំហែងដែលប្រឈមដោយអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា។ ការប្រឈមសំខាន់និងធ្ងន់ធ្ងរបំផុតដែលប្រឈមដោយអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាគឺជាការវាយប្រហារលើរូបរាងកាយ ការចាប់ខ្លួនដោយគ្មានការចោទប្រកាន់រួមទាំងការយាយីផ្នែកច្បាប់និងប្រព័ន្ធតុលាការ។

អ្នកការពារសិទ្ធិមនុស្សបានប្រឈមនឹងការគំរាមកំហែងជាក់លាក់ ពិសេសដូចជា ចំពោះសមាជិករដ្ឋសភាគឺការគំរាមកំហែងដកអភ័យឯកសិទ្ធិរដ្ឋសភា ចំពោះ មេធាវីការពារសំណុំរឿងសិទ្ធិមនុស្សគឺការគំរាមកំហែងដកដំណែងជាមេធាវី ចំពោះលោកសង្ឃដែលជាសកម្មជនគឺការគំរាមកំហែងចាប់ផ្សឹក និងសម្រាប់អង្គការមិនមែនរដ្ឋាភិបាលគឺប្រឈមនឹងការព្យួរសកម្មភាពការងារ។

ដើម្បីវាយតម្លៃនូវស្ថានភាពសុវត្ថិភាពរបស់អ្នកការពារសិទ្ធិមនុស្ស នៅកម្ពុជា អ្វីដែលចាំបាច់គឺមើលលើភាពប្រថុយប្រថានពាក់ព័ន្ធនឹងការលើកកម្ពស់និងការពារសិទ្ធិមនុស្ស។ កម្រិតនៃភាពប្រថុយប្រថានដែលប្រឈមដោយអ្នកការពារសិទ្ធិមនុស្ស កើនឡើងយោងទៅលើការគំរាមកំហែងដែលពួកគេទទួលរង និងកម្រិតភាពងាយរងគ្រោះពីការគំរាមកំហែងទាំងនោះ។ ប៉ុន្តែ កម្រិតនៃភាពប្រថុយប្រថានអាចត្រូវបានកាត់បន្ថយតាមរយៈការបង្កើនសមត្ថភាពរបស់អ្នកការពារសិទ្ធិមនុស្ស ក្នុងការដោះស្រាយជាមួយនឹងការគំរាមកំហែងដែលពួកគេជួបប្រទះ។[152]

ចំពោះគោលបំណងនៃរបាយការណ៍នេះ **ការគំរាមកំហែង** គឺជាការប្រមាថមកលើអ្នកការពារសិទ្ធិមនុស្ស ដោយសារតែការងាររបស់ពួកគេ ហើយការប្រមាថបែបនេះនឹងកើតមានឡើងផ្ទួនៗ ប្រសិនបើ អ្នកការពារសិទ្ធិមនុស្សទាំងនោះបន្តការងាររបស់ពួកគេ។ កម្រិតនៃការគំរាមកំហែង គឺផ្អែកលើភាពធ្ងន់ធ្ងរ នៃផលប៉ះពាល់ដែលទទួលបានពីការគំរាមកំហែង និងភាពអាចទៅរួចនៃការគំរាមកំហែងនីមួយៗគឺផ្អែកលើកម្រិតនៃភាពញឹកញាប់ដែលប្រភេទនៃការគំរាមកំហែងនេះកើតមានឡើងក្នុងអតីតកាល។

ភាពធ្ងន់ធ្ងរនិងភាពអាចទៅរួចនៃការគំរាមកំហែង ត្រូវបានកំណត់តាមរយៈព័ត៌មានដែលត្រូវបានប្រមូលបានតាមការសម្ភាសន៍ក៏ដូចជាការតាមដានយ៉ាងជិតស្និទ្ធ និងការស្រាវជ្រាវយ៉ាងទូលំទូលាយស្តីពីស្ថានភាពនៃអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា។

---

[152] អ្នកការពារនៅជួរមុខ 'សៀវភៅណែនាំសម្រាប់ការការពារអ្នកការពារសិទ្ធិមនុស្ស' (ដាប់ប្លីន, ខែវិច្ឆិកា ឆ្នាំ២០០៧) <http://www.frontlinedefenders.org/files/en/Front%20Line%20Protection%20Handbook.pdf>

**ភាពងាយរងគ្រោះ** សំដៅដល់កត្តាបង្កើនឱកាសដែលអ្នកការពារសិទ្ធិមនុស្សម្នាក់ឬមួយក្រុមរងនូវការវាយប្រហារ ឬរងគ្រោះថ្នាក់ធ្ងន់ធ្ងរដោយសារតែលទ្ធផលនៃការវាយប្រហារ។[153] អ្នកការពារសិទ្ធិមនុស្សទាំងអស់ងាយរងគ្រោះជាខ្លាំងនៅកម្ពុជា ដោយសារតែកត្តា ដូចជាបរិបទផ្នែកច្បាប់ ការខ្វះខាតស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិឯករាជ្យប្រព័ន្ធតុលាការពុករលួយនិងមានទំនាក់ទំនងផ្នែកនយោបាយ ការប្រើប្រាស់ភ្នាក់ងាររដ្ឋដើម្បីបំបិទសំឡេងប្រឆាំង និងការរាលដាលនៃកម្រិតនិទណ្ឌភាពរបស់អ្នករំលោភបំពានលើសិទ្ធិ របស់អ្នកការពារសិទ្ធិមនុស្ស។ ប៉ុន្តែភាពងាយរងគ្រោះក៏ខុសគ្នាទៅតាមប្រភេទនៃអ្នកការពារសិទ្ធិមនុស្សផងដែរ។ ប្រភេទផ្សេងៗ នៃអ្នកការពារសិទ្ធិមនុស្ស មានលទ្ធភាពខុសៗគ្នាក្នុងការដោះស្រាយជាមួយនឹងការគំរាមកំហែង ប្រភេទនៃអ្នកការពារសិទ្ធិមនុស្សមួយចំនួន ត្រៀមខ្លួនបានច្រើនជាងអ្នកដទៃទៀតក្នុងការដោះស្រាយជាមួយការគំរាមកំហែង ហេតុដូច្នេះបានកាត់បន្ថយភាពងាយរងគ្រោះ។

ឧទាហរណ៍ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដែលមានទីតាំងនៅភ្នំពេញនឹងមានភាពងាយរងគ្រោះតិចតួចនិងទទួលបានការការពារប្រសើរជាង សកម្មជនថ្នាក់មូលដ្ឋានដែលធ្វើការនៅខេត្តដាច់ស្រយាល ដោយសារតែបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅក្នុងទីតាំងកណ្តាល មានទំនាក់ទំនងជាមួយនឹងអង្គការដទៃទៀតដែលអាចមានរបៀបការពារសុវត្ថិភាពរួចជាស្រេច មានទំនាក់ទំនងជាប់លាប់ជាមួយអង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយអន្តរជាតិ និងសារព័ត៌មានដទៃមានលទ្ធភាពរកអ្នកតំណាងផ្នែកច្បាប់ និងការបង្កើនចំណេះដឹង និងការយល់ដឹងពីភាពប្រថុយប្រថានបានច្រើនជាង។ បន្ថែមពីលើនោះ អ្នកការពារសិទ្ធិមនុស្សមួយចំនួនត្រូវបានដៅមុខសញ្ញាជាញឹកញាប់ហើយប្រឈមនឹងការគំរាមកំហែងធ្ងន់ធ្ងរជាងដោយសារតែប្រភេទនៃការងាររបស់ពួកគេដូចជា សកម្មជនសិទ្ធិដីធ្លីថ្នាក់មូលដ្ឋានឬសកម្មជនសហជីពជាដើម។ ដូច្នេះកម្រិតនៃភាពងាយរងគ្រោះដោយសារតែប្រភេទការគំរាមកំហែងខុសៗគ្នា គឺផ្អែកលើប្រភេទនៃអ្នកការពារសិទ្ធិមនុស្សដែលកំពុងតែប្រឈមនឹងការគំរាមកំហែង។

ក្នុងផ្នែកតូចនេះ ម.ស.ម.ក និងអង្គការមាត្រា១៩ នឹងវិភាគនូវភាពប្រថុយប្រថានដែលអ្នកការពារសិទ្ធិមនុស្សកម្ពុជាជួបប្រទះ។ ការគំរាមកំហែងធំៗដែលបានរកឃើញនឹងត្រូវកំណត់សូចនាករផ្អែកលើកម្រិតធ្ងន់ធ្ងរនៃការគំរាមកំហែងនិងភាពញឹកញាប់ ដូចបានបង្ហាញក្នុងតារាងខាងក្រោម។ភាពងាយរងគ្រោះរបស់អ្នកការពារសិទ្ធិមនុស្សនៃការគំរាមកំហែងជាក់លាក់នោះ ក៏នឹងត្រូវកំណត់សូចនាការ ដោយយោងទៅលើថាតើអ្នកការពារសិទ្ធិមនុស្សនឹងងាយរងគ្រោះចំពោះការគំរាមកំហែងនោះ ផ្អែកលើវិធានការការពារដែលមានពីមុន (ឬក៏មិនមាន) ស្ថានភាពផ្នែកសង្គម-សេដ្ឋកិច្ច របស់អ្នកការពារសិទ្ធិមនុស្សទីតាំង និងប្រភេទនៃការងារដែលពួកគេកំពុងធ្វើ។

[153]ដូចខាងលើ។

| | ការគំរាមកំហែង | ភាពងាយរងគ្រោះ |
|---|---|---|
| ខ្ពស់ | ការគំរាមកំហែងអាចកើតមាន និង/ឬមានផលប៉ះពាល់ខ្ពស់ ដល់សន្តិសុខនិងសុវត្ថិភាពរបស់អ្នកការពារសិទ្ធិមនុស្ស ប្រសិនបើកើតឡើង | សមត្ថភាពនៅទាបក្នុងការដោះស្រាយជាមួយការគំរាមកំហែង |
| មធ្យម | ការគំរាមកំហែងអាចកើតមាននិង/ឬមានផលប៉ះពាល់ល្មមដល់សន្តិសុខនិងសុវត្ថិភាពរបស់អ្នកការពារសិទ្ធិមនុស្ស ប្រសិនបើកើតឡើង | សមត្ថភាពមធ្យមក្នុងការដោះស្រាយជាមួយការគំរាមកំហែង |
| ទាប | ការគំរាមកំហែងអាចកើតមាននិង/ឬមានផលប៉ះពាល់ទាបដល់សន្តិសុខនិងសុវត្ថិភាពរបស់អ្នកការពារសិទ្ធិមនុស្ស ប្រសិនបើកើតឡើង | សមត្ថភាពខ្ពស់ក្នុងការដោះស្រាយជាមួយការគំរាមកំហែង |

វិធីសាស្ត្រនេះ ត្រូវបានអង្គការមាត្រា១៩ ក្នុងប្រទេសមិកស៊ិកកូ អនុវត្តជាច្រើនឆ្នាំ គឺជាជញ្ជីងសាមញ្ញដាក់ឲ្យប្រើប្រាស់ដោយ ម.ស.ម.ក និងអង្គការមាត្រា១៩ ដើម្បីប្រៀបធៀបនិងធៀបមើលភាពប្រថុយប្រថានផ្សេងៗដែលអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាជួបប្រទះ និងដើម្បីបង្កើតរូបភាពរួមស្តីពីស្ថានភាពសន្តិសុខរបស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា។

## ការប្រឈមសំខាន់ៗ

មានការយល់ស្របជាឯកច្ឆ័ន្ទ តាមរយៈបទសម្ភាសន៍ដែលធ្វើឡើងជាមួយអ្នកការពារសិទ្ធិមនុស្ស និងត្រូវបានបញ្ជាក់បន្ថែមដោយការស្រាវជ្រាវដែលបានធ្វើឡើងថា "ភ្នាក់ងារដែលធ្វើទុក្ខបុកម្នេញ" ដ៏ខ្លាំងក្លាមកលើអ្នកការពារសិទ្ធិមនុស្សគឺរដ្ឋាភិបាល។ ប្រភពនៃការគំរាមកំហែងធំបន្ទាប់គឺបុគ្គល ឬក្រុមដែលមានទំនាក់ទំនងជាមួយ គ.ប.ក។ អ្នកការពារសិទ្ធិមនុស្ស ក៏បានរងការគំរាមកំហែងពីសន្តិសុខរបស់ក្រុមហ៊ុនឯកជន ដែលធ្វើការឲ្យក្រុមហ៊ុន ដែលជាទូទៅមានមន្ត្រីរដ្ឋាភិបាល ឬក្រុមគ្រួសារ និងមិត្តភក្តិរបស់ពួកគេជាម្ចាស់។

*អំពើហិង្សាលើរូបរាងកាយនិងការឃាត់៖កម្រិតនៃការគំរាមកំហែងខ្ពស់*

មុនឆ្នាំ២០១២ មើលទៅដូចជាការវាយប្រហារផ្នែករូបរាងកាយមកលើអ្នកការពារសិទ្ធិមនុស្ស ថយចុះ ហើយអាជ្ញាធរចូលចិត្តប្រើតុលាការ និងនីតិកម្មដើម្បីសម្លុតបំភ័យនិងបំបិទមាត់អ្នកការពារសិទ្ធិមនុស្ស ជាជាងប្រើអំពើហិង្សាផ្នែកខាងក្រៅ។ ប៉ុន្តែ ឈានចូលចុងឆ្នាំ២០១២ និងទូទាំងឆ្នាំ២០១២ ចំនួនវាយប្រហាររូបរាងកាយលើអ្នកការពារសិទ្ធិមនុស្ស មានការកើនឡើងគួរឲ្យកត់សម្គាល់។ដូចបានពិភាក្សាខាងលើមានអ្នកការពារសិទ្ធិមនុស្សពីរនាក់គឺអ្នកសារព័ត៌មានហង្ស សេរីឧត្តម និងសកម្មជនបរិស្ថាន លោកឈុត វុទ្ធីត្រូវបានសម្លាប់ក្នុងឆ្នាំ២០១២។ សម្រាប់អ្នកការពារសិទ្ធិមនុស្សជាច្រើនការគំរាម

កំហែងក្នុងរូបបែបជាអំពើហិង្សាលើរូបរាងកាយនិងការយាយី ជាការគំរាមកំហែងធ្ងន់ធ្ងរនិងញឹកញាប់ដែលមានផលប៉ះពាល់ជាខ្លាំងលើសុវត្ថិភាព និងការងាររបស់ពួកគេ។

*ការចាប់ខ្លួនដោយគ្មានបទចោទ៖ កម្រិតការគំរាមកំហែងខ្ពស់*

ការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្ស ជាពិសេសសកម្មជនដែលចូលរួមក្នុងសកម្មភាពបាតុកម្មជារឿងធម្មតា។ ដូចបានកត់សម្គាល់ខាងលើសមាគមអាដហុកបានរាយការណ៍ថាមានសកម្មជនដីធ្លីយ៉ាងហោចណាស់២០១នាក់ ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ២០១២។ នេះជានិន្នាការដែលអាជ្ញាធរនឹងចាប់ខ្លួននិងឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សបណ្តោះអាសន្ន ហើយជាញឹកញាប់គឺដោយគ្មានបទចោទប្រកាន់។ ភាពញឹកញាប់ដែលការគំរាមកំហែងបែបនេះកើតមានឡើង និងភាពធ្ងន់ធ្ងរនៃការគំរាមកំហែងត្រូវបានចាត់ទុកថាមានកម្រិតខ្ពស់។

*ការយាយីផ្នែកច្បាប់និងប្រព័ន្ធតុលាការ៖ កម្រិតការគំរាមកំហែងខ្ពស់*

ដូចបានកំណត់ខាងលើក្របខណ្ឌច្បាប់នៅកម្ពុជា ជាការគំរាមកំហែងមួយសម្រាប់អ្នកការពារសិទ្ធិមនុស្សនិងការងាររបស់ពួកគេ។ អង្គការសិទ្ធិមនុស្សជាច្រើន ទាំងថ្នាក់ជាតិនិងអន្តរជាតិបានចងក្រងករណីការយាយីផ្នែកប្រព័ន្ធតុលាការមកលើអ្នកការពារសិទ្ធិមនុស្ស ដែលជាញឹកញាប់កើតឡើងដោយសារតែច្បាប់មានលក្ខណៈរឹតបន្តឹង និងមិនច្បាស់លាស់[154]ឬតាមរយៈការបង្កើតបទឧក្រិដ្ឋ។[155] ការយាយីផ្នែកច្បាប់និងប្រព័ន្ធតុលាការ កើតមានជាក់ស្តែងមកលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា។ ក្នុងករណីមួយចំនួនអ្នកការពារសិទ្ធិមនុស្ស គ្រាន់តែកោះហៅទៅកាន់តុលាការដើម្បីសាកសួរប៉ុន្តែពួកគេមិនទាន់ត្រូវបានចោទប្រកាន់នោះទេ។ មានការពិបាកក្នុងការទាយមើលថាតើអាជ្ញាធរនឹងដំណើរការករណីនេះបន្តទៀតដោយរបៀបណា ប៉ុន្តែការគំរាមកំហែងផ្នែកច្បាប់ក្នុងដំណាក់កាលដំបូងនិងការយាយីដោយប្រើប្រព័ន្ធតុលាការគឺជាក់ស្តែង ធ្ងន់ធ្ងរជាទូទៅនិងមានផលប៉ះពាល់ខ្ពស់មកលើសន្តិសុខរបស់អ្នកការពារសិទ្ធិមនុស្ស។

*ការរារាំងលើការងារនិងជីវភាពរស់នៅ៖ កម្រិតការគំរាមកំហែងមធ្យម*

ការគំរាមកំហែងមួយចំនួនដែលបានរកឃើញក្នុងផ្នែកមុន គឺកើតមានជាក់ស្តែងចំពោះក្រុមអ្នកការពារសិទ្ធិមនុស្សជាក់លាក់មួយចំនួនហើយពាក់ព័ន្ធនឹងលទ្ធភាពការបន្តការងាររបស់ពួកគេ ដូចជា ការបាត់បង់អភ័យឯកសិទ្ធិសភាប្រឈមដោយសមាជិកសភាដែលហ៊ាននិយាយ ការដកតំណែងមេធាវីប្រឈមដោយមេធាវីការពាររឿងក្តីសិទ្ធិមនុស្ស ការចាប់ផ្សឹករបស់ព្រះសង្ឃជាសកម្មជន និងការគំរាមកំហែងព្យួរសកម្មភាពប្រឈមដោយអង្គការមិនមែនរដ្ឋាភិបាល។ ខណៈពេលដែលការបាត់បង់អភ័យ

---

[154]មើលផ្នែកស្តីពី ការការពារផ្នែកច្បាប់ ខាងលើ។

[155]មើលផ្នែកខាងលើដើម្បីព័ត៌មានលម្អិតលើករណីរបស់ លោក ម៉ម សូណង់ដូ អ្នកស្រី យ៉ោម បុប្ផា និងអ្នកស្រី ទឹម សាក់មុន្នី។

ឯកសិទ្ធិសភាឬការដេកដំណែងមេធាវី មិនមានផលប៉ះពាល់ភ្លាមៗ និងគ្រោះថ្នាក់លើសុវត្ថិភាព និងសន្តិសុខរបស់អ្នកការពារសិទ្ធិមនុស្ស ប៉ុន្តែវាអាចបណ្តាលឲ្យបាត់បង់នូវការការពារផ្នែកវិជ្ជាជីវៈនិងមិនអាចឲ្យអ្នកការពារសិទ្ធិមនុស្សទាំងនោះអាចទ្រទ្រង់ជីវភាពរបស់ខ្លួនបាន។

*សន្តិសុខផ្នែកព័ត៌មាននៅលើអ៊ីនធើណែតៈ កម្រិតការគំរាមកំហែងទាប*

ការយល់ដឹងពីសន្តិសុខផ្នែកព័ត៌មាន សម្រាប់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា នៅមានកម្រិតទាបនៅឡើយជាពិសេសពាក់ព័ន្ធនឹងទំនាក់ទំនងរបស់ពួកគេលើប្រព័ន្ធអ៊ីនធើណេត។ ការកើនឡើង នៃការប្រើប្រាស់អ៊ីនធើណែត ដើម្បីចែកចាយព័ត៌មានឯករាជ្យ គំនិតនិងការជជែកពិភាក្សាបានបង្កឲ្យមានការប៉ុនប៉ងពីសំណាក់អាជ្ញាធរដើម្បីបង្ក្រាបសេរីភាពលើប្រព័ន្ធអ៊ីនធើណែត។ ឧទាហរណ៍ បុគ្គលិក អង្គការមិនមែនរដ្ឋាភិបាលជាច្រើន បានរាយការណ៍ថាអ៊ីម៉ែលរបស់ពួកគេត្រូវបានគេតាមដាននិងបិទមិនអាចឲ្យដំណើរការបាន។ ក្នុងឆ្នាំ២០១២ រដ្ឋាភិបាលបានប្រកាសពីផែនការដើម្បីអនុម័តច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ីនធើណែតនៅកម្ពុជា ដើម្បីការពារ "បុគ្គលដែលមានគំនិតមិនល្អ...មិនឲ្យចែកចាយព័ត៌មានខុស" ។[156] ច្បាប់នេះនៅក្នុងដំណាក់កាលធ្វើសេចក្តីព្រាងនៅឡើយ ហើយមិនទាន់មានការបញ្ជាក់ថាច្បាប់នេះនឹងត្រូវបានដាក់បង្ហាញដល់សាធារណជននោះទេ។ ប៉ុន្តែ ការគំរាមកំហែងស្តីពីសន្តិសុខផ្នែកព័ត៌មានមានកម្រិតទាប ដោយសារតែចំនួនអ្នកប្រើប្រាស់អ៊ីនធើណែតនៅកម្ពុជាមានចំនួនតិចនៅឡើយ។ ក្នុងខែធ្នូ ឆ្នាំ២០១២ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានប៉ាន់ស្មានថា មានចំនួនអ្នកប្រើប្រាស់អ៊ីនធើណែត២.៧លាននាក់ ស្មើនឹង១៨ភាគរយនៃចំនួនប្រជាពលរដ្ឋសរុប។ ចំនួននេះមានការកើនឡើងគួរឲ្យកត់សម្គាល់ បើធៀបការប៉ាន់ប្រមាណរបស់ធនាគារពិភពលោកក្នុងឆ្នាំ២០១១ ដែលបានរាយការណ៍ថាអត្រាចំនួនអ្នកប្រើប្រាស់មាន៣.១ភាគរយ។[157] ម.ស.ម.ក និងអង្គការមាត្រា១៩បានកត់សម្គាល់ថាការគំរាមកំហែងជាក់លាក់នេះ នឹងកើនឡើងនាពេលខាងមុខដោយសារតែប្រជាពលរដ្ឋកម្ពុជានឹងប្រើប្រាស់អ៊ីនធើណែត សម្រាប់ធ្វើការងារការពារសិទ្ធិមនុស្ស និងដោយសារតែអាជ្ញាធរនឹងអភិវឌ្ឍន៍យន្តការទំនើបៗដើម្បីទប់ស្កាត់នូវសកម្មនិយមលើអ៊ីនធើណែត។

---

[156]ប្រ៊ីហ្កេត ឌី សីតូ និង គឹម យុទ្ធណា ' "ជនអគតិជំរុញឲ្យមានការបង្កើតច្បាប់គ្រប់គ្រងអ៊ីនធើណែត": មន្ត្រីរដ្ឋាភិបាល' *សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍* (ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២) <http://www.phnompenhpost.com/2012052456372/National/the-ill-willed-spark-cyber-law-officials.html>

[157]ម.ស.ម.ក "សេរីភាពបញ្ចេញមតិ និងការគាបសង្កត់លើប្រព័ន្ធអ៊ីនធើណែតនៅកម្ពុជា" (របាយការណ៍សង្ខេប) (ខែមេសា ឆ្នាំ២០១៣) <http://www.cchrcambodia.org/admin/media/analysis/analysis/english/2013-04-29-Internet-Censorship-Briefing-Note-eng.pdf>

| កម្រិតនៃការគំរាមកំហែង | | |
|---|---|---|
| | ខ្ពស់ | អំពើហិង្សាឬការយាយីលើរូបរាងកាយ |
| | ខ្ពស់ | ការចាប់ខ្លួនដោយគ្មានបទចោទ |
| | ខ្ពស់ | ការយាយីផ្នែកច្បាប់និងប្រព័ន្ធតុលាការ |
| | មធ្យម | បាត់បង់អភ័យឯកសិទ្ធិសភា |
| | មធ្យម | ដកតំណែងមេធាវី |
| | មធ្យម | ចាប់ផ្សឹក |
| | មធ្យម | ព្យួរសកម្មភាព |
| | ទាប | ការរំលោភបំពានលើសន្តិសុខផ្នែកព័ត៌មានលើអ៊ីនធើណែត |

**ភាពងាយរងគ្រោះ**

ប្រសិនបើអ្នកការពារសិទ្ធិមនុស្សមិនអាចការពារការគំរាមកំហែង ពួកគេអាចកាត់បន្ថយភាពងាយរងគ្រោះនៃការគំរាមកំហែង ដោយបង្កើនសមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយជាមួយការគំរាមកំហែងតាមរយៈវិធានការជាក់ស្ដែងមួយចំនួនដែលនឹងត្រូវពិភាក្សានៅក្នុងផ្នែក "សេចក្ដីសន្និដ្ឋាននិងអនុសាសន៍" ខាងក្រោម។

*សកម្មជនដីធ្លីមូលដ្ឋាន៖ ភាពងាយរងគ្រោះខ្ពស់*

សកម្មជនដីធ្លីមូលដ្ឋាន ប្រឈមនឹងការគំរាមកំហែងភាគច្រើន។ ពួកគេតែងតែធ្វើការនៅក្នុងតំបន់ដាច់ស្រយាល មានលទ្ធភាពតិចតួចក្នុងការទំនាក់ទំនងទៅសារព័ត៌មាននិងសហគមន៍អន្តរជាតិខ្វះខាតធនធានសម្រាប់ការការពារផ្នែកច្បាប់ និងមិនបានប្រមូលផ្ដុំជាសមូហភាពដែលនឹងអាចទទួលបានការការពារសន្តិសុខបានគ្រប់គ្រាន់។ បន្ថែមពីលើនោះពួកគេធ្វើការលើបញ្ហាដែលជាចំណុចរសើបនិងលាក់កំបាំងរបស់រដ្ឋាភិបាលនិងក្រុមហ៊ុនឯកជន។

ពួកគេមានភាពប្រថុយប្រថានខ្ពស់ក្នុងការរងអំពើហិង្សា និងការយាយីលើរូបរាងកាយនិងតែងតែត្រូវយាយីនិងវាយដំដោយអាជ្ញាធរ ជាពិសេសដោយសារតែពួកគេ ជាញឹកញាប់បានចូលរួមក្នុងការធ្វើបាតុកម្ម។សកម្មជនដីធ្លីមូលដ្ឋាន ក៏មានភាពងាយរងគ្រោះជាពិសេសពីការចាប់ខ្លួនដោយគ្មានបទចោទ និងការយាយីផ្នែកច្បាប់/ផ្នែកប្រព័ន្ធតុលាការផងដែរ។

*សកម្មជនសហជីព៖ ភាពងាយរងគ្រោះខ្ពស់*

សកម្មជនសហជីពតែងតែប្រឈមនឹងភាពងាយរងគ្រោះ ប្រហាក់ប្រហែលនឹងសកម្មជនដីធ្លីមូលដ្ឋាន ដោយសារតែពួកគេជាញឹកញាប់បានចូលរួមក្នុងបាតុកម្ម និងកង្វះខាតវិធានការការពារសន្តិសុខ។ ចំណុចនេះបានបង្កឲ្យមានភាពងាយរងគ្រោះខ្ពស់នៃការគំរាមកំហែង ពីការវាយប្រហាររូបរាងកាយ។

ការយាយីផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ មកលើសកម្មជនសហជីពកើតមានជាធម្មតា។ ភាពងាយរងគ្រោះចំពោះការគំរាមកំហែងនេះកាន់តែខ្ពស់ ដោយសារតែកង្វះខាតលទ្ធភាពទទួលបានការការពារផ្នែកច្បាប់ កង្វះខាតចំណេះដឹងពាក់ព័ន្ធនឹងការគំរាមកំហែង កង្វះខាតទំនាក់ទំនងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត ឬទំនាក់ទំនងទៅដៃគូអន្តរជាតិ។ ភាពប្រថុយប្រថានក្នុងការរងការចាប់ខ្លួនដោយគ្មានបទចោទក៏មានកម្រិតខ្ពស់ដោយសារថាជាញឹកញាប់ពួកគេចូលរួមក្នុងបាតុកម្ម។

*សកម្មជនដីធ្លីជាស្ត្រី៖ភាពងាយរងគ្រោះខ្ពស់*

ដូចបានរៀបរាប់ខាងលើ ការប្រណិប័តន៍ពីសំណាក់អាជ្ញាធរមកលើសកម្មជនជាស្ត្រី ហាក់ដូចជាដូចគ្នាទៅនឹងការប្រណិប័តន៍មកលើសកម្មជនជាបុរស។ ប៉ុន្តែដោយសារតែស្ត្រីជាអ្នកមើលថែទាំគ្រួសារ ដូច្នេះនាំឲ្យមានការបន្ថែមនូវកម្រិតភាពងាយរងគ្រោះ។ បន្ថែមពីលើនោះ ភាពងាយរងគ្រោះរបស់អ្នកការពារសិទ្ធិមនុស្សដែលមានផ្ទៃពោះ គឺកាន់តែខ្ពស់ ដោយសារតែអាចនឹងមានការវាយប្រហាររូបរាងកាយនិងការយាយី ធ្វើឲ្យមានការប៉ះពាល់ដល់ការមានផ្ទៃពោះ។

ដោយសារតែការចូលរួមជាញឹកញាប់ក្នុងបាតុកម្ម របស់សកម្មជនជាស្ត្រី ភាពប្រថុយប្រថាននៃការចាប់ខ្លួនដោយគ្មានបទចោទ និងការយាយីដោយប្រព័ន្ធតុលាការគឺមានកម្រិតខ្ពស់។ ដូចបានបង្ហាញក្នុងករណីការចាប់ខ្លួនប្រជាពលរដ្ឋក្នុងតំបន់បុរីកីឡា ដែលមានរៀបរាប់ខាងលើ សកម្មជនសិទ្ធិដីធ្លីជាស្ត្រីត្រូវបានចាប់ខ្លួន និងឃុំខ្លួនដោយគ្មានមូលដ្ឋានព្រមជាមួយកូនរបស់ពួកគេ។

*បុគ្គលិកសារព័ត៌មាននិងអ្នកកាសែត៖ ភាពងាយរងគ្រោះមធ្យម*

បុគ្គលិកសារព័ត៌មាននិងអ្នកកាសែតតែងតែប្រឈមមុខនឹងការយាយីផ្នែកច្បាប់ និងប្រព័ន្ធតុលាការ ជាលទ្ធផលនៃការធ្វើការរបស់ពួកគេ ក្នុងការចែករំលែកព័ត៌មាន និងគំនិតដោយឯករាជ្យនិងសេរី។ មិនមានយន្តការការពារជាក់លាក់ត្រៀមជាស្រេចសម្រាប់អ្នកកាសែត ហើយពួកគេតែងតែធ្វើការនៅក្នុង

តំបន់ដាច់ស្រយាលនិងតែម្នាក់ឯង។ កម្រិតផ្នែកសង្គម-សេដ្ឋកិច្ចកម្រិតទាបរបស់ពួកបុគ្គលិកសារព័ត៌មាន និងអ្នកកាសែតក៏ហាមឃាត់ពួកគេមិនឲ្យទទួលបានការការពារផ្នែកច្បាប់បានគ្រប់គ្រាន់នោះដែរ។[158]

បុគ្គលិកសារព័ត៌មាននិងអ្នកកាសែតជាញឹកញាប់ក៏រងនូវការយាយីលើរូបរាងកាយនៅពេលដែលពួកគេមានបំណងចង់ផ្សព្វផ្សាយអត្ថបទព័ត៌មានដែលមានលក្ខណៈរិះគន់រដ្ឋាភិបាលឬពេលខ្លះពួកគេរងអំពើហិង្សា ដោយសារតែចរិតលក្ខណៈនៃការងាររបស់ពួកគេដូចជា ការរាយការណ៍ពីការធ្វើបាតុកម្មឬជម្លោះដីធ្លីជាដើម។

អាជ្ញាធរប្រើប្រាស់នូវយុទ្ធវិធីសម្លុតបំភ័យ មកលើបុគ្គលិកសារព័ត៌មាននិងអ្នកកាសែត ក្នុងគោលបំណងបំបិទមាត់អ្នកជំទាស់ ដូច្នេះបានធ្វើឲ្យមានផលប៉ះពាល់ដែលកើតមានបន្ទាប់និងវប្បធម៌នៃការត្រួតពិនិត្យខ្លួនឯង។

*មេធាវីការពាររឿងក្ដីសិទ្ធិមនុស្ស៖ ភាពងាយរងគ្រោះមធ្យម*

មេធាវីការពាររឿងក្ដីសិទ្ធិមនុស្សជាទូទៅជួបប្រទះនឹងការយាយីផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌និងភាពប្រថុយប្រថានក្នុងការដេកតំណែងជាមេធាវី។ មេធាវីការពាររឿងក្ដីសិទ្ធិមនុស្ស ងាយរងគ្រោះពីការយាយីផ្នែកច្បាប់និងប្រព័ន្ធយុត្តិធម៌ ជាពិសេស ប្រសិនបើពួកគេមិនមានទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាលនិងជាពិសេសប្រសិនបើ គណៈមេធាវី ដាក់វិន័យមិនឲ្យមេធាវីមានទំនាក់ទំនងជាមួយនឹងសារព័ត៌មាន។ដូចបានឃើញក្នុងផ្នែកមុនៗ គណៈមេធាវីមានទំនាក់ទំនងផ្នែកនយោបាយ[159]ហើយដូច្នេះ នឹងមានភាពប្រថុយប្រថានខ្ពស់ប្រសិនបើមេធាវីទទួលការពារក្ដីដែលមានលក្ខណៈរសើបប្រសិនបើពួកគេមានបំណងចង់ការពារប្រភពជីវភាពរបស់ពួកគេ។ ចំនួនមេធាវីដែលដកហូតតំណែងថ្មីៗនេះ នៅមានកម្រិតទាប ទោះបីជាចរិតលក្ខណៈពាក់ព័ន្ធនឹងនយោបាយរបស់គណៈមេធាវី ដែលមានន័យថាមេធាវីនៅតែប្រឈមនឹងភាពងាយរងគ្រោះខ្ពស់។

ចាប់តាំងពីចាប់ផ្ដើមគម្រោងនេះ ម.ស.ម.ក និងអង្គការមាត្រា១៩ មិនបានកត់ត្រានូវករណីថ្មីៗដែលមានអំពើហិង្សារូបរាងកាយមកលើមេធាវីការពាររឿងក្ដីសិទ្ធិមនុស្សនោះទេ។

*អង្គការមិនមែនរដ្ឋាភិបាល៖ភាពងាយរងគ្រោះមធ្យម*

---

[158]អែន ឡៃសម៉ែរ៍ អ្នកតំណាងអង្គការយូណេស្កូ និងលោក ជេមស៍ ហ៊ីណាន់ អ្នកតំណាងរង និងមន្ត្រីទទួលបន្ទុកនៃ ឧត្តមស្នងការនៃការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅកម្ពុជា"ទិវាសេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០១២ ៖ លើកកម្ពស់សារព័ត៌មានដែលមានទំនួលខុសត្រូវនៅកម្ពុជា" (លិខិតបញ្ចេញគំនិត) *សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍* (ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២) <http://www.un.org.kh/index.php?option=com_content&view=article&id=559:world-press-freedom-day-2012-promoting-responsible-journalism-in-cambodia&catid=47:features&Itemid=88>

[159]លីកាដូ 'ការដាក់កំហិតលើអាជីពផ្នែកច្បាប់ ដោយគណៈមេធាវី ៖ ការគំរាមកំហែង លើជំនួយផ្នែកច្បាប់នៅកម្ពុជា' (អត្ថបទសង្ខេប) (ខែធ្នូ ឆ្នាំ២០០៧) <https://www.licadho-cambodia.org/~licadhoc/reports.php?perm=114&pagenb=4&filter=-1>

បុគ្គលិកធ្វើការនៅអង្គការមិនមែនរដ្ឋាភិបាលហាក់ដូចជាមានការការពារពីការឃាយីនិងការវាយប្រហារលើរូបរាងកាយច្រើនជាងដោយសារតែបណ្តាញរបស់ពួកគេ និងការយល់ដឹង និងការត្រៀមជាស្រេចចំពោះស្ថានភាពផ្នែកសន្តិសុខ។ ប៉ុន្តែទោះបីជា បុគ្គលិកធ្វើការនៅអង្គការមិនមែនរដ្ឋាភិបាល អាចមានការការពារខ្លះៗពីអង្គភាពរបស់ពួកគេនិងទំនាក់ទំនងជាមួយនឹងម្ចាស់ជំនួយអន្តរជាតិ និងស្ថានទូត ចរិតលក្ខណៈនៃតួនាទីរបស់អង្គការសង្គមស៊ីវិល និងចរិតលក្ខណៈបែបនយោបាយរបស់ប្រព័ន្ធតុលាការ បានធ្វើឲ្យពួកគេងាយរងគ្រោះពីការឃាយីផ្នែកច្បាប់និងប្រព័ន្ធតុលាការ។

ការគំរាមកំហែងដ៏សំខាន់មួយទៀតរបស់ បុគ្គលិកធ្វើការនៅអង្គការមិនមែនរដ្ឋាភិបាលគឺការគំរាមកំហែងលើសន្តិសុខផ្នែកព័ត៌មាននៅលើប្រព័ន្ធអ៊ីនធើណែត។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ជាទូទៅមានការការពារសន្តិសុខផ្នែកព័ត៌មានរបស់ពួកគេតាមរយៈអង្គភាពរបស់ពួកគេប៉ុន្តែពួកគេមិនត្រូវបានការពារពេលដែលពួកគេនៅផ្ទះ។ ភាពងាយរងគ្រោះចំពោះអសន្តិសុខផ្នែកឌីជីថលរបស់ពួកគេមានកម្រិតមធ្យម។

ក្រៅពីបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលត្រូវបានគំរាមកំហែងក្នុងនាមជាបុគ្គលហើយ អង្គភាពរបស់ពួកគេផ្ទាល់ក៏តែងតែត្រូវបានដៅមុខសញ្ញាផងដែរដូចជាករណីសមាគមជាងត្នោតស្ថានទៅកាន់ សន្តិភាពកម្ពុជានិងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលដែលបានរៀបរាប់ក្នុងផ្នែកខាងដើម។ បុគ្គលិកអង្គការសិទ្ធិមនុស្ស តែងតែប្រឆាំងយ៉ាងខ្លាំងក្លាចំពោះការរំលោភបំពានសិទ្ធិមនុស្សដែលប្រព្រឹត្តដោយរដ្ឋាភិបាលឬបុគ្គលដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយរដ្ឋាភិបាល។ ចំណុចនេះមានន័យថាអង្គការសិទ្ធិមនុស្សអាចប្រឈមនឹងភាពប្រថុយប្រថានជាក់ស្តែងក្នុងការព្យួរសកម្មភាព។ ការគំរាមកំហែងនេះ មានផលប៉ះពាល់ធ្ងន់ធ្ងរលើការងាររបស់អង្គការមិនមែនរដ្ឋាភិបាលនិងភាពរស់រានមានជីវិតរបស់ពួកគេ។ ប៉ុន្តែយុទ្ធសាស្ត្រនៃការដៅមុខសញ្ញាមកលើបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលតែម្នាក់ គឺមានលក្ខណៈសាមញ្ញ។ ក្នុងករណីដែលអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាទាំងមូលត្រូវបានដៅមុខសញ្ញា ម្ចាស់ជំនួយនិងដៃគូអន្តរជាតិនៃអង្គការនោះ តែងតែលូកដៃចូល ដើម្បីដាក់សម្ពាធមកលើរដ្ឋាភិបាលដើម្បីបញ្ឈប់យុទ្ធវិធីសម្លុតបំភ័យ។ ប្រសិនបើរាប់បញ្ចូលការគាំទ្រពីអន្តរជាតិរួមជាមួយនឹងការផ្អាកការអនុម័តច្បាប់អង្គការ ភាពងាយរងគ្រោះនៃអង្គការមិនមែនរដ្ឋាភិបាលទាំងមូល ក្នុងពេលបច្ចុប្បន្ននៅមានកម្រិតទាបនៅឡើយ។

*សមាជិកសភាគណបក្សប្រឆាំង៖ ភាពងាយរងគ្រោះទាបទៅមធ្យម*

សមាជិកសភាគណបក្សប្រឆាំងជាធម្មតាមានកម្រិតផ្នែកសង្គម-សេដ្ឋកិច្ច មានភាពល្បីល្បាញនិងមានវិធានការការពារសន្តិសុខត្រៀមជាស្រេច ដូច្នេះភាពងាយរងគ្រោះចំពោះអំពើហិង្សារូបរាងកាយ និងការចាប់ខ្លួន មានកម្រិតទាប។ បន្ថែមពីលើនោះសមាជិកគណបក្សប្រឆាំង ក៏មានការការពារផ្នែកព័ត៌មានរួចជាស្រេច ដូច្នេះបានកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេក្នុងបរិបទនេះ។

ប៉ុន្តែដោយសារតែចរិតលក្ខណៈនៃការងាររបស់ពួកគេ ក្នុងការប្រឈមមុខជាមួយនឹងគណបក្សកាន់អំណាច ការគំរាមកំហែងសំខាន់មួយដែលប្រឈមដោយសមាជិកសភាគណបក្សប្រឆាំង គឺការដកអភ័យឯកសិទ្ធិសភា ដែលជារឿងងាយស្រួលសម្រាប់ គ.ប.ក។ នេះមានន័យថា សមាជិកសភាគណបក្សប្រឆាំង ងាយរងគ្រោះពីការគំរាមកំហែងនេះ និងជាលទ្ធផលងាយរងគ្រោះពីការយាយីផ្នែកច្បាប់ និងប្រព័ន្ធតុលាការ។

*ព្រះសង្ឃ ៖ ភាពងាយរងគ្រោះទាប*

ការគំរាមកំហែងធំបំផុតរបស់ព្រះសង្ឃគឺការចាប់ផ្សឹក។ ជាលទ្ធផលនៃសកម្មនិយមរបស់ព្រះអង្គ ព្រះតេជគុណ លួន សុវ៉ាត ត្រូវបានហាមឃាត់មិនឲ្យចូលទៅស្នាក់នៅក្នុងកុដិរបស់ព្រះតេជគុណ នៅវត្តឧណ្ណាលោម និងវត្តដទៃទៀតនៅជុំវិញទីក្រុងភ្នំពេញ។ ការដឹកនាំនៃភាតរភាពរបស់ព្រះសង្ឃ ត្រូវបានគេអះអាងថាមានទំនាក់ទំនងជិតស្និទ្ធនឹង គ .ប.ក ដែលបង្កើនឲ្យមានភាពងាយរងគ្រោះកាន់តែខ្ពស់សម្រាប់ព្រះសង្ឃ។[160] ដូច្នេះ ព្រះសង្ឃដែលគាំទ្រសកម្មជនមូលដ្ឋាន នឹងមានគ្រោះថ្នាក់ពីការចាប់ផ្សឹក។ ភាពងាយរងគ្រោះរបស់ព្រះសង្ឃដែលជាសកម្មជនចំពោះការគំរាមកំហែងនេះមានកម្រិតខ្ពស់។

ប៉ុន្តែ ថ្មីៗនេះមិនមានកំណត់ត្រាណាដែលបង្ហាញពីការយាយី និងការវាយប្រហារលើរូបរាងកាយ ឬការយាយីផ្នែកច្បាប់ និងប្រព័ន្ធតុលាការ ដែលមានមកលើព្រះសង្ឃដើម្បីបង្ហាញពីនិន្នាការទាំងមូលនោះទេ។

[160]ម.ស.ម.ក 'កម្រងអត្ថបទករណីសិក្សា ៖ ព្រះតេជគុណ លួន សុវ៉ាត' (សលាកប័ត្រព័ត៌មាន) (ខែកក្កដា ឆ្នាំ២០១១) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=5&id=5>

## កម្រិតនៃភាពងាយរងគ្រោះ

| | |
|---|---|
| ខ្ពស់ | សកម្មជនសិទ្ធិដីធ្លីមូលដ្ឋាន |
| ខ្ពស់ | សកម្មជនសហជីព |
| ខ្ពស់ | សកម្មជនដីធ្លីដែលជាស្ត្រី |
| មធ្យមទៅខ្ពស់ | អ្នកកាសែត និងសារព័ត៌មាន |
| មធ្យម | មេធាវីការពាររឿងក្តីសិទ្ធិមនុស្ស |
| មធ្យម | អង្គការមិនមែនរដ្ឋាភិបាល |
| ទាបទៅមធ្យម | សមាជិកសភា |
| ទាប | ព្រះសង្ឃ |

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

នេះបង្ហាញឲ្យឃើញច្បាស់ថា អ្នកការពារសិទ្ធិមនុស្សកម្ពុជា ប្រឈមនឹងភាពប្រថុយប្រថានចំពោះគ្រោះថ្នាក់ក្នុងកម្រិតខ្ពស់ ក្នុងបរិបទនៃការងាររបស់ពួកគេ។ ការគំរាមកំហែងប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សមាន ច្រើនករណី ហើយដែលជាញឹកញាប់មិនអាចដៅស្មានទុកមុនបាន។ កង្វះខាតមធ្យោបាយត្រឹមត្រូវក្នុងការវាយតម្លៃ និងដោះស្រាយចំពោះការគំរាមកំហែងប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស កាន់តែធ្វើឲ្យការគំរាមកំហែងទាំងនេះ កើនឡើង។ បន្ថែមពីលើនោះ ការខ្វះខាតនៃការត្រៀមទុកជាមុន ការយល់ដឹង និងចំណេះដឹងក្នុងចំណោមអ្នកការពារសិទ្ធិមនុស្ស ពាក់ព័ន្ធនឹងការកាត់បន្ថយការគំរាមកំហែង និងភាពប្រថុយប្រថាន ក៏បង្កើននូវភាពងាយរងគ្រោះជាក់ស្តែងរបស់ពួកគេផងដែរ។ គួរកត់សម្គាល់ផងដែរថា ស្ថានភាពសន្តិសុខ ក្នុងឆ្នាំ២០១២ កាន់តែធ្ងន់ធ្ងរទៅប្រសិនបើប្រៀបធៀបនឹងឆ្នាំមុនៗ។ ការធ្លាក់ចុះនេះ មួយចំនួនអាចបណ្តាលមកពីការខិតចូលនៃការបោះឆ្នោតរដ្ឋសភា ក្នុងខែកក្កដា ឆ្នាំ២០១៣ ក៏ដូចជាការកើនឡើងនៃការរើបម្រះដែលបានមកពីការរំលោភបំពានសិទ្ធិដីធ្លី និងសិទ្ធិពលករ។

អនុសាសន៍ខាងក្រោម សម្រាប់ដាក់ជូន អ្នកការពារសិទ្ធិមនុស្ស អង្គការសិទ្ធិមនុស្ស សហគមន៍សិទ្ធិមនុស្សទូទៅនៅកម្ពុជា និងរដ្ឋាភិបាល ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយភាពប្រថុយប្រថានដែលប្រឈមដោយអ្នកការពារសិទ្ធិមនុស្ស ដូចបានកំណត់ក្នុងការវាយតម្លៃភាពប្រថុយប្រថានខាងលើ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពរួមរបស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា។ អ្នកការពារសិទ្ធិមនុស្ស ជាផ្នែកសំខាន់មួយនៃសង្គមប្រជាធិបតេយ្យ។ នៅពេលអ្នកការពារសិទ្ធិមនុស្ស អាចអនុវត្តការងាររបស់ពួកគេដោយភាពប្រថុយប្រថានតិចតួច នោះស្ថានភាពសិទ្ធិមនុស្សទូទៅនៅកម្ពុជានឹងកាន់តែប្រសើរឡើង។

## អនុសាសន៍

## អ្នកការពារសិទ្ធិមនុស្ស៖

- បញ្ជាក់ថាខ្លួនជាអ្នកការពារសិទ្ធិមនុស្ស ជាសាធារណៈ ប្រើប្រាស់មុខងារនេះ និងផ្សព្វផ្សាយការពិតដែលថាការងាររបស់អ្នកត្រូវបានការពារដោយច្បាប់អន្តរជាតិ។ ចំណុចនេះនឹងធានាថា អាជ្ញាធរ និងសង្គមនឹងបានដឹងកាន់តែច្បាស់ពីកម្រិតនៃការការពារដែលមាន។

    - បញ្ជាក់ខ្លួនឯងថាជាអ្នកការពារសិទ្ធិមនុស្ស ក្នុងទម្រង់នៃការបញ្ជាក់អត្តសញ្ញាណទាំងអស់ ដូចជាកាតទំនាក់ទំនង លិខិតផ្លូវការ និងប្រវត្តិក្នុងបណ្តាញសារព័ត៌មានសង្គម។
    - ពេលអនុវត្តការងាររបស់អ្នក ត្រូវកាន់លិខិតបញ្ជាក់ខ្លួនអ្នកថាជាអ្នកការពារសិទ្ធិមនុស្ស រៀបរាប់លម្អិតពីកាតព្វកិច្ច និងអាណត្តិការងាររបស់អ្នក និង/ឬ ភ្ជាប់ខ្លួនអ្នកទៅនឹងអង្គការ។

- បង្កើតបណ្តាញសន្តិសុខ និងសាមគ្គីភាព

    - ស្វែងរកមើលសហការី អង្គការ ឬសូម្បីតែមន្ត្រីរដ្ឋាភិបាល ដែលអាចផ្តល់ជំនួយក្នុងករណីមានរឿងកើតឡើងបន្ទាន់ សូមចងចាំទុកថាការរួមសាមគ្គីគ្នាក្នុងដំណាក់កាលដំបូង អាចនឹងការពារការរំលោភបំពានមិនឲ្យកើតមានបន្តទៀត។
    - ស្វែងរកជំនួយផ្នែកច្បាប់ជាទៀងទាត់ពីមេធាវី និងអង្គការដែលគួរឲ្យជឿជាក់បាន។
    - ធានាថាមានអ្នកតំណាងផ្នែកច្បាប់ ពេលអ្នកប្រឈមនឹងការឃាឃីដោយប្រព័ន្ធតុលាការ ប្រសិនបើអ្នកត្រូវការដាក់ពាក្យបណ្តឹងទៅតុលាការ ឬប្រសិនបើអ្នកត្រូវបានចាប់ខ្លួន ឬឃុំខ្លួន។

- បង្កើតផែនការបន្ទាន់ជាពិសេស និងវិធានការការពារសន្តិសុខ។

    - យល់ និងវិភាគពីភាពជាប់ពាក់ព័ន្ធស្តីពីផ្នែកច្បាប់ និងនយោបាយលើការងាររបស់អ្នក និងរកមើលការគំរាមកំហែងដែលអាចកើតមានឡើង ផ្អែកលើ ភេទ ជាតិសាសន៍ សាវតារសាសនា។ល។ និងបង្កើតវិធានការសន្តិសុខដើម្បីទប់ទល់នឹងការគំរាមកំហែងទាំងនោះ ដូចជា សន្តិសុខផ្នែកព័ត៌មាន សន្តិសុខផ្នែកទ្រព្យសម្បត្តិ និងសន្តិសុខផ្ទាល់ខ្លួន។
    - តាមដានមើលការផ្លាស់ប្តូរនៃមជ្ឈដ្ឋានសន្តិសុខ យ៉ាងជាប់លាប់ (ឧ. ការអនុម័តច្បាប់ថ្មី ការបោះឆ្នោតដែលជិតចូលមកដល់ ឬការបង្កើនការចាប់ខ្លួន ) ដើម្បីការពារមិនឲ្យការគំរាមកំហែងកើតឡើង និងដើម្បីត្រៀមខ្លួនជាស្រេច នៅពេលដែលការគំរាមកំហែងនោះកើតឡើង។

- ប្រសិនបើការគំរាមកំហែងកើតមានឡើង ត្រៀមខ្លួនដើម្បីដាក់ពាក្យបណ្តឹងទៅអាជ្ញាធរ (ប្រសិនបើអាច និងមានសុវត្ថិភាពក្នុងការធ្វើបែបនោះ)។

- បង្កើតផែនការបន្ទាន់ ដើម្បីចូលរួមធ្វើបាតុកម្ម និងក្នុងករណីដែលមានការចាប់ខ្លួនដោយប្រើកម្លាំង។ (ចំណុចនេះ មានសារៈសំខាន់ជាពិសេសសម្រាប់ សកម្មជនដីធ្លីជាស្ត្រី និងសកម្មជនសហជីព)។

  - ធ្វើការកំណត់ជាមួយសហការី និងដៃគូ អំពីព័ត៌មានដែលមិនគួរបង្ហាញក្នុងកំឡុងពេលសាកសួរ ឬសួរចម្លើយ ដើម្បីមិនឲ្យមានអន្តរាយដល់សុវត្ថិភាពរបស់អ្នក និងសហការី។
  - ក្នុងអំឡុងពេលឃុំខ្លួន ត្រូវធានាថាមាននរណាម្នាក់ពីបណ្តាញសាមគ្គី/សន្តិសុខ របស់អ្នកដឹងពីកន្លែងដែលអ្នកនៅ លក្ខខណ្ឌ និងការចោទប្រកាន់។ អ្នកក៏ត្រូវតែដឹងឲ្យបានច្បាស់ពីសិទ្ធិរបស់អ្នកដើម្បីអាចរកឃើញ និងការពារនូវការបំពាននាពេលអនាគត។
  - បង្ហាញឲ្យច្បាស់ពីតួនាទីរបស់អ្នក ក្នុងអំឡុងពេលធ្វើបាតុកម្ម ដូចជា ការចូលរួម ឬតាមដាន និងរៀបចំផែនការទៅតាមនោះ។
  - ពេលតាមដានការធ្វើបាតុកម្ម ផ្តល់ព័ត៌មានដល់សហការីដែលនៅក្រៅតំបន់ធ្វើបាតុកម្ម អំពីរឿងរ៉ាវលម្អិតនៃការបំពាន និងព័ត៌មានណាក៏ដោយអំពីបុគ្គលដែលត្រូវបានឃុំខ្លួន។
  - ពេលចងក្រងស្ថានភាពការបំពាន ត្រូវធានាថាអ្នកទទួលបានការការពារពីសហការីពេលដែលកំពុងថតវីដេអូ ឬថតរូប និងធានាថាអ្នកមានម៉េម៉ូរីកាតទំនេរ ក្នុងករណីដែលនគរបាលព្យាយាមរឹបអូសយកសម្ភារៈដែលផ្ទុករូបថត ឬវីដេអូទាំងនោះ។
  - ពេលដាក់បង្ហោះភស្តុតាងនៃការបំពាន ទៅលើអ៊ីនធើណែត ត្រូវធានាថាអ្នកបានលុបទិន្នន័យសំខាន់ និងបានការពារអត្តសញ្ញាណរបស់ជនរងគ្រោះរួចរាល់ហើយ។

- រក្សាទំនាក់ទំនងជាមួយនឹងបណ្តាញដែលអ្នកជឿទុកចិត្តយ៉ាងជាប់លាប់។

  - ធានាថាអ្នកបានផ្តល់ព័ត៌មានជាញឹកញាប់អំពីកន្លែងដែលអ្នកនៅ ទៅកាន់សហការីផ្សេងៗទៀតជាពិសេស ពេលដែលធ្វើការនៅក្នុងតំបន់ដាច់ស្រយាល។ ធានាថាអ្នកមានទូរស័ព្ទ ឬមធ្យោបាយទំនាក់ទំនងដទៃទៀត សម្រាប់ទាក់ទងសហការី និងសាច់ញាតិដទៃទៀតគ្រប់ពេលវេលា។ ចំណុចនេះមានសារៈសំខាន់ជាពិសេសចំពោះសកម្មជនដីធ្លីមូលដ្ឋាន និងអ្នកធ្វើការក្នុងបណ្តាញសារព័ត៌មានដែលធ្វើការរាយការណ៍លើបញ្ហានោះ។

**អង្គការសិទ្ធិមនុស្ស ៖**

- បង្កើតវិធានការសន្តិសុខជាសមូហភាព និងផែនការសន្តិសុខ រួមជាមួយសហការី និងដៃគូទាំងអស់ ព្រមទាំងគោលបំណងសំខាន់ក្នុងការកាត់បន្ថយ ផលប៉ះពាល់ដែលបានមកពីការគំរាមកំហែង និងដើម្បីធានាថានឹងមានការឆ្លើយតបយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព ក្នុងករណីមានបញ្ហាបន្ទាន់។ ជាតុផ្សំមួយចំនួនដែលគួរតែរាប់បញ្ចូលរួមមាន ៖
    - ការវាយតម្លៃភាពប្រថុយប្រថាន និងវិធានការការពារ
    - ការឆ្លើយតបយ៉ាងឆាប់រហ័សក្នុងការស្វែងរកតំណាងផ្នែកច្បាប់
    - ផែនការគ្រប់គ្រងវិបត្តិ និងបញ្ហាបន្ទាន់ដើម្បីធានាឲ្យមានភាពជាប់លាប់នៃប្រតិបត្តិការនោះ ក្នុងករណីដែលមានរឿងរ៉ាវកើតឡើងពិតប្រាកដមែន
    - ចងក្រង និងវិភាគនូវព្រឹត្តិការណ៍ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខទាំងអស់ ក្នុងករណីដែលអាចទៅរួច ដាក់ពាក្យបណ្តឹងជាផ្លូវការទៅអាជ្ញាធរ ដោយមិនខ្វល់ពីលទ្ធផលរំពឹងទុកដែលនឹងទទួលបានមកពីការស៊ើបអង្កេត។
    - បែងចែកធនធានចាំបាច់ ក្នុងការផ្តល់អំណាចដល់បុគ្គលិក ដើម្បីបង្កើតវិធានការដែលតម្រូវឲ្យមានក្នុងការការពារផ្ទាល់ខ្លួន រួមទាំងវគ្គបណ្តុះបណ្តាល ការវាយតម្លៃសន្តិសុខផ្ទាល់ខ្លួន និងឧបករណ៍ដើម្បីអាចធ្វើគោលការណ៍សន្តិសុខ និងសុវត្ថិភាពមានសារៈសំខាន់ក្នុងប្រតិបត្តិការទាំងមូល។

- បង្កើតនីតិវិធី ក្នុងករណីដែលមានការឃុំខ្លួនដោយគ្មានមូលដ្ឋាន និងឬខុសច្បាប់ និងការបាត់ខ្លួនដោយបង្ខំរបស់បុគ្គលិក ឬអ្នករួមប្រតិបត្តិការ ជាមួយនឹងគោលបំណងដើម្បីធានាថានឹងមានការឆ្លើយតបបានយ៉ាងឆាប់រហ័ស។ ជាតុផ្សំមួយចំនួនរួមបញ្ចូល មានដូចជា ៖
    - បញ្ជីមណ្ឌលឃុំខ្លួន អាជ្ញាធរពាក់ព័ន្ធ និងមេធាវី ឬអង្គការដែលអាចជានាឲ្យមានការឆ្លើយតបយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព។
    - ពេលធ្លាក់ក្នុងស្ថានភាពបែបនោះ អង្គការគួរតែផ្តល់រឿងរ៉ាវលម្អិតឲ្យបានឆាប់រហ័សអំពីបទចោទ និងលក្ខខណ្ឌជាក់ស្តែង និងលក្ខខណ្ឌការឃុំខ្លួនរបស់បុគ្គលដែលត្រូវឃុំខ្លួន ទៅកាន់ដៃគូ ម្ចាស់មូលនិធិ និងបណ្តាញសាមគ្គីទាំងអស់។

- ផ្តល់លិខិត ឬការបញ្ជាក់ពីអត្តសញ្ញាណដែលពាក់ព័ន្ធនឹងអង្គការ ទៅដល់បុគ្គលិក ឬអ្នករួមប្រតិបត្តិការ។

- រៀបចំការសង្ខេបតាមពេលវេលា និងទៀងទាត់ ជាមួយម្ចាស់ជំនួយ សហប្រជាជាតិនិងតំណាងអង្គការអន្តរជាតិ ស្តីពីស្ថានភាពសន្តិសុខ ដែលប្រឈមដោយអង្គការនីមួយៗ ដើម្បីពង្រឹងបណ្តាញសាមគ្គី និងសន្តិសុខ។ ម្ចាស់ជំនួយគួរតែត្រូវបានជំរុញទឹកចិត្តឲ្យផ្តល់មូលនិធិដល់គម្រោងដែលមានគោលបំណងការពារ និងលុបបំបាត់បទឧក្រិដ្ឋនៃសេរីភាពបញ្ចេញមតិ។

**សហគមន៍សិទ្ធិមនុស្ស៖**

- លើកកម្ពស់ការយល់ដឹង និងបង្កើនទំនាក់ទំនងជាមួយអាជ្ញាធរ និងសាធារណជនទូទៅអំពីសារៈសំខាន់នៃអ្នកការពារសិទ្ធិមនុស្ស ការងាររបស់ពួកគេ និងសន្តិសុខរបស់ពួកគេ។
    - បង្កើតនូវយន្តការសន្ទនា ជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដើម្បីដោះស្រាយជាមួយការព្រួយបារម្ភពីសុវត្ថិភាពរបស់អ្នកការពារសិទ្ធិមនុស្ស និងពិភាក្សាពីកំណែទម្រង់ដែលចាំបាច់ និងសកម្មភាពនយោបាយដែលត្រូវការដើម្បីចៀសវាងការរំលោភបំពានដែលកើតឡើងជាបន្តបន្ទាប់។
- បង្កើតប្រព័ន្ធដាស់តឿនក្នុងដំណាក់កាលដំបូង ដើម្បីបញ្ចេញព័ត៌មានស្តីពីការរំលោភបំពានមកលើអ្នកការពារសិទ្ធិមនុស្ស។
- សម្របសម្រួលកិច្ចខិតខំប្រឹងប្រែង ក្នុងចំណោមភាគីពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពការបណ្តុះបណ្តាលផ្នែកសន្តិសុខ ការប្រមូលព័ត៌មាន និងការចែកចាយ និងការការពារដល់អ្នកការពារសិទ្ធិមនុស្ស។
    - បង្កើតយន្តការរួមមួយដែលអ្នកការពារសិទ្ធិមនុស្ស អង្គការមិនមែនរដ្ឋាភិបាល និងសកម្មជនដទៃទៀតអាចនឹងពឹងពាក់ក្នុងការការពារសិទ្ធិមនុស្ស រួមទាំងជំនួយផ្នែកច្បាប់ និងវិធានការការពារបន្ទាន់សម្រាប់ពួកគេ និងក្រុមគ្រួសាររបស់ពួកគេ។ សកម្មភាពពិសេស គួរតែត្រូវបានអនុវត្តដើម្បីអាចឲ្យបុគ្គលដែលមិនស្គាល់ថាខ្លួនគេជាអ្នកការពារសិទ្ធិមនុស្ស ឬក៏អ្នកដែលមិនមានទំនាក់ទំនងជាមួយនឹងអង្គការណាមួយទទួលបាននូវព័ត៌មានទាំងនោះ។
    - បង្កើតយន្តការដើម្បីដោះដូរព័ត៌មានស្តីពីបញ្ហាសន្តិសុខ រវាងអ្នកការពារសិទ្ធិមនុស្ស និងអង្គការសិទ្ធិមនុស្ស ក្នុងលក្ខខណ្ឌជាយុទ្ធសាស្ត្រ និងជាប្រព័ន្ធ ជាមួយនឹងការយកចិត្តទុកដាក់ជាពិសេសទៅលើអ្នកការពារសិទ្ធិមនុស្ស និងអង្គការដែលមានមូលដ្ឋាននៅតំបន់ដាច់ស្រយាល។
    - បង្កើតឲ្យមានកិច្ចខិតខំប្រឹងប្រែង និងធនធានរួម ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលស្តីពីបញ្ហាសន្តិសុខ សុវត្ថិភាពផ្នែកច្បាប់ និងនីតិវិធីសន្តិសុខបែបលម្អិត និងផែនការបន្ទាន់។

- ធ្វើការតស៊ូមតិដើម្បីឲ្យមានការបង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិឯករាជ្យ ដើម្បីតាមដានស្ថានភាពអ្នកការពារសិទ្ធិមនុស្ស និងផ្ដល់ដំបូន្មានផ្នែកសន្តិសុខ ជំនួយ និងការការពារដល់អ្នកការពារសិទ្ធិមនុស្ស។

**រាជរដ្ឋាភិបាលកម្ពុជា ៖**

- ទទួលស្គាល់ពីសារៈសំខាន់របស់អ្នកការពារសិទ្ធិមនុស្ស និងអង្គការសិទ្ធិមនុស្ស និងតម្រូវការឲ្យមានការការពារសម្រាប់ពួកគេ។
    - ទោះបីជាសមាជិកសភាគណបក្សប្រឆាំងមួយចំនួន ក៏ជាអ្នកការពារសិទ្ធិមនុស្សដែរ អ្នកការពារសិទ្ធិមនុស្សជាទូទៅ គឺអព្យាក្រឹត្យ។ ពួកគេមិនមានទំនាក់ទំនងជាមួយគណបក្សប្រឆាំង ពួកគេអំពាវនាវឲ្យគណបក្សណាក៏ដោយដែលកាន់អំណាច ការពារសិទ្ធិមនុស្ស មិនមែនតែគណបក្សជាក់លាក់ណានោះទេ។ ពិតជាមានសារៈសំខាន់ក្នុងការទទួលស្គាល់ការអំពាវនាវរបស់សមាជិកសភាទាំងនេះ ដើម្បីការការពារសិទ្ធិមនុស្ស មិនមែនដោយសារហេតុផលនយោបាយនោះទេ។
    - ថ្កោលទោសលើការវាយប្រហារ ដែលកើតមានឡើងតបទៅនឹងការអនុវត្តន៍សេរីភាពបញ្ចេញមតិ និងហាមឃាត់មិនឲ្យបង្ហាញពីសេចក្ដីថ្លែងការណ៍ ដែលហាក់ដូចជាបង្កើនភាពងាយរងគ្រោះនៃបុគ្គលដែលត្រូវបានដៅមុខសញ្ញាចំពោះការអនុវត្តន៍នៃសិទ្ធិសេរីភាពបញ្ចេញមតិរបស់ពួកគេ។

បង្កើតវិធានការពិសេស ដើម្បីការពារអ្នកការពារសិទ្ធិមនុស្ស ដែលតែងតែត្រូវបានដៅមុខសញ្ញាដោយសារតែការងាររបស់ពួកគេ និងធានាថា អ្នកការពារសិទ្ធិមនុស្ស ដែលរងគ្រោះពីបទឧក្រិដ្ឋ និងការរំលោភបំពានសិទ្ធិមនុស្សអាចទទួលបានសំណងសមស្រប។

- ធ្វើការ និងធ្វើសហប្រតិបត្តិការយ៉ាងជិតដិតជាមួយអ្នកតំណាងពិសេស របស់ សហប្រជាជាតិ ស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដើម្បីទទួលបាននូវការណែនាំជាចាំបាច់ និងជំនួយក្នុងការពង្រឹងដល់លក្ខខណ្ឌសន្តិសុខរបស់អ្នកការពារសិទ្ធិមនុស្ស។

- បង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិឯករាជ្យ ដើម្បីតាមដានពីស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្សទាំងមូលនិងដើម្បីផ្ដល់ការការពារ និងអាចចុះទៅដល់តំបន់ដាច់ស្រយាលនៃប្រទេស។

- ផ្សព្វផ្សាយរបាយការណ៍តាមពេលវេលាកំណត់ ស្តីពីលក្ខខណ្ឌសន្តិសុខសម្រាប់អ្នកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នីតិវិធីផ្នែកច្បាប់ ជុំវិញការរំលោភបំពានដែលបានកើតឡើង។

- បង្កើតឲ្យមានកិច្ចពិគ្រោះយោបល់ដ៏ទូលំទូលាយ ជាមួយសង្គមស៊ីវិល ដើម្បីទទួលបានមតិយោបល់ចាំបាច់ក្នុងការធ្វើវិសោធនកម្មច្បាប់ដែលរឹតបន្តឹងសិទ្ធិមនុស្ស ហើយដែលមិនអនុលោមតាមច្បាប់រដ្ឋធម្មនុញ្ញ នៃប្រទេសកម្ពុជា ក៏ដូចជាកាតព្វកិច្ចច្បាប់សិទ្ធិមនុស្សអន្តរជាតិ។
- កាត់បន្ថយអំពើពុករលួយក្នុងជួររដ្ឋាភិបាល និងប្រព័ន្ធតុលាការដើម្បីធានានីតិរដ្ឋ រួមទាំងការស៊ើបអង្កេតដ៏មានប្រសិទ្ធភាពចំពោះការរំលោភបំពានប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស ជាពិសេស ការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ។
    - បង្កើតគណៈកម្មការនិទណ្ឌភាពដើម្បីពិនិត្យមើលការស៊ើបអង្កេត ដោយមានវត្តមាន និងជំនួយពីអង្គការជាតិ និងអន្តរជាតិ។
    - អនុញ្ញាតឲ្យសារព័ត៌មានអាចចូលទៅយកព័ត៌មាននៅក្នុងតុលាការបាន។
- ធានាថានគរបាល ទាហាន និងសន្តិសុខឯកជន តំណាងរបស់អាជ្ញាធរណាមួយដែលនឹងមានទំនាក់ទំនងជាមួយនឹងអ្នកការពារសិទ្ធិមនុស្ស ទទួលបានការបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស និងភាពខុសច្បាប់នៃការប្រើប្រាស់កម្លាំងមិនសមាមាត្រ។ នគរបាល និងទាហាន គួរតែត្រូវបានប្រើដើម្បីការពារប្រជាពលរដ្ឋកម្ពុជា មិនមែនប្រើដើម្បីការពារនូវផលប្រយោជន៍របស់អ្នកមានអំណាចមួយចំនួនតូចនោះទេ។
    - រៀបចំវគ្គបណ្តុះបណ្តាលឲ្យបានត្រឹមត្រូវទៅកាន់កងកម្លាំងនគរបាល ដើម្បីការពារសិទ្ធិមនុស្សរបស់បាតុករដើម្បីសម្របសម្រួលការងាររបស់អ្នកការពារសិទ្ធិមនុស្ស ក្នុងខណៈពេលធ្វើបាតុកម្ម។
    - បង្កើតវិធានការពិសេសដើម្បីធានាថាអង្គការ និងមេធាវី អាចទៅសួរសុខទុក្ខអ្នកការពារសិទ្ធិមនុស្សក្នុងពេលជាប់ឃុំខ្លួន ដើម្បីធានានូវសុខមាលភាព និងលក្ខខណ្ឌសុវត្ថិភាពក្នុងពន្ធនាគារ។

# ឧបសម្ព័ន្ធ ៖ អក្សរកាត់

| | |
|---|---|
| | សន្និសីទអង្គការសង្គមស៊ីវិលអាស៊ាន |
| សមាគមអាដហុក | សមាគម ការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍នៅកម្ពុជា |
| | សន្និបាតប្រជាពលរដ្ឋថ្នាក់មូលដ្ឋាន អាស៊ាន |
| | សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន |
| | វេទិកាពលរដ្ឋអាស៊ាន |
| អាស៊ាន | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| | ស្ពានទៅកាន់សន្តិភាពកម្ពុជា |
| | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| | គណបក្សសង្គ្រោះជាតិកម្ពុជាំ |
| គ.ប.ក | គណបក្សប្រជាជនកម្ពុជា |
| | សហគមន៍អឺរ៉ុប |
| | សម្បទានដីសេដ្ឋកិច្ច |
| | ក្រុមប្រឹក្សាសិទ្ធិមនុស្ស |
| | អ្នកការពារសិទ្ធិមនុស្ស |
| | តុលាការយុត្តិធម៌អន្តរជាតិ |
| ក.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ច្បាប់អង្គការ | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល |
| អង្គការ លីកាដូ | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស |
| | ក្រសួងមហាផ្ទៃ |
| | ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ |
| អង្គការ | អង្គការមិនមែនរដ្ឋាភិបាល |
| | ការិយាល័យឧត្តមស្នងការសហប្រជាជាតិ ទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |

| | |
|---|---|
| | គណបក្ស សម រង្ស៊ី |
| | សមាគម ជាងត្នោត |
| ស.ប | សហប្រជាជាតិ |
| ស.ប.ស.ស | សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស |